រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាស

**ស្តីពី**

# ពន្ធលើប្រាក់ចំណេញ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ និង ព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៥ ស្តីពីគោលការណ៍ជាមូលដ្ឋានសំរាប់អនុវត្តការប្រមូលពន្ធលើប្រាក់ចំណេញ
- បានឃើញប្រកាសលេខ ៥៣៩ ប្រក.សហវ.ពដ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០០ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ។

## <u>សំរេច:</u>

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

## ផ្នែកទី ១.១ : មូលដ្ឋាននៃពន្ធ

១- ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់ស្ដីពីសារពើពន្ធ (ចសព) ពន្ធលើប្រាក់ចំណេញ (ពបច) គឺជាបំណុលរបស់បុគ្គលនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស និងជាបំណុលរបស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា ។

## ផ្នែកទី ១.២ : និវាសនជន និងអនិវាសនជន

១- ចំពោះរូបវន្តបុគ្គល ពាក្យអ្នកជាប់ពន្ធនិវាសនជន សំដៅដល់រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន កន្លែងស្នាក់នៅជាគោលដើម ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២ថ្ងៃ នៅក្នុងរយៈពេល១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត ។ សំរាប់លក្ខណៈវិនិច្ឆ័យនៃនិវាសនដ្ឋាននៅកម្ពុជា រូបវន្តបុគ្គលណាដែលមានលក្ខណៈស្របតាមលក្ខណៈវិនិច្ឆ័យចាប់ពីមួយឡើងទៅ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងបីដូចខាងក្រោម ត្រូវបានចាត់ទុកជានិវាសនជននៅព្រះរាជាណាចក្រកម្ពុជា :

ក- លក្ខណៈវិនិច្ឆ័យទី១ត្រូវបានកំណត់ទៅលើនិវាសនដ្ឋានរបស់រូបវន្តបុគ្គល ។ រូបវន្តបុគ្គលមាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើរូបវន្តបុគ្គលនោះ មានជាកម្មសិទ្ធ ឬជួល ឬភិតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន ។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅឬកាន់កាប់ ។

ខ- លក្ខណៈវិនិច្ឆ័យទី២ត្រូវបានកំណត់ទៅតាមកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់រូបវន្តបុគ្គលដែលជាការកំណត់តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅ ដោយផ្អែកទៅលើកត្តានានា ដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់ ។

គ- លក្ខណៈវិនិច្ឆ័យទី៣គឺវត្តមានរបស់រូបវន្តបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២ថ្ងៃ ក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត ។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជា មួយថ្ងៃពេញ ។

២- រូបវន្តបុគ្គលត្រូវបានចាត់ទុកថាអ្នកជាប់ពន្ធអនិវាសនជន ប្រសិនបើបុគ្គលនោះមិនមែនជាអ្នកជាប់ពន្ធនិវាសនជន ប៉ុន្តែទទួលបាននូវប្រាក់ចំណូលប្រភពកម្ពុជា ។

៣- ចំពោះនីតិបុគ្គល ពាក្យអ្នកជាប់ពន្ធនិវាសនជន សំដៅដល់អង្គភាព (នីតិបុគ្គល) ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រង ឬដែលមានទីកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- អង្គភាពមួយដែលមិនមែនជាអង្គភាពនិវាសនជន ដែលកាន់កាប់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាអ្នកជាប់ពន្ធអនិវាសនជន ។

៥- គ្រឹះស្ថានអចិន្ត្រៃយ៍ដែលចែងក្នុងកថាខ័ណ្ឌ៤ សំដៅដល់ទីកន្លែងធ្វើអាជីវកម្មជាប់លាប់ ឬភ្នាក់ងារជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មទាំងអស់ ឬមួយចំណែករបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គ្រឹះស្ថានអចិន្ត្រៃយ៍រួមបញ្ចូលផងដែរនូវសមាគម ឬរូបភាពទំនាក់ទំនងផ្សេងៗ ឬមធ្យោបាយផ្សេងៗ ដែលតាមរយៈនេះ បុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវបានចាត់ទុកថាជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ ។

ក- គ្រឹះស្ថានអចិន្ត្រៃយ៍មានជាអាទិ៍ :

- ទីកន្លែងសំរាប់ធ្វើការងារគ្រប់គ្រង
- សាខារបស់សហគ្រាសបរទេស ភ្នាក់ងារ
- ការិយាល័យរបស់សហគ្រាសបរទេស
- ឃ្លាំង
- រោងចក្រ
- រោងជាង
- កន្លែងយករ៉ែ អណ្តូងប្រេងកាត ឬឧស្ម័នធម្មជាតិ កន្លែងយកថ្ម ឬធនធានធម្មជាតិផ្សេងទៀត
- កសិដ្ឋាន ឬកន្លែងដាំដុះ

ខ- គ្រឹះស្ថានអចិន្ត្រៃយ៍មានរួមបញ្ចូលផងដែរនូវ :

- ការដ្ឋាន កន្លែងសាងសង់ គំរោងការសាងសង់ ឬគំរោងការផ្គុំតំលើង និងសកម្មភាពតាមដានពិនិត្យដែលជាប់ទាក់ទិននឹងទីកន្លែង ឬគំរោងការទាំងនោះ ក្នុងករណីដែលទីកន្លែងសាងសង់ ឬគំរោងការ ឬសកម្មភាពទាំងនោះមានរយៈពេលលើសពីប្រាំមួយខែ ។
- ការផ្តល់សេវាដែលក្នុងនោះមានទាំងសេវាទីប្រឹក្សាផង ធ្វើឡើងដោយនិយោជិត ឬបុគ្គលិកផ្សេងទៀតរបស់សហគ្រាសបរទេស ក្នុងករណីដែលសកម្មភាពទាំងនោះបានប្រព្រឹត្តទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលសរុបលើសពីប្រាំមួយខែនៅក្នុងរយៈពេល១២ខែណាមួយ។

គ- បន្ថែមលើសេចក្តីចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ បុគ្គលណាមួយត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលបុគ្គលនោះបំពេញល័ក្ខខ័ណ្ឌចាប់ពីមួយឡើងទៅក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីដូចតទៅ :

- មាន និងប្រើជាប្រចាំនូវសិទ្ធិអំណាចក្នុងការចុះកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមសហគ្រាសបរទេសណាមួយ
- កាន់កាប់ជាប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជានូវស្តុកទំនិញ ហើយបុគ្គលនោះតែងធ្វើការបញ្ចេញ ឬផ្គត់ផ្គង់ទំនិញចេញពីស្តុកនោះ នៅក្នុងនាមសហគ្រាសបរទេសណាមួយ
- ធ្វើការប្រមូលបុព្វលាភ ឬធ្វើការធានារ៉ាប់រង លើកលែងតែការធានារ៉ាប់រងបន្តនូវហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមសហគ្រាសបរទេសណាមួយ ។

ឃ- ក្នុងការអនុវត្តន៍ រដ្ឋបាលសារពើពន្ធត្រូវវិនិច្ឆ័យទៅតាមករណីដោយឡែកនីមួយៗ ទៅតាមព្រឹត្តិការណ៍ជាក់ស្តែងនៃករណីនីមួយៗថាតើមាន ឬគ្មានគ្រឹះស្ថានអចិន្ត្រៃយ៍ លើកលែងតែការអនុវត្តន៍នូវប្រការទាំងឡាយនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

## ផ្នែកទី ១.៣ : ប្រាក់ចំណូលប្រភពកម្ពុជា

១- ស្របតាមមាត្រា ៣៣ថ្មី និងមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ដោយមិនមានការកំរិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជារួមមាន :

ក-	ការប្រាក់ដែលបង់ដោយសហគ្រាសអនិវាសនជន ឬក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ខ-	ភាគលាភដែលបានបែងចែកដោយសហគ្រាសអនិវាសនជន

គ-	ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឃ-	ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេស ដែលបានទូទាត់ដោយបុគ្គលនិវាសនជន

ង-	ប្រាក់ចំណូលដែលបានមកពី ចលនទ្រព្យ ឬអចលនទ្រព្យ ក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ច-	ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបីដែលបានទូទាត់ដោយបុគ្គលនិវាសនជនឬបុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឆ-	ផលចំណេញពីការលក់អចលនទ្រព្យ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ជ-	បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឈ-	ផលចំណេញពីការលក់ចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ញ-	ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

បន្ថែមលើប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា ៣៣ថ្មី និងមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព អ្នកជាប់ពន្ធនិវាសនជននៅកម្ពុជា និងអ្នកជាប់ពន្ធអនិវាសនជន អាចមានប្រាក់ចំណូលប្រភពកម្ពុជាផ្សេងទៀតពីការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូចមានចែងក្នុងកថាខ័ណ្ឌ ៧ នៃមាត្រា ៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ពាក្យ "អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិត និងការលក់ទំនិញ (ការផ្គត់ផ្គង់ទំនិញ) ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត ។ ម្យ៉ាងទៀត កថាខ័ណ្ឌ ៧ នៃមាត្រា ៨៨ នៃចសព បានកំណត់ "សកម្មភាពសេដ្ឋកិច្ច" ថាជាសកម្មភាពរបស់បុគ្គលដែលធ្វើ ជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកចំណេញក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ ។

## ផ្នែកទី ១.៤ : ប្រាក់ចំណូលប្រភពបរទេស

១-	ស្របតាមមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ប្រាក់ចំណូលណាមួយដែលមិនត្រូវបានកំណត់ថាជាប្រាក់ចំណូលប្រភពកម្ពុជា ដូចមានចែងក្នុងផ្នែកទី ១.៣ នៃប្រកាសនេះ និងមាត្រា ៣៣ថ្មី និងមាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព និងមាត្រា ៣៥ នៃចសព ត្រូវបានចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស ។

## ផ្នែកទី ១.៥ : សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការកំណត់ប្រភពប្រាក់ចំណូល

១- ដូចមានចែងក្នុងមាត្រា ៣៥ នៃចសព ក្នុងករណីដែលគ្មានពត៌មានគ្រប់គ្រាន់ដើម្បីកំណត់ប្រភពចំណូល ឬបើសិនជាវិធាននានាដែលមានរួចមកហើយ ពុំអាចឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេនោះ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ ។

## ផ្នែកទី ១.៦ : ប្រាក់ចំណូលមិនជាប់ពន្ធលើប្រាក់ចំណេញ

១- ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្សឬជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម ដូចមានចែងក្នុងប្រកាសលេខ ៣៨៦ ប្រក.សហវ.ពដ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេ ។

២- ចំពោះប្រាក់ចំណូលដែលជាថ្លៃឈ្នួលផ្ទះ និងដី ត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

ក- ប្រាក់ចំណូលបានមកពីការជួលផ្ទះនិងដីរបស់បុគ្គល ដែលមិនស្ថិតក្នុងក្របខ័ណ្ឌត្រូវយកពន្ធតាមរបបពិត មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេ ។

ខ- ដោយឡែកចំពោះប្រាក់ចំណូលបានមកពីការជួលផ្ទះនិងដី ដែលបានកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់បុគ្គលជាប់ពន្ធតាមរបបពិត ប្រាក់ចំណូលនេះត្រូវដាក់រួមគ្នាជាមួយផលផ្សេងទៀតរបស់បុគ្គល ដើម្បីបង្កើតជាលទ្ធផលសំរាប់កំណត់ពន្ធលើប្រាក់ចំណេញ ។

៣- មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេនូវ ប្រាក់ចំណូល ឬប្រាក់ចំណេញ ដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបពិតផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃ ឬកែច្នៃហើយក៏ដោយទៅតាមទំលាប់នៃការងារកសិកម្ម ។ ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្ម រួមទាំងការកែច្នៃ ការរក្សាគុណភាព ការវេចខ្ចប់សំរាប់លក់ ពុំត្រូវបានចាត់ទុកជាទំលាប់នៃការងារកសិកម្មឡើយ ។ ទោះក្នុងករណីណាក៏ដោយ ប្រសិនបើសាមីបុគ្គលជាអ្នកជាប់ពន្ធតាមរបបពិត ឬប្រសិនបើសកម្មភាពកសិកម្មរបស់បុគ្គលមានផលរបរច្រើនលើសពីកំរិតអប្បបរមាត្រូវជាប់ពន្ធតាមរបបពិត ដែលតម្រូវឱ្យបុគ្គលមានកាតព្វកិច្ចត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបពិត ប្រាក់ចំណូលពីសកម្មភាពកសិកម្មរបស់បុគ្គលនេះ ត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមគោលការណ៍ទូទៅ ។

៤- មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេ នូវប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលរបស់ស្ថាប័នរាជរដ្ឋាភិបាល លើកលែងតែស្ថាប័នណាដែលធ្វើអាជីវកម្មរកចំណេញ ដូចជាសហគ្រាសសាធារណៈជាដើម ។

៥- មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេ នូវប្រាក់ចំណូលរបស់អង្គការដូចមានចែងក្នុងវាក្យខ័ណ្ឌ ខ និងវាក្យខ័ណ្ឌ គ នៃមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។

៦- ចំពោះអង្គការដូចមានចែងក្នុងកថាខ័ណ្ឌ ៥ នៃផ្នែកនេះ ដើម្បីបានទទួលការលើកលែងពន្ធ សាមីអង្គការត្រូវដាក់ពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវផ្តល់ឯកសារស្តីពី :

ក- គោលដៅ និងកម្មវត្ថុរបស់សាមីអង្គការ ។

ខ- ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលនិវាសជននានា ដែលជាសមាជិកក្រុមប្រឹក្សាភិបាលរបស់សាមីអង្គការ (ប្រសិនបើមាន) ។

គ- ឈ្មោះនិងអាសយដ្ឋានរបស់នាយកឬបណ្ណានាយក ដែលទទួលខុសត្រូវលើប្រតិបត្តិការរបស់សាមីអង្គការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើសាមីអង្គការមានចំណងទាក់ទងជាមួយអង្គការនៅខាងក្រៅព្រះរាជាណាចក្រកម្ពុជា ។

ឃ- ប្រភព និងការប្រើប្រាស់មូលនិធិទាំងអស់ដែលបានផ្តល់ឱ្យសំរាប់ប្រតិបត្តិការរបស់សាមីអង្គការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ទ្រព្យសកម្មនានាដែលសាមីអង្គការ ឬអង្គការមេកាន់កាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច- តារាងគណនីរបស់សាមីអង្គការ ។ តារាងនេះត្រូវដាច់ដោយឡែកពីតារាងគណនីរបស់អង្គការជាប់ទាក់ទិនដែលស្ថិតនៅខាងក្រៅព្រះរាជាណាចក្រកម្ពុជា ។

៧- ការលើកលែងដូចមានចែងក្នុងកថាខ័ណ្ឌ ៥ នៃផ្នែកនេះ មិនត្រូវអនុវត្តទេចំពោះប្រាក់ចំណូលពីទ្រព្យសម្បត្តិ ឬពីអាជីវកម្ម ដែលពុំមានទាក់ទិនជាសំខាន់ដល់គោលដៅ ឬមុខងារដែលជាមូលដ្ឋាននៃការលើកលែងពន្ធចំពោះអង្គការមិនស្វែងរកចំណេញ ។

៨- ក្នុងករណីមានការប្រែប្រួលនៅក្នុងល័ក្ខខ័ណ្ឌនានា ដែលមានចុះបញ្ជាក់នៅក្នុងពាក្យសុំលក្ខណៈសម្បត្តិលើកលែងពន្ធ សាមីអង្គការត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការប្រែប្រួលនេះ ។

៩- លក្ខណៈសម្បត្តិលើកលែងពន្ធដែលបានផ្តល់ឱ្យតាមការយល់ព្រមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តមានតំលៃអនុវត្ត ដរាបណាសាមីអង្គការបំពេញបាន និងបន្តបំពេញបាននូវល័ក្ខខ័ណ្ឌនានាដែលមានបញ្ជាក់នៅក្នុងពាក្យសុំដែលនាំឱ្យមានការចេញសេចក្តីសំរេចយល់ព្រមនេះ ។

១០- ប្រាក់ចំណូលពីអាជីវកម្មមិនទាក់ទិនដូចមានចែងក្នុងកថាខ័ណ្ឌ ៧ នៃផ្នែកនេះ ត្រូវជាប់ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា ។ វិធានសំរាប់កំណត់ប្រាក់ចំណេញនៃអាជីវកម្មមិនទាក់ទិន នឹងមានចែងនៅក្នុងប្រកាសមួយដោយឡែក ។

## ជំពូកទី២
## វិធានទូទៅស្តីពីប្រាក់ចំណេញជាប់ពន្ធ

### ផ្នែកទី ២.១ : រយៈពេលកំណត់ពន្ធ

១- ដូចមានចែងក្នុងមាត្រា ៩ នៃចសព :

ក- ពន្ធលើប្រាក់ចំណេញ (ពបច) អនុវត្តចំពោះរបបពិត ត្រូវគណនាចេញពីលទ្ធផលនៃតារាងតុល្យការសំរេចបានក្នុងឆ្នាំសារពើពន្ធកន្លងទៅ ។

ខ- ប្រសិនជាពុំមានតុល្យការណាមួយបានបញ្ឈប់ក្នុងអំឡុងនៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់ ត្រូវគិតយកលើប្រាក់ចំណេញក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ ។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី ៣១ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។

គ- កាលបើមានតារាងតុល្យការជាច្រើនត១គ្នាក្នុងអំឡុងនៃឆ្នាំមួយដដែល លទ្ធផលនៃតារាងតុល្យការទាំងឡាយ ត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធដែលត្រូវបង់ ។

ឃ- គោលការណ៍ដោយឡែកនានាសំរាប់ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបម៉ៅការ មានបញ្ជាក់នៅក្នុងជំពូកទី ១៤ នៃប្រកាសនេះ ។

២- ចំពោះសហគ្រាសដែលផ្អាកសកម្មភាព ត្រូវកំណត់ពន្ធភ្លាមលើប្រាក់ចំណេញដែលសំរេចបានពីថ្ងៃទី០១ ខែមករា ឬពីថ្ងៃបិទការិយបរិច្ឆេទក្រោយបង្អស់ដែលបានកំណត់ពន្ធ រហូតដល់ថ្ងៃផ្អាកសកម្មភាពជាស្ថាពរ ក្នុងនេះ :

ក- ចំពោះសហគ្រាសឯកបុគ្គល ត្រូវគិតបញ្ចូលផងដែរក្នុងប្រាក់ចំណេញជាប់ពន្ធនូវតំលៃលើសនៃទ្រព្យសកម្ម ដែលអាចកើតមាន ។ ទ្រព្យសកម្មមិនបានលក់នាថ្ងៃផ្អាកសកម្មភាព (អចលកម្ម ស្តុកទំនិញ វត្ថុធាតុដើម ការងារកំពុងដំណើរការ...) ត្រូវចាត់ទុកថាជាការយកវិញរបស់ម្ចាស់សហគ្រាស (ផ្ទេរពីបេតិកភ័ណ្ឌអាជីវកម្មទៅបេតិកភ័ណ្ឌឯកជន) ។ ទ្រព្យសម្បត្តិទាំងនេះត្រូវវាយតំលៃតាមតំលៃទីផ្សារ ដើម្បីគិតគូរតំលៃលើសដែលត្រូវបញ្ចូលទៅក្នុងលទ្ធផលជាប់ពន្ធ ។

ខ- ចំពោះសហគ្រាសនីតិបុគ្គល បែបបទអនុវត្តមានបញ្ជាក់នៅក្នុងជំពូក ១០ នៃប្រកាសនេះ ។

## ផ្នែកទី ២.២ : និយមន័យប្រាក់ចំណេញជាប់ពន្ធ

១- ដូចមានចែងក្នុងមាត្រា ៧ នៃចសព ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទដែលសហគ្រាសសំរេចបាន រួមបញ្ចូលទាំងតំលៃលើសបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្មឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលអំពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ឬវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផង ។ តាមនិយមន័យនេះ ការធ្វើអាជីវកម្មអ្វីមួយដែលខុសច្បាប់ គ្មានឥទ្ធិពលអ្វីទៅលើភាពត្រូវជាប់ពន្ធលើប្រាក់ចំណេញនោះទេ ។

២- ដូចមានចែងក្នុងមាត្រា ៨ នៃចសព ប្រាក់ចំណេញជាប់ពន្ធកើតចេញពីចំនួនលើសនៃផលដុល ឬចំណូលដុលដែលសំរេចបានអាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញនិងរក្សាទុកនូវចំណេញ ។ ដូច្នេះប្រាក់ចំណេញជាប់ពន្ធកើតចេញពីការកាត់កងគ្នារវាងចំណូលដុល និងបន្ទុកទាំងអស់ដែលមានប្រភពពីប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាសក្នុងរយៈកាលកំពុងដំណើរការឬនៅពេលបញ្ចប់អាជីវកម្ម ។ តាមន័យគណនេយ្យ ប្រាក់ចំណេញនេះគឺជាសមតុល្យនៃគណនីលទ្ធផល ។ ប្រតិបត្តិការដែលសហគ្រាសសំរេចបាន អាចទាក់ទងដោយផ្ទាល់នឹងកម្មវត្ថុរបស់សហគ្រាស ឬអាចមិនទាក់ទងដោយផ្ទាល់នឹងសកម្មភាពរបស់សហគ្រាស ។ ប្រតិបត្តិការនេះអាចប្រព្រឹត្តទៅក្នុងលក្ខណៈជាគោលដើមឬក្នុងលក្ខណៈបន្ទាប់បន្សំ ។ ប្រតិបត្តិការទាំងនេះ មានជាអាទិ៍ :

ក- ការលក់ ការផ្គត់ផ្គង់សេវា ការងារផ្សេងៗ ឬប្រតិបត្តិការដទៃទៀត (ជំនួញជើងសារ ការងារយកកំរៃជើងសារ សម្បទានសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម...)

ខ- ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្ម ។ ក្នុងន័យនេះការបញ្ចេញ គឺគ្រប់ប្រតិបត្តិការ ឬគ្រប់ព្រឹត្តិការណ៍ដែលនាំដល់ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្មរបស់សហគ្រាស (ការលក់ ការដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ឧបហារិត ការដោះដូរ ការបែងចែកអំណោយ ការដកចេញនូវទ្រព្យសកម្ម...) ។

៣- ប្រាក់ចំណេញជាប់ពន្ធ គឺជាចំនួនលំអៀងរវាងតំលៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទនិងនាពេលបើកនៃរយៈកាលកំណត់ពន្ធ ។

ក- ប្រាក់ចំណេញជាប់ពន្ធ គឺជាចំនួនលំអៀងរវាងតំលៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទនិងនាពេលបើកនៃរយៈកាលមួយ ដែលលទ្ធផលក្នុងរយៈកាលនោះត្រូវបានប្រើប្រាស់ជាមូលដ្ឋានសំរាប់គិតពន្ធ ដោយត្រូវដកចេញនូវឧបហារិតបន្ថែម និងបូកចូលនូវរាល់ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការកាត់យកមុនដែលម្ចាស់សហគ្រាសឯកបុគ្គលបានធ្វើនៅក្នុងគ្រា ។ និយមន័យនេះបានបង្ហាញឱ្យឃើញថា នៅក្នុងប្រាក់ចំណេញជាប់ពន្ធក៏មានផងដែរ នូវប្រាក់ចំណេញទាំងឡាយដែលបានកើតឡើងក្នុងកាលៈទេសៈដែលសហគ្រាសមិនបានធ្វើប្រតិបត្តិការណាមួយ ដូចជាករណីតម្លៃលើសដែលសំរេចបានក្នុងពេលដក

ហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ក្នុងពេលរឹបអូស ឬក្នុងពេលមានព្រឹត្តិការណ៍ដែលនាំដល់ការទទួលប្រាក់សំណងធានារ៉ាប់រង ។

ខ- ទ្រព្យសកម្មសុទ្ធ គឺជាតំលៃពិតប្រាកដនៃទ្រព្យសកម្មសរុប ដកផលបូកនៃខ្ទង់នានាខាងអកម្ម ដែលផ្សំដោយឥណទេយ្យតតិយជន រំលស់ និងសំវិធានធនដែលបានបង្កើតឡើងដោយស្របច្បាប់ ។

ខ១- ទ្រព្យសកម្មសុទ្ធ រួមមានខ្ទង់សំខាន់ៗដូចតទៅ :

- អចលកម្ម
- តំលៃអចលកម្មផ្សេងទៀត (ឥណទេយ្យរយៈពេលវែង និងរយៈពេលមធ្យម, ភាគកម្មអចល័ត, មូលប័ត្រ...)
- ស្តុក (ទំនិញ វត្ថុធាតុដើម និងសំភារៈផ្គត់ផ្គង់ផ្សេងៗ សំបកវេចខ្ចប់ ផលិតផលការងារកំពុងដំណើរការ...)
- ប័ណ្ណបណ្តាក់ទុនផ្សេងៗ ប្រាក់នៅធនាគារ ប្រាក់ក្នុងបេឡា... ។

សោហ៊ុយស្រាវជ្រាវ និងអភិវឌ្ឍន៍ និងសោហ៊ុយអចលកម្មផ្សេងទៀត : សោហ៊ុយទាំងនេះមិនបង្កើតបានជាតំលៃពិតប្រាកដនៃទ្រព្យសកម្មទេ ។

ខ២- ឥណទេយ្យនៃតតិយជន : នេះគឺជាបំណុលប្រាកដប្រជា និងជាស្ថាពរទាំងគោលការណ៍ និងទាំងទឹកប្រាក់របស់វាដែលបានចុះកិច្ចសន្យាសំរាប់តម្រូវការអាជីវកម្ម និងដែលផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងធម្មតារបស់សហគ្រាស ។

ខ៣- រំលស់ និងសំវិធានធន : ខ្ទង់ទាំងនេះត្រូវតែបានបង្កើតឡើងដោយស្របច្បាប់ ។

គ- ឧបហារិត : ឧបហារិតទោះជាប្រាក់ ឬជាវត្ថុក្តី មិនមែនជាប្រាក់ចំណេញជាប់ពន្ធទេ ។ ឧបហារិតបន្ថែមដោយម្ចាស់សហគ្រាសឯកបុគ្គលនៅក្នុងករណីដែលមានសក្ខីកម្មត្រឹមត្រូវនោះ ត្រូវផាត់ចេញពីចំនួនលំអៀងរវាងតំលៃទ្រព្យសកម្មពិតនាពេលបិទ និងនាពេលបើកនៃរយៈពេលកំណត់ពន្ធ ។

ឃ- ការដកយកប្រើប្រាស់ផ្ទាល់ខ្លួន(ឬការកាត់យកមុន) របស់ម្ចាស់សហគ្រាសឯកបុគ្គល មានជាអាទិ៍:

ឃ១- ការដកយកនូវវត្ថុធាតុដើម ផលិតផលសំរេច ទំនិញ សេវា... សំរាប់តម្រូវការជាឯកជនរបស់ម្ចាស់សហគ្រាសឯកបុគ្គលនិងគ្រួសាររបស់គេ (ឧទាហរណ៍ : របស់ហូប សំលៀកបំពាក់ បរិក្ខារគេហកិច្ច ចំណីអាហារសំរាប់អ្នកបំរើការនៅភោជនីយដ្ឋាន សំភារៈ និងសេវាផ្សេងៗ សំរាប់សហគ្រិនសំណង់...)

ឃ២- ការប្រើប្រាស់សំរាប់តម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសឯកបុគ្គល នូវទ្រព្យសកម្មរបស់សហគ្រាស (ផ្ទះ រថយន្ត...)

ឃ៣- ការយកធ្វើជាបន្ទុករបស់សហគ្រាស នូវសោហ៊ុយសំរាប់តម្រូវការផ្ទាល់ខ្លួន របស់ម្ចាស់សហគ្រាសឯកបុគ្គល និងគ្រួសាររបស់គេ (ឈ្នួលផ្ទះ សោហ៊ុយធ្វើដំណើរ សោហ៊ុយលើអ្នកបំរើ...)

ឃ៤- ការដកយកប្រើប្រាស់ផ្ទាល់ខ្លួននូវសាច់ប្រាក់ មានជាអាទិ៍ :

- លាភការផ្តល់ជូនម្ចាស់សហគ្រាសឯកបុគ្គល ឬសហព័ទ្ធរបស់គេ
- រាល់ទឹកប្រាក់ដែលបានដកយកទៅប្រើប្រាស់ផ្ទាល់ខ្លួនពីក្នុងសហគ្រាស ( ប្រាក់ដកពីបេឡា ឬ ធនាគារ ប្រាក់កាត់យកផ្ទាល់ពីការទូទាត់របស់អតិថិជន...)

ង- ការលក់ឱ្យម្ចាស់ភាគទុននូវទំនិញឬសេវាតាមថ្លៃទាបជាងថ្លៃធម្មតាដែលអនុវត្តចំពោះតតិយជន : នេះគឺជាសទ្ធាទានមួយមិនធម្មតាដែលត្រូវជាប់ពន្ធ ។

ច- និយមន័យនៃប្រាក់ចំណេញជាប់ពន្ធនេះ អាចញ៉ាំងជាអាទិ៍ឱ្យមានការកំណត់ពន្ធលើ :

- ការលុបចោលបំណុលខាងអកម្ម
- ការកាត់បន្ថយបំណុល ដែលម្ចាស់បំណុលបានផ្តល់ឱ្យសហគ្រាស
- គណនីទាំងឡាយនៃទ្រព្យអកម្ម ដែលជាក់ស្តែងគ្មានការពិត (គ្រប់បំណុលគ្មានភស្តុតាងបញ្ជាក់ ដែលនាំដល់ការកើនឡើងនូវទ្រព្យសកម្មពិត ត្រូវតែគិតបញ្ចូលមកវិញក្នុងប្រាក់ចំណេញជាប់ពន្ធ)
- ការបង្កើតឡើងវិញខាងទ្រព្យសកម្មនូវខ្ទង់ដែលភ្លេច (ដោយហេតុថាមានការកើនឡើងនៃទ្រព្យសកម្មសុទ្ធ)

ឆ- និយមន័យនៃប្រាក់ចំណេញជាប់ពន្ធ ដែលផ្អែកលើការប្រែប្រួលនៃទ្រព្យសកម្មសុទ្ធបានអនុញ្ញាតឱ្យមានការកែតម្រូវលើរាល់ការខុសឆ្គង ដែលមាននៅក្នុងតារាងតុល្យការនៅពេលបញ្ចប់ការិយបរិច្ឆេទណាមួយ ហើយប្រសិនបើការកែតម្រូវនេះនាំឱ្យ ឬមានការកើនឡើងនៃគណនីទ្រព្យសកម្ម ( អចលកម្ម ស្តុក សាច់ប្រាក់ គណនីអតិថិជន ឬគណនីឥណាយិកផ្សេងៗ..) ឬមានការថយចុះនៃគណនីទ្រព្យអកម្មទាំងឡាយ ឬមានការថយចុះនៃគណនីវិលស់ឬសិវិធានធន ការកើនឡើងនៃទ្រព្យសកម្មសុទ្ធដែលកើតចេញពីការកែតម្រូវនេះតម្រូវឱ្យមានការកំណត់ឡើងវិញនូវប្រាក់ចំណេញជាប់ពន្ធនៃការិយបរិច្ឆេទនោះ ។ អ្នកជាប់ពន្ធមានសិទ្ធិកែនូវ តារាងតុល្យការនាពេលបើកនៃការិយបរិច្ឆេទ ដែលនៅក្នុងរយៈកាលនៃអាជ្ញាយុកាល លើកលែងតែតារាងតុល្យការនាពេលបើកនៃការិយបរិច្ឆេទទីមួយ នៃរយៈកាលនៃអាជ្ញាយុកាល (ដែលត្រូវស្ថិតនៅខាងក្រៅរយៈកាលនៃអាជ្ញាយុកាល) ដែលមិនត្រូវប៉ះពាល់ទេ ។

## ផ្នែកទី ២.៣ : និយមន័យនៃទ្រព្យសកម្មអាជីវកម្ម

១- ដោយហេតុថា តំលៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទនិងពេលបើកការិយបរិច្ឆេទ ត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសំរាប់កំណត់ពន្ធនោះ ដូច្នេះត្រូវមានការកំណត់ប្រភេទនៃទ្រព្យសកម្មដែលជាចំណែកនៃបេតិកភ័ណ្ឌរបស់សហគ្រាស (ឬទ្រព្យសកម្មអាជីវកម្ម) ។ និយមន័យនៃទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាស មានការខុសគ្នាអាស្រ័យដោយសហគ្រាសនោះជាសហគ្រាសឯកបុគ្គលឬជាសហគ្រាសនីតិបុគ្គល ។

២- ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសឯកបុគ្គល ត្រូវគោរពតាមគោលការណ៍ដូចតទៅ :

ក- សំរាប់គោលដៅខាងសារពើពន្ធ ម្ចាស់សហគ្រាសត្រូវញែកឱ្យដាច់ពីគ្នានៅក្នុងបេតិកភ័ណ្ឌរបស់ខ្លួនរវាងចំណែកទាំងឡាយដែលបង្កើតទ្រព្យសកម្មអាជីវកម្មនៃសហគ្រាសឯកបុគ្គល ជាមួយនឹងអ្វីដែលបង្កើតជាបេតិកភ័ណ្ឌឯកជនរបស់ម្ចាស់សហគ្រាស ។ ការកត់ត្រាក្នុងតារាងតុល្យការបង្កើតជាលក្ខណៈវិនិច្ឆ័យខុសគ្នា រវាងទ្រព្យសកម្មអាជីវកម្ម និងបេតិកភ័ណ្ឌឯកជន ។

ខ- ប្រព័ន្ធសារពើពន្ធកម្ពុជា គឺជាប្រព័ន្ធ "ពន្ធវិភាគតាមប្រភេទចំណូល" ដែលឈរលើការកំណត់ពន្ធចំពោះប្រភេទចំណូលនីមួយៗដាច់ពីគ្នា ហើយដែលក្នុងនេះសំរាប់ប្រភេទចំណូលនីមួយៗ ត្រូវគោរពទៅតាមបែបបទកំណត់មូលដ្ឋានគិតពន្ធ និងទៅតាមការគិតពន្ធដោយឡែកៗ ។

គ- ការគោរពតាមវិធានទាំងឡាយអំពីមូលដ្ឋានកំណត់ពន្ធ និងការគិតពន្ធនៃបណ្តាពន្ធវិភាគតាមប្រភេទចំណូល បាននាំដល់ការបង្កើតចេញនូវគោលការណ៍ដែលថា ម្ចាស់សហគ្រាសឯកបុគ្គលពុំមានសិទ្ធិអាចកត់ត្រាក៏បាន ឬមិនកត់ត្រាក៏បាននូវចំណែកណាមួយនៃទ្រព្យសកម្មឬទ្រព្យអកម្មនោះទេ ។

ឃ- សំរាប់គោលដៅខាងសារពើពន្ធ ម្ចាស់សហគ្រាសឯកបុគ្គលត្រូវកត់ត្រាក្នុងតារាងតុល្យការនៃសហគ្រាសខ្លួននូវ ចំណែកទាំងអស់នៃទ្រព្យសកម្មនិងទ្រព្យអកម្មដែលជាប់ទាក់ទងនឹងប្រតិបត្តិការអាជីវកម្ម ។ តាមនេះ ម្ចាស់សហគ្រាសត្រូវកត់ត្រាជាដាច់ខាតក្នុងតារាងតុល្យការនៃសហគ្រាសខ្លួននូវ :

- រាល់អចលកម្មប្រើប្រាស់សំរាប់ការធ្វើសកម្មភាពអាជីវកម្ម ( ជាអាទិ៍មាន លំនៅដ្ឋាន មូលនិធិពាណិជ្ជកម្ម សំភារៈដឹកជញ្ជូន...)។ អចលកម្មទាំងឡាយដែលប្រើប្រាស់ចំរុះ ( សំរាប់អាជីវកម្ម និងតម្រូវការជាឯកជន) ក៏ត្រូវតែកត់ត្រាផងដែរក្នុងទ្រព្យសកម្មនៃតារាងតុល្យការ
- រាល់ទ្រព្យសកម្មចរន្តដែលទាក់ទងដល់ការធ្វើសកម្មភាពអាជីវកម្ម ( ស្តុកទំនិញ ផលិតផល វត្ថុធាតុដើម តណទេយ្យ ប្រាក់ក្នុងដៃ...)
- រាល់តំលៃនៃទ្រព្យអកម្មទាក់ទងដល់ការធ្វើសកម្មភាពអាជីវកម្ម ( កម្ចីសំរាប់ធ្វើហិរញ្ញប្បទានដល់ការទិញអចលកម្ម បំណុលរយៈពេលខ្លី មធ្យម និងវែង ...) ។

ង- ម្ចាស់សហគ្រាសឯកបុគ្គល មិនត្រូវបានអនុញ្ញាតឱ្យកត់ត្រាក្នុងតារាងតុល្យការសហគ្រាសខ្លួនទេនូវទ្រព្យសកម្ម ឬទ្រព្យអកម្មដែលមិនទាក់ទងដល់ការធ្វើសកម្មភាពអាជីវកម្ម ។ តាមន័យនេះ ម្ចាស់សហគ្រាសមិនអាចកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការសហគ្រាសខ្លួនទេ នូវអចលនទ្រព្យឬចំណែកណាមួយនៃអចលនទ្រព្យដែលមិនបំរើសកម្មភាពអាជីវកម្ម ( ឧទាហរណ៍ ផ្ទះសំរាប់ស្នាក់នៅ ) ។ ដូចគ្នាដែរ ការឱ្យខ្ចី ឬការខ្ចីបុល ដែលមិនទាក់ទងដល់សកម្មភាពអាជីវកម្ម មិនអាចកត់ត្រាក្នុងបញ្ជីគណនេយ្យសហគ្រាសបានទេ ។ ដូច្នេះតារាងតុល្យការនៃសហគ្រាសឯកបុគ្គល ត្រូវតែគូសបញ្ជាក់ឱ្យឃើញនូវរាល់ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលមានលក្ខណៈបំរើអាជីវកម្មតាមចរឹតតាមការដាក់ប្រើប្រាស់ឬតាមគោលដៅ ប៉ុន្តែត្រូវបង្ហាញតែតំលៃទាំងនេះតែប៉ុណ្ណោះ ។

ច- វិបាកសារពើពន្ធដែលផុសចេញពីការញែកដាច់ពីគ្នារវាងទ្រព្យសកម្មអាជីវកម្ម និងបេតិកភ័ណ្ឌឯកជនមានលក្ខណៈសំខាន់ណាស់ ពីព្រោះ :

- បន្ទុកដែលយកមកគិតសំរាប់ការកំណត់លទ្ធផលជាប់ពន្ធ គឺជាបន្ទុកទាំងឡាយដែលទាក់ទងនឹងចំណែកនៃទ្រព្យសកម្មអាជីវកម្ម ។ តាមន័យនេះ បន្ទុកទាំងឡាយដែលទាក់ទងដល់ទ្រព្យសកម្មមិនបានកត់ត្រាខាងសកម្មនៃតារាងតុល្យការ មិនត្រូវកាត់ចេញទេ ។ បន្ទុកទាំងឡាយនៃកម្មសិទ្ធិ (សោហ៊ុយលទ្ធកម្ម រំលស់ ធានារ៉ាប់រង ជួសជុលធំ...) ដែលទាក់ទងដល់ទ្រព្យសកម្មដែលមិនបានកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការក៏មិនត្រូវកាត់ចេញដែរ ទោះបីទ្រព្យសកម្មទាំងនេះបានចូលរួមក្នុងអាជីវកម្មក៏ដោយ ។
- ការផ្ទេរទ្រព្យសកម្មពីទ្រព្យសកម្មអាជីវកម្មទៅបេតិកភ័ណ្ឌឯកជន ( ដកចេញពីទ្រព្យសកម្មអាជីវកម្ម ) គឺជាការលក់ដែលបណ្តាលឱ្យមានតំលៃលើសត្រូវជាប់ពន្ធ ឬតំលៃខ្វះត្រូវកាត់ចេញ ។
- ប្រតិបត្តិការបញ្ច្រាស គឺការផ្ទេរទ្រព្យសកម្មពីបេតិកភ័ណ្ឌឯកជនទៅទ្រព្យសកម្មអាជីវកម្ម គឺជាឧបហារិត ។ ឧបហារិតនេះ ត្រូវធ្វើគណនេយ្យកម្មតាមតំលៃពិតប្រាកដនាថ្ងៃដែលមានការផ្ទេរនេះ ។

៣- ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសនីតិបុគ្គល ត្រូវគោរពតាមគោលការណ៍ដូចតទៅ :

ក- ទ្រព្យសកម្មអាជីវកម្ម គឺជាបេតិកភ័ណ្ឌរបស់សហគ្រាស ។ ជាគតិយុត្តិ ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសនីតិបុគ្គល ត្រូវដាច់ដោយឡែកពីបេតិកភ័ណ្ឌរបស់អ្នកចូលហ៊ុនឬម្ចាស់ហ៊ុន ។

ខ- សំរាប់ក្រុមហ៊ុនដែលបង្កើតឡើងដោយគ្មានមូលដ្ឋានច្បាប់ ទ្រព្យសកម្មនានាដែលអ្នកចូលហ៊ុនបានយល់ព្រមដាក់ជាកម្មសិទ្ធិរួម ត្រូវតែកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការ ។

## ផ្នែកទី ២.៤ : វិធានគណនេយ្យ

១- ចំពោះអ្នកជាប់ពន្ធតាមរបបពិត ដែលប្រើវិធីគណនេយ្យតាមប្រព័ន្ធគណនេយ្យជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី ។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់ ។

២- ចំពោះកិច្ចការជំនួញដែលគិតតំលៃជារូបិយវត្ថុបរទេស ត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

ក- សហគ្រាសត្រូវអនុវត្តតាមវិធានទូទៅដែលបានកំណត់ថា ចំពោះរាល់កិច្ចការជំនួញដែលបានធ្វើឡើងជារូបិយវត្ថុបរទេស ត្រូវកត់ត្រាចូលក្នុងបញ្ជីគណនេយ្យជាប្រាក់រៀលកម្ពុជា ដោយប្រើអត្រាប្តូរប្រាក់នាថ្ងៃធ្វើកិច្ចការជំនួញ (ថ្ងៃធ្វើវិក្កយបត្រ ឬថ្ងៃទូទាត់ប្រាក់បុរេប្រទាន ឬប្រាក់រំដោះ) ។

ខ- ក្នុងករណីមានប្រព័ន្ធធានាការប្តូរប្រាក់ ឥណទេយ្យ និងបំណុល ត្រូវប្តូរជាប្រាក់រៀលលើមូលដ្ឋាននៃអត្រាប្តូរប្រាក់នាពេលកំណត់ដែលបានចែងក្នុងកិច្ចសន្យា ។

គ- កាលណាឥណទេយ្យនិងបំណុលបានកើតឡើងនិងត្រូវបានទូទាត់នៅក្នុងការិយបរិច្ឆេទតែមួយនោះ ចំនួនលំអៀងដែលបានពិនិត្យឃើញរវាងតំលៃនាពេលកើតឡើងនិងកត់ចូលបញ្ជី និងតំលៃនាពេលទូទាត់សងគឺបង្កើតបានជាខាតឬចំណេញពីការប្តូរប្រាក់ ដែលត្រូវកត់ត្រាក្នុងបន្ទុកហិរញ្ញវត្ថុឬផលហិរញ្ញវត្ថុនៃការិយបរិច្ឆេទ ។

ឃ- នាពេលបញ្ចប់ការិយបរិច្ឆេទ ឥណទេយ្យនិងបំណុលជារូបិយវត្ថុបរទេស ត្រូវវាយតំលៃតាមអត្រាប្តូរប្រាក់នាថ្ងៃបិទការិយបរិច្ឆេទ ។ ប្រាក់លំអៀងបានមកពីការវាយតំលៃនេះត្រូវកត់ត្រាភ្លាមជា ខាតឬចំណេញពីការប្តូរប្រាក់ ។

ង- នៅក្នុងការិយបរិច្ឆេទបន្ទាប់ នៅពេលទូទាត់ឥណទេយ្យ ឬបំណុលពាក់ព័ន្ធខាត ឬចំណេញពីការប្តូរប្រាក់ ត្រូវកត់ត្រាឡើងតាមប្រាក់លំអៀងរវាងតំលៃរបស់វានៅពេលទូទាត់ និងតំលៃរបស់វានាពេលបិទនៃការិយបរិច្ឆេទមុន ។

ច- ចំពោះសាច់ប្រាក់ជារូបិយវត្ថុបរទេសដែលសហគ្រាសមាននៅចុងការិយបរិច្ឆេទ សហគ្រាសត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធានដែលបានចែងសំរាប់ឥណទេយ្យ និងបំណុលនៃវាក្យខ័ណ្ឌ ឃ នៃកថាខ័ណ្ឌនេះ ។

## ផ្នែកទី ២.៥ : ការកែតម្រូវក្រៅគណនេយ្យ

១- តាមវិធានគណនេយ្យ ប្រាក់ចំណេញពិត គឺជាសមតុល្យនៃគណនី"លទ្ធផលនៃការិយបរិច្ឆេទ" ។ ប៉ុន្តែដោយហេតុមានបទប្បញ្ញត្តិសារពើពន្ធដោយឡែកនោះ លទ្ធផលពិតគណនេយ្យត្រូវតែជាកម្មវត្ថុនៃការកែតម្រូវក្រៅគណនេយ្យដែលមានការបញ្ចូលមកវិញ និងការកាត់ចេញ ដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃផ្នែកទី ៩.១ នៃប្រកាសនេះ ។

## ផ្នែកទី ២.៦ : គោលការណ៍រួមស្តីពីបន្ទុកភស្តុតាង (មាត្រា ១១៩ នៃចសព)

១- នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ឬក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធ ឬកំណត់ពន្ធឡើងវិញលើអ្នកជាប់ពន្ធ ដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ដែល

រដ្ឋបាលសារពើពន្ធមាន ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

២- នៅពេលណាដែលប្រាក់ចំណូលជាប់ពន្ធ ឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធ មានភាពខុសគ្នាច្រើន ធៀបទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានា ដែលធ្វើឱ្យឃើញចំណាយស្តុកស្តម្ភរបស់អ្នកជាប់ពន្ធលេចធ្លោឡើង នោះ រដ្ឋបាលសាពើពន្ធមានសិទ្ធិកំណត់ពន្ធឬកំណត់ពន្ធឡើងវិញ ដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មាន សមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្មឬវត្ថុនានាដែលលេចធ្លោនោះ ។ បន្ទុកភស្តុតាង ដើម្បីបញ្ជាក់ថាប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មានលក្ខណៈមិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

## ផ្នែកទី ២.៧ : គោលការណ៍រួមស្តីពីសំវិធានធន

១- ស្របតាមមាត្រា ៦ នៃចសព ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់ ។ ដូច្នេះ ក្រៅតែពីធនាគារ និងស្ថាប័នសញ្ញ័យធនក្នុងស្រុក សហគ្រាសនានាមិនត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសំរាប់រ៉ាប់រងបន្ទុកចំណាយ ឬការខាតបង់នានាដែលមិនទាន់កើតមានឡើងជាក់ស្តែងនោះទេ ទោះបីលទ្ធភាពនៃការកើតមានបន្ទុកចំណាយ ឬការខាតបង់ទាំងនេះមានកំរិតខ្ពស់ ឬជាក់លាក់យ៉ាងណាក៏ដោយ ។

២- ចំពោះធនាគារនិងស្ថាប័នសញ្ញ័យធនក្នុងស្រុក សហគ្រាសទាំងនេះត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសំរាប់ឥណទេយ្យជាប់សង្ស័យ ដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។

# ជំពូកទី៣

## វិធានទូទៅស្តីពីស្តុក និងការងារកំពុងដំណើរការ

## ផ្នែកទី៣.១ : និយមន័យ

១- ស្តុកកើតចេញពីទ្រព្យសកម្មទាំងអស់ជាកម្មសិទ្ធិរបស់សហគ្រាស គឺទ្រព្យសកម្មដែលចូលរួមក្នុងជុំអាជីវកម្មនៃសហគ្រាស ដើម្បី :

   ក- ឬមួយលក់ក្នុងសភាពដើម ឬលក់ក្រោយការកែច្នៃ ឬក្រោយការផលិត

   ខ- ឬមួយប្រើប្រាស់អស់ក្នុងដំណាក់កាលប្រើប្រាស់ដំបូង ។

២- ស្តុករួមមាន :

   - ទំនិញនានា សំភារៈផ្គត់ផ្គង់ (វត្ថុធាតុដើម វត្ថុធាតុ និងសំភារៈប្រើប្រាស់ សំភារៈវេចខ្ចប់...) ផលិតផល (ផលិតផលពាក់កណ្តាលសំរេច ផលិតផលសំរេច កាកសំណល់ ឬវត្ថុធាតុសំរាប់យកទៅកែច្នៃឡើងវិញ)

   - ការងារកំពុងដំណើរការ : នេះគឺជាទ្រព្យសកម្ម ឬសេវា ដែលកំពុងកកើតឡើងនៅក្នុងដំណើរការផលិតកម្ម ។

៣- ត្រូវចាត់ទុកជាស្តុកបាននូវរាល់ផលិតផលដែលជាកម្មសិទ្ធិរបស់សហគ្រាស ទោះបីទ្រព្យសកម្មទាំងនោះស្ថិតនៅក្នុង ឬស្ថិតនៅក្រៅទីតាំងផ្ទាល់របស់សហគ្រាសក៏ដោយ ។

៤- នៅពេលធ្វើសារពើភ័ណ្ឌផលិតផល និងទំនិញដែលសហគ្រាសមិនទាន់បានទទួល ប៉ុន្តែដែលគេអាចចាត់ទុកដោយប្រាកដប្រជាថាជាកម្មសិទ្ធិរបស់សហគ្រាសហើយនោះ ត្រូវតែឆ្លុះបញ្ចាំងក្នុងស្តុក និងត្រូវតែកត់ត្រាចូលតារាងតុល្យការនៃការិយបរិច្ឆេទ ។

៥- ទំនិញ វត្ថុធាតុ ឬផលិតផលដែលស្តុកទុកនៅក្នុងឃ្លាំងឆ្ងាយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ឬដែលបានប្រគល់ឱ្យអ្នកក្រៅឱ្យគេថែទាំឱ្យ ឬជាបញ្ញើ ឬជាការដាក់ធានា ឬជាការឱ្យខ្ចី ត្រូវតែបានឆ្លុះបញ្ចាំងក្នុងទ្រព្យសកម្មនៃសហគ្រាសដែលនៅតែជាម្ចាស់កម្មសិទ្ធិ ។

៦- ជារួម ត្រូវបានចាត់ទុកថាជាស្តុកនូវផលិតផលដែលបំពេញល័ក្ខខ័ណ្ឌទាំងពីរដូចខាងក្រោម :

ក- ផលិតផលជាកម្មសិទ្ធិរបស់សហគ្រាសនាថ្ងៃធ្វើសារពើភ័ណ្ឌ (ទោះស្ថិតក្នុងឃ្លាំងរបស់សហគ្រាស ឬផ្ញើទុកនៅក្នុងឃ្លាំងរបស់អ្នកដទៃក្តី)

ខ- ផលិតផលមានគោលដៅ ឬមួយទុកសំរាប់ផលិត ឬមួយទុកសំរាប់លក់ទៅវិញក្នុងសភាពដើមឬបន្ទាប់ពីកែច្នៃរួច (គឺចំណែកចល័តក្នុងទ្រព្យសកម្មសហគ្រាសដែលមិនអាចធ្វើអចលកម្មបាន) ។

៧- ការងារកំពុងដំណើរការ គឺជាការងារកំពុងប្រព្រឹត្តទៅនាពេលបញ្ចប់ការិយបរិច្ឆេទ ។ ការងារកំពុងដំណើរការច្រើនកើតមាននៅក្នុងសហគ្រាសសំណង់ សហគ្រាសសាធារណៈការ និងបណ្តាសហគ្រាសដែលអនុវត្តការងារដោយឧបករណ៍ធុនធ្ងន់ និងដែលប្រើរយៈពេលវែងក្នុងការផលិត ។

៨- សហគ្រាសមិនត្រូវឆ្លុះបញ្ចាំងក្នុងស្តុកទេ នូវ :

ក- ទ្រព្យសកម្មបានលក់ តែមិនទាន់ប្រគល់

ខ- ទ្រព្យសកម្មបានប្រគល់ តែមិនទាន់ធ្វើវិក្កយបត្រ ។

៩- ចំពោះគណនីស្តុក និងគណនីផលិតផលកំពុងផលិត គេអាចបែងចែកជា :

ក- គណនីវត្ថុធាតុដើម និងសំភារៈផ្គត់ផ្គង់ : គណនីនេះកត់ត្រានូវវត្ថុ និងវត្ថុធាតុបានកែច្នៃច្រើនឬតិចដែលសំរាប់បញ្ចូលក្នុងធាតុផ្សំនៃផលិតផលកំពុងកែច្នៃឬផលិត ។

ខ- គណនីផ្គត់ផ្គង់ផ្សេងៗ : គណនីនេះកត់ត្រានូវវត្ថុ និងវត្ថុធាតុបានកែច្នៃច្រើនឬតិច ដែលប្រើប្រាស់អស់នៅពេលប្រើដំបូង ឬប្រើប្រាស់អស់ដោយឆាប់រហ័ស ដែលចូលរួមក្នុងការកែច្នៃឬក្នុងផលិតកម្មដោយមិនចូលក្នុងធាតុផ្សំនៃផលិតផលកែច្នៃឬផលិត ឬដែលត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មជាសំបកវេចខ្ចប់ ។ ក្នុងនេះគឺមាន :

ខ១- វត្ថុធាតុប្រើប្រាស់

ខ២- សំភារៈផ្គត់ផ្គង់ប្រើប្រាស់

- គ្រឿងឆេះ
- សំភារៈថែទាំ
- សំភារៈផ្គត់ផ្គង់រោងជាង និងរោងចក្រ
- សំភារៈផ្គត់ផ្គង់ឃ្លាំង
- សំភារៈផ្គត់ផ្គង់ការិយាល័យ

ខ៣- សំបកវេចខ្ចប់

- សំបកវេចខ្ចប់មិនប្រមូលវិញ
- សំបកវេចខ្ចប់ប្រមូលវិញដែលមិនអាចកត់ភិនភាគបាន ។

គ- គណនីកំពុងផលិតទ្រព្យសកម្ម: គណនីនេះកត់ត្រាផលិតផលកំពុងផលិត និងការងារកំពុងដំណើរការ ។

ឃ- គណនីកំពុងផលិតសេវា : គណនីនេះកត់ត្រាការសិក្សាស្រាវជ្រាវ និងការផ្គត់ផ្គង់សេវា ដែលមិនទាន់ចប់ និងដែលអនុវត្តតាមកិច្ចសន្យាមួយដែលមិនបានគ្រោងទុកនូវការផ្ទេរកម្មសិទ្ធិជាបណ្តើរៗ ឬកត់ត្រាការ

សិក្សាស្រាវជ្រាវនិងការផ្គត់ផ្គត់ផ្គង់សេវាដែលបានចប់ហើយ តែកិច្ចសន្យាបានចែងថាទាល់តែមានការយល់ព្រមរបស់អតិថិជនលើតំលៃ ទើបការងារនេះក្លាយជាឥណទេយ្យបាន ។

ង- ស្តុកផលិតផល ក្នុងនេះមាន :

ង១- ផលិតផលពាក់កណ្តាលសំរេច គឺផលិតផលដែលបានដល់ដំណាក់ការបង្ហើយណាមួយ ប៉ុន្តែត្រូវទុកសំរាប់បញ្ចូលក្នុងដំណាក់ថ្មីមួយទៀតនៃជុំផលិតកម្ម

ង២- ផលិតផលសំរេច : គឺផលិតផលដែលបានដល់ដំណាក់ការបង្ហើយជាស្ថាពរក្នុងជុំផលិតកម្ម

ង៣- ផលិតផលកាកសំណល់(ឬវត្ថុធាតុប្រមូលបាន) : គឺជាកាកសំណល់ពីផលិតកម្ម ដែលតាមធម្មតាគេទុកសំរាប់លក់ (ឧទាហរណ៍ កំទេចក្រណាត់ កំទេចឈើ កំទេចលោហធាតុ កំទេចក្រដាស...) ឬជាវត្ថុធាតុប្រមូលបាន ដូចជាបំណែក និងវត្ថុធាតុផ្សេងៗដែលប្រមូលបាននៅពេលដែលអចលកម្មណាមួយត្រូវគេឈប់ប្រើប្រាស់ ឬត្រូវគេរុះរើ ដោះបំបែក ។ វត្ថុធាតុទាំងនេះ គេទុកសំរាប់ប្រើប្រាស់ក្នុងជុំអាជីវកម្ម ឬទុកសំរាប់លក់ដោយ មិនកែច្នៃ ។

ច- ស្តុកទំនិញ : គឺជាវត្ថុ និងផលិតផល ដែលសហគ្រាសទិញដើម្បីលក់ទៅវិញដោយមិនបាច់កែច្នៃ ។ ការកែច្នៃដែលធ្វើលើទំនិញ ហើយដែលបង្កើនបរិយាទានផលិតកម្មរបស់ទំនិញទាំងនោះ គឺបានផ្លាស់ទ្រង់ទ្រាយទំនិញទាំងនោះជាផលិតផលសំរេច ។

ឆ- ស្តុកកំពុងធ្វើដំណើរតាមផ្លូវ : គណនីនេះកត់ត្រា :

ឆ១- វត្ថុធាតុ សំភារៈផ្គត់ផ្គង់ និងទំនិញ មិនទាន់បានទទួលបញ្ចូលឃ្លាំង ប៉ុន្តែបានក្លាយជាកម្មសិទ្ធិរបស់សហគ្រាសហើយ

ឆ២- ផលិតផលនិងទំនិញ បញ្ចេញពីឃ្លាំងកំពុងប្រគល់ឱ្យអតិថិជន ប៉ុន្តែនៅជាកម្មសិទ្ធិរបស់សហគ្រាសនៅឡើយ

ឆ៣- វត្ថុធាតុ សំភារៈផ្គត់ផ្គង់ ផលិតផល និងទំនិញ ទុកនៅកន្លែងលក់ដែលស្ថិតនៅក្រៅទីស្នាក់ការ ឬផ្ញើទុកនៅតតិយជន ។

## ផ្នែកទី ៣.២ : ការវាយតំលៃស្តុក

១- ការវាយតំលៃតាមបរិយាទានលទ្ធកម្ម : គឺការវាយតំលៃតាមបរិយាទានទិញពិតដែលផ្សំឡើងដោយ :

ក- ថ្លៃទិញតាមវិក្កយបត្រ ។ ការចុះថ្លៃ ការបន្ថយថ្លៃ ឬការបង្វិលតំលៃដែលពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់បានយល់ព្រមផ្តល់ឱ្យ ត្រូវកាត់ចេញពីថ្លៃទិញ ។

ខ- បន្ទុកបន្ទាប់បន្សំពាក់ព័ន្ធពិតប្រាកដដល់ការទិញនិងការផ្គត់ផ្គង់ ដូចជាការដឹកជញ្ជូន សោហ៊ុយឆ្លងកាត់ ប្រាក់កំរៃនិងកំរៃជើងសារ ការដាក់ទំនិញចុះ ការលើកដាក់លីសែង ពន្ធគយនិងពន្ធអាករផ្សេងទៀត លើកលែងតែពន្ធអាករដែលអាចទាមទារវិញបាន ជាអាទិ៍ អតប ។ ចំណាយទូទៅនៃការផ្គត់ផ្គង់ និងចំណាយក្នុងការស្តុក មិនត្រូវគិតបញ្ចូលក្នុងបរិយាទានលទ្ធកម្មទេ ។ ការខាតនិងការខ្វះខ្វាយជាយថាហេតុ ព្រមទាំងបន្ទុកហិរញ្ញវត្ថុផង ក៏មិនត្រូវគិតបញ្ចូលក្នុងបរិយាទាននេះដែរ ។

២- ការវាយតំលៃតាមបរិយាទានផលិតកម្ម : បរិយាទានផលិតកម្មត្រូវផ្សំឡើងដោយ :

ក- បរិយាទានលទ្ធកម្មនៃវត្ថុធាតុ និងសំភារៈផ្គត់ផ្គង់ ដែលបានប្រើប្រាស់សំរាប់ផលិតកម្ម ។

ខ- បន្ទុកផ្ទាល់ដែលបានចំណាយ ដើម្បីនាំផលិតផលទៅដល់កន្លែង និងក្នុងសភាពដែលផលិតផលនោះស្ថិតនៅ ។ សហគ្រាសអាចបូកបញ្ចូលនូវបន្ទុកប្រយោលក្នុងលក្ខណៈដែលបន្ទុកនោះអាចបញ្ចូលយ៉ាងស្រួល និងយ៉ាងសមហេតុផលទៅក្នុងបរិយាទានផលិតកម្មនៃស្តុក ។

គ- ជាទូទៅមិនត្រូវគិតបញ្ចូលក្នុងបរិយាទានផលិតកម្មទេនូវ សោហ៊ុយរដ្ឋបាលទូទៅ សោហ៊ុយស្តុកផលិតផល សោហ៊ុយស្រាវជ្រាវនិងអភិវឌ្ឍន៍ និងបន្ទុកហិរញ្ញវត្ថុ ។

៣- ការកំណត់បរិយាទានបញ្ចេញនៃស្តុក :

ក- ចំពោះអីវ៉ាន់ របស់របរ ឬក្រុមវត្ថុ ដែលដាច់ដោយឡែកពីគ្នា និងដែលអាចសំគាល់មួយៗបាន បរិយាទាននៃស្តុកត្រូវកំណត់តាមបរិយាទានបញ្ចូលស្តុកសំរាប់អីវ៉ាន់ របស់របរ ឬក្រុមវត្ថុនីមួយៗនោះ ។

ខ- ចំពោះអីវ៉ាន់ឬវត្ថុដែលដោះដូរគ្នាបាន និងដែលមិនអាចសំគាល់ចេញពីគ្នាមួយៗបាន ត្រូវបានអនុញ្ញាតឱ្យប្រើវិធីពីរយ៉ាងដូចខាងក្រោមនេះ សំរាប់កំណត់បរិយាទាននៃស្តុក :

ខ១- បរិយាទានមធ្យមភាគសមតា ដែលមានពីររបៀប :

- បរិយាទានមធ្យមភាគសមតាប្រចាំខែ : ក្នុងនេះ បរិយាទានឯកតានៃស្តុកក្នុងខែណាមួយ ត្រូវស្មើនឹងផលបូកនៃបរិយាទាននៃស្តុកដើមខែ និងបរិយាទានចូលនៃការទិញ ឬផលិតកម្មទាំងអស់នៅក្នុងខែនោះ យកទៅចែកនឹងផលបូកនៃបរិមាណស្តុកដើមខែ និងបរិមាណនៃការទិញ ឬការផលិតទាំងអស់នៅក្នុងខែនោះ ។ បរិយាទានឯកតាដែលបានគណនាឃើញនេះ ត្រូវយកទៅប្រើប្រាស់សំរាប់វាយតម្លៃទំនិញចេញទាំងអស់នៅក្នុងខែនោះ ។
- បរិយាទានមធ្យមភាគសមតាក្រោយពេលបញ្ចូលម្តងៗ : បរិយាទានឯកតានៃការបញ្ចេញស្តុកដែលបានធ្វើឡើងក្រោយការបញ្ចូលស្តុកណាមួយ ត្រូវស្មើនឹងផលបូកនៃបរិយាទានស្តុកដែលនៅសល់មុនការបញ្ចូលនោះ និងបរិយាទាននៃការបញ្ចូលនោះយកទៅចែកនឹង ផលបូកនៃបរិមាណស្តុកដែលនៅសល់មុនការបញ្ចូលនោះនិងបរិមាណនៃការបញ្ចូលនោះ ។ បរិយាទានឯកតាដែលបានគណនាឃើញនេះ ត្រូវយកទៅប្រើប្រាស់សំរាប់វាយតម្លៃទំនិញចេញរហូតដល់មានការបញ្ចូលទំនិញថ្មីទៀត ។

ខ២- វិធីចូលមុនចេញមុន (FIFO) : ក្នុងវិធីនេះមានការកំណត់ថាទ្រព្យដែលចូលស្តុកមុន ត្រូវបញ្ចេញមុន ។ ដូច្នេះស្តុកចុងក្រោយ ត្រូវវាយតំលៃតាមបរិយាទានចូលនៃទ្រព្យដែលចូលក្រោយគេបំផុត ។ ក្នុងវិធីនេះ ទ្រព្យក្នុងស្តុកត្រូវបានប្រមូលផ្តុំជាចង្កោមៗ ទៅតាមពេលបញ្ចូលស្តុក និងតាមតំលៃ ។

## ផ្នែកទី ៣.៣ : ការវាយតំលៃការងារកំពុងដំណើរការ

១- ការងារកំពុងដំណើរការ ត្រូវវាយតំលៃតាមបរិយាទានផលិតកម្មដែលផ្សំឡើងជាអាទិ៍ដោយ :

- បរិយាទាននៃសំភារៈនានាដែលបានប្រើប្រាស់
- បរិយាទាននៃសំភារៈដែលមិនទាន់បានយកប្រើនៅឡើយ ប៉ុន្តែបានផ្គត់ផ្គង់ដល់ការដ្ឋានហើយ
- ចំណាយពលកម្ម
- សោហ៊ុយការដ្ឋាន

- មួយភាគនៃសោហ៊ុយទូទៅនៃទីស្នាក់ការ និងមួយភាគនៃរំលស់ ដែលជាទូទៅច្រើនតែវាយតម្លៃតាមរបៀបម៉ៅការ ។ សហគ្រាសមិនអាចយកមកគិតបញ្ចូលបានទេនូវសោហ៊ុយសុទ្ធសាធខាងពាណិជ្ជកម្មនិងខាងរដ្ឋបាល ព្រមទាំងសោហ៊ុយហិរញ្ញវត្ថុ ។

## ជំពូកទី៤

## វិធានទូទៅស្តីពីផលនៃអាជីវកម្ម

### ផ្នែកទី ៤.១ : គោលការណ៍

១- សហគ្រាសជាប់ពន្ធតាមរបបពិត ត្រូវអនុវត្តតាមគោលការណ៍គណនេយ្យទូទៅ ។ សំរាប់គោលដៅនៃពបច ចំណូលត្រូវតែកត់បញ្ចូលនៅក្នុងការិយបរិច្ឆេទដែលខ្ទង់ចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី (ជាឥណទេយ្យមួយដែលទទួលបាន និងអាចទារបានដោយសហគ្រាស) ។

២- ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា សហគ្រាសត្រូវកត់ត្រាចំណូលនៅពេលផ្គត់ផ្គង់ ។

ក- ពេលផ្គត់ផ្គង់ទំនិញឬសេវា គឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ។

ខ- ក្នុងករណីទំនិញឬសេវាត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង ឬជាពេលដែលសេវាត្រូវបានបំពេញរួចរាល់ ។

គ- ក្នុងករណីទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ឱ្យត្រូវបានបំពេញរួចរាល់ ។

ឃ- ចំពោះទំនិញផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួលដោយមានល័ក្ខខ័ណ្ឌទិញផ្តាច់ឬភតិសន្យាហិរញ្ញវត្ថុពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ។

ង- ក្នុងករណីដែលទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល ឬទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យា ឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬសេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត ទំនិញឬសេវានោះត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ ចំពោះចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យា ឬរយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ គឺជាកាលបរិច្ឆេទមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់ ។

ច- សំរាប់សេវាខាងហិរញ្ញវត្ថុ ពេលផ្គត់ផ្គង់ គឺកាលបរិច្ឆេទដែលអ្នកផ្គត់ផ្គង់សេវាត្រូវបានទទួលការប្រាក់ ប្រាក់កំរៃឬកំរៃជើងសារ ដូចមានចែងនៅក្នុងកិច្ចសន្យាផ្គត់ផ្គង់សេវាខាងហិរញ្ញវត្ថុ ឬកាលបរិច្ឆេទនៃការបង់ការប្រាក់ ប្រាក់កំរៃឬកំរៃជើងសារ ប្រសិនបើការបង់ប្រាក់ត្រូវបានធ្វើឡើងមុនកាលបរិច្ឆេទដែលអ្នកផ្គត់ផ្គង់សេវាត្រូវបានទទួលប្រាក់ ។

### ផ្នែកទី៤.២ : លក្ខណៈប្រាកដប្រជានៃភាពអាចទារបាននូវឥណទេយ្យ

១- ការលក់ : ចំពោះសហគ្រាសអ្នកលក់ទំនិញ ភាពអាចទារបានកើតឡើងក្នុងពេលនៃការផ្ទេរកម្មសិទ្ធិដែលក្នុងករណីទូទៅត្រូវកើតឡើងនៅពេលប្រគល់ទ្រព្យសកម្ម ។

ក- ការលក់ក្រោមល័ក្ខខ័ណ្ឌសំរាប់ព្យួរកិច្ចសន្យា : ក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិត្រូវចំណុះទៅនឹងការធ្វើឱ្យសំរេចនូវព្រឹត្តិការណ៍អ្វីមួយក្នុងអនាគត ។ បើព្រឹត្តិការណ៍នោះមិនសំរេច កិច្ចសន្យាក៏គ្មានផលអ្វីឡើយ ។ តែថាបើវាសំរេចវិញនោះ ការលក់ក៏សំរេចបានផលដែរ គឺបានសេចក្តីថាមានការផ្ទេរកម្មសិទ្ធិ ហើយការផ្ទេរកម្មសិទ្ធិនេះត្រូវកើតឡើងនៅក្នុងថ្ងៃដែលព្រឹត្តិការណ៍នោះបានកើតឡើង ។ ដូច្នេះការសំរេចបាននូវល័ក្ខខ័ណ្ឌធ្វើឱ្យខ្ទង់ចំណូលមានភាពអាចទារបាន ។

ខ- ការលក់ក្រោមល័ក្ខខ័ណ្ឌសំរាប់រំលាយកិច្ចសន្យា : ក្នុងករណីនេះ ការផ្ទេរកម្មសិទ្ធិត្រូវបានធ្វើឡើងភ្លាមៗ ដូចគ្នានឹងការលក់ត្រង់ៗតាមកិច្ចសន្យាសាមញ្ញដែរ។ ប៉ុន្តែវាត្រូវលុបចោលវិញ ប្រសិនបើល័ក្ខខ័ណ្ឌដែលបានគ្រោងទុកក្នុងកិច្ចសន្យាក្លាយទៅជាពិត ។ ដូច្នេះប្រាក់ចំណូលត្រូវកត់ត្រាក្នុងការិយបរិច្ឆេទដែលមានការផ្ទេរកម្មសិទ្ធិ ។ បើសិនក្រោយមក ល័ក្ខខ័ណ្ឌសំរាប់រំលាយកិច្ចសន្យាក្លាយទៅជាពិត ការលុបចោលនូវការលក់ត្រូវកត់ត្រាក្នុងការិយបរិច្ឆេទដែលល័ក្ខខ័ណ្ឌបានក្លាយទៅជាពិត ។

គ- ប្រាក់កាត់ទុកដើម្បីធានា : ចំពោះប្រាក់ដែលអ្នកទិញបានកាត់ទុកជាបណ្តោះអាសន្នដើម្បីធានាលើគុណភាពការងារដែលបានផ្គត់ផ្គង់ សហគ្រាសអ្នកផ្គត់ផ្គង់ត្រូវគិតបញ្ចូលក្នុងលទ្ធផលនៃការិយបរិច្ឆេទចរន្តនាពេលប្រគល់ទទួលការងារ ឬនាពេលដាក់ការងារឱ្យនៅក្រោមការទទួលខុសត្រូវរបស់ម្ចាស់កម្មសិទ្ធិនៃការងារនោះ ។

ឃ- ប្រាក់កក់ : ប្រាក់កក់ដែលអ្នកទិញបានបង់ជាមុននាពេលបញ្ជាទិញទំនិញឬសេវា គឺជាចំណែកមួយនៃថ្លៃទិញទំនិញឬសេវា ហើយសហគ្រាសអ្នកផ្គត់ផ្គង់ត្រូវកត់ត្រាប្រាក់កក់នេះជាចំណូលនាថ្ងៃទទួលប្រាក់ ។

## ផ្នែកទី ៤.៣ : ចំណូលបន្ទាប់បន្សំ

១- ចំណូលបន្ទាប់បន្សំ គឺជាចំណូលទាំងឡាយដែលមិនផ្សារភ្ជាប់ទៅនឹងសកម្មភាពជាគោលដើមរបស់សហគ្រាស និងដែលត្រូវគិតបញ្ចូលផងដែរក្នុងលទ្ធផលរបស់សហគ្រាស ។ ចំណូលបន្ទាប់បន្សំមានជាអាទិ៍ :

ក- ចំណូលពីអចលនទ្រព្យ

ខ- ចំណូលពីមូលប័ត្រ និងភាគហ៊ុន

គ- ចំណូលពីឥណទេយ្យ ប្រាក់ធានា គណនីសន្សំ គណនីចរន្ត ...

ឃ- សួយសារ

ង- អំណោយ និងឧបត្ថម្ភកធន

## ផ្នែកទី ៤.៤ : ចំណូលពីអចលនទ្រព្យកត់ត្រាក្នុងតារាងតុល្យការ

១- អចលនទ្រព្យចូលរួមក្នុងអាជីវកម្ម : ចំណូលពីអចលនទ្រព្យប្រភេទនេះ ត្រូវគិតបញ្ចូលក្នុងលទ្ធផលរបស់សហគ្រាស ។

២- អចលនទ្រព្យមិនចូលរួមក្នុងអាជីវកម្ម : មានតែសហគ្រាសនីតិបុគ្គលទេដែលអាចមានអចលនទ្រព្យប្រភេទនេះ ។ ចំណូលពីទ្រព្យសកម្មនេះគឺជាចំណូលបន្ទាប់បន្សំមួយក្នុងប្រភេទផលផ្សេងៗពីការគ្រប់គ្រងធម្មតា ។

ក- អចលនទ្រព្យជួលឱ្យគេ : ចំណូលបានមកពីការជួលអចលនទ្រព្យដែលបានកត់ត្រានៅខាងទ្រព្យសកម្មនៃតារាងតុល្យការ ត្រូវជាប់ ពបច ដូចគ្នានឹងផលទាំងឡាយដែលបានមកពីអាជីវកម្មជាគោលដើមរបស់សហគ្រាស ។

ខ- អចលនទ្រព្យដាក់ឱ្យនិយោជិតប្រើប្រាស់ដោយឥតគិតថ្លៃ : ក្នុងនេះត្រូវបានកំណត់ថា សហគ្រាសបានទទួលនូវចំណូលជាប់ ពបច មួយស្មើនឹងថ្លៃឈ្នួលតាមទីផ្សារនៃអចលនទ្រព្យ រីឯនិយោជិតអ្នកប្រើ

ប្រាស់អចលនទ្រព្យ គឺបានទទួលនូវអត្ថប្រយោជន៍បន្ថែមមួយស្មើនឹងថ្លៃឈ្នួលទីផ្សារនៃអចលនទ្រព្យ ហើយនិយោជិតត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមចំពោះការប្រើប្រាស់នេះ ។

គ- អចលនទ្រព្យដែលដាក់ឱ្យតតិយជនប្រើប្រាស់ដោយឥតគិតថ្លៃ : សហគ្រាសត្រូវចាត់ទុកថាបានទទួលចំណូលមួយ និងបានធ្វើចំណាយមិនអាចកាត់កងបានមួយដែលមានទឹកប្រាក់ស្មើនឹងថ្លៃឈ្នួលតាមទីផ្សារនៃអចលនទ្រព្យ ។

ឃ- ការកែលំអអចលនទ្រព្យធ្វើដោយអ្នកជួល : កាលបើអ្នកជួលធ្វើឱ្យល្អប្រសើរដោយសោហ៊ុយផ្ទាល់ខ្លួននូវអចលនទ្រព្យដែលជួល និងដោយមិនបានគិតថ្លៃពីសហគ្រាសវិញទេ ការកើនឡើងនៃតំលៃអចលនទ្រព្យដែលបណ្តាលមកពីការធ្វើឱ្យល្អប្រសើរនេះ គឺជាប្រាក់ចំណូលដែលត្រូវគិតបញ្ចូលទៅក្នុងលទ្ធផលនៃឆ្នាំជាប់ពន្ធដែលជាឆ្នាំដែលសហគ្រាសបានយកអចលនទ្រព្យរបស់ខ្លួនមកវិញ ។

## ផ្នែកទី ៤.៥ : ចំណូលភាគលាភ

១- បទប្បញ្ញត្តិស្តីពីចំណូលភាគលាភ មានចែងនៅក្នុងកថាខ័ណ្ឌ ៨ នៃផ្នែកទី ១០.២ នៃប្រកាសនេះ ។

## ផ្នែកទី ៤.៦ : ចំណូលពីឥណទេយ្យ ប្រាក់តំកល់ គណនីសន្សំ ប្រាក់ធានា និងគណនីចរន្ត

១- ចំណូលពីឥណទេយ្យ ប្រាក់តំកល់ គណនីសន្សំ ប្រាក់ធានា និងគណនីចរន្ត គឺជាចំណែកមួយនៃប្រាក់ចំណេញជាប់ពន្ធ ។ ចំណូលទាំងនេះ គឺជាចំណែកមួយនៃចំណូលហិរញ្ញវត្ថុ ។

## ផ្នែកទី ៤.៧ : សួយសារ

១- សួយសារដែលជាចំណូលបានមកពីអាជីវកម្មលើទ្រព្យសកម្មអរូបីផ្សេងៗដូចជាប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិចំលងគំនូរ ប្លង់គំរូ សិទ្ធិអាជីវកម្ម សញ្ញាផលិត វិធីធ្វើ... ត្រូវកត់បញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធ ។

## ផ្នែកទី ៤.៨ : អំណោយ និងឧបត្ថម្ភកធន

១- អំណោយនិងឧបត្ថម្ភកធន ត្រូវគិតបញ្ចូលក្នុងចំណូលជាប់ពន្ធនៃការិយបរិច្ឆេទដែលបានទទួលអំណោយនិងឧបត្ថម្ភកធនទាំងនេះ ។ អំណោយនិងឧបត្ថម្ភកធន មានជាអាទិ៍ :

ក- អំណោយផ្សេងៗ ទោះបានពីប្រភពណាក៏ដោយ

ខ- ឧបត្ថម្ភកធនសំរាប់អាជីវកម្ម ដែលរដ្ឋ សមូហភាពសាធារណៈ តតិយជន... បានផ្តល់ឱ្យ (ឧទាហរណ៍ ប្រាក់ប៉ះប៉ូវសំរាប់បំពេញថ្លៃ ឧបត្ថម្ភកធនសំរាប់សំរាលបន្ទុកអាជីវកម្ម ឧបត្ថម្ភកធនសំរាប់ធានាលំនឹង...) ។

២- វិធានពិសេសនៃឧបត្ថម្ភកធនវិនិយោគ:

ក- ចំពោះឧបត្ថម្ភកធនវិនិយោគដែលសហគ្រាសបានទទួល សហគ្រាសអាចមិនកត់ត្រាវាជាចំណូលជាប់ពន្ធភ្លាមៗបានទេ ។ ក្នុងករណីនេះ សហគ្រាសត្រូវកត់ត្រាឧបត្ថម្ភកធនវិនិយោគមួយចំណែកម្តងៗជាចំណូលជាប់ពន្ធ ។ សំរាប់ឆ្នាំជាប់ពន្ធនីមួយៗ ចំណែកដែលត្រូវកត់ត្រាជាចំណូលជាប់ពន្ធ ត្រូវមានទឹកប្រាក់ស្មើគ្នានឹងរំលស់នៃទ្រព្យសកម្មដែលបានទទួល ឬដែលបានបង្កើតដោយសារឧបត្ថម្ភកធនវិនិយោគក្នុងឆ្នាំជាប់ពន្ធដដែលនោះ ។ ឧទាហរណ៍ : ចំពោះទ្រព្យសកម្មក្នុងថ្នាក់ ១ ដែលមានអត្រារំលស់ស្មើភាគ ៥ ភាគរយ និងដែលត្រូវបានទទួលមកដោយឧបត្ថម្ភកធនក្នុងតំលៃ ១០០ លានរៀល

ចំណែកត្រូវកត់ត្រាជាចំណូលជាប់ពន្ធសំរាប់ឆ្នាំជាប់ពន្ធនីមួយៗ គឺត្រូវស្មើនឹង ៥ លានរៀល (លើកលែងតែសំរាប់ឆ្នាំបញ្ចប់រំលស់) ។

ខ- វិធានសំរាប់កត់ត្រាឧបត្ថម្ភកធនវិនិយោគមួយចំណែកម្តងៗជាចំណូលជាប់ពន្ធ
ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ អាចអនុវត្តបានតែចំពោះទ្រព្យសកម្មក្នុងថ្នាក់១ ដែលមានតំលៃចាប់ពី ២០ លានរៀល ឡើងទៅ ។

គ- សំរាប់គ្រប់ប្រភេទទ្រព្យសកម្មទាំងអស់ដែលស្ថិតនៅក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ ឧបត្ថម្ភកធនវិនិយោគត្រូវបានកត់ត្រាជាចំណូលជាប់ពន្ធទាំងស្រុង ដោយកាត់កងតាមតារាងរំលស់ ដើម្បីកំណត់ចំនួនសមស្របសំរាប់រំលស់ទ្រព្យសកម្មនៅឆ្នាំទីមួយដែលទ្រព្យទាំងនោះត្រូវបានដាក់ប្រើប្រាស់ ។

## ផ្នែកទី ៤.៩ : ចំណូលបន្ទាប់បន្សំផ្សេងៗទៀត

១- ចំណូលបន្ទាប់បន្សំផ្សេងៗទៀត មានជាអាទិ៍ : ចំណូលពីការលក់ផលិតផលកាកសំណល់ ការជួលសំភារៈអាជីវកម្ម ប្រាក់ចំណេញលើសំបកវេចខ្ចប់បានផ្ញើទុក ប្រាក់ចំណេញបានមកពីសកម្មភាពអាជីវកម្មដែលបានធ្វើសំរាប់ជាប្រយោជន៍បុគ្គលិក ...។

## ផ្នែកទី ៤.១០ : ចំណូលផ្សេងៗ

១- ក្រៅពីចំណូលពីអាជីវកម្មជាគោលដើមនិងចំណូលបន្ទាប់បន្សំ នៅក្នុងចំណូលជាប់ពន្ធរបស់សហគ្រាសនៅមានចំណូលផ្សេងៗជាច្រើនទៀតដូចជា :

ក- សំណងធានារ៉ាប់រង : សហគ្រាសអាចបានទទួលសំណងធានារ៉ាប់រងក្រោយពេលមានកើតមហន្តរាយ (អគ្គិភ័យ ចោរកម្ម ការខូចខាតទ្រព្យសកម្មផ្សេងៗ...) ឬនៅក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងជីវិតដែលបានចុះកិច្ចសន្យាសំរាប់ជាប្រយោជន៍ដល់សហគ្រាស ។ ប្រាក់សំណងនេះ ត្រូវកត់ត្រាក្នុងចំណូលជាប់ពន្ធរបស់សហគ្រាស ។ ចំណែកឯការខាតបង់របស់សហគ្រាស និងចំណាយរបស់សហគ្រាសក្នុងការដាក់ឱ្យដំណើរការឡើងវិញនូវទ្រព្យសកម្មដែលខូចខាត គឺត្រូវកត់ត្រាជាចំណាយ ។

ខ- សំណងផ្សេងៗ គឺមានជាអាទិ៍ :

ខ១- សំណងចំពោះការកេណ្ឌប្រមូលយកទៅប្រើប្រាស់នូវមធ្យោបាយផ្សេងៗ ដូចជាកាណូតដែលរដ្ឋបានកេណ្ឌឱ្យទៅដឹកប្រជាជនពេលមានគ្រោះទឹកជំនន់ ...

ខ២- សំណងពីការលុបកិច្ចសន្យា

ខ៣- សំណងផ្តល់ឱ្យជាជំងឺចិត្ត

ខ៤- សំណងការខូចខាតដោយការធ្វើអាជីវកម្មប្រជែងគ្នាមិនស្មោះត្រង់ ។

គ- ការបន្ធូរបន្ថយនូវពន្ធអាករដែលកាលពីមុនបានកាត់ចេញពីប្រាក់ចំណេញជាប់ពន្ធ : ប្រាក់បន្ធូរបន្ថយ នេះគឺជាចំណូលនៃការិយបរិច្ឆេទដែលសហគ្រាសបានទទួលផលប្រយោជន៍នេះ ។

ឃ- ការបន្ថយបំណុល : ការបន្ថយបំណុលដែលអ្នកផ្គត់ផ្គង់ ឬតតិយជនបានយល់ព្រមផ្តល់ឱ្យសហគ្រាស និងដែលបានធ្វើឱ្យមានការកើនឡើងនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស ត្រូវកត់ត្រាជាចំណូលនៃការិយបរិច្ឆេទដែលសហគ្រាសបានទទួលការយល់ព្រមបន្ថយនេះ ( បញ្ជាក់ : ការសងបំណុលមិនបណ្តាលឱ្យមានការកើនឡើង ឬថយចុះនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាសទេ ដូច្នេះពុំមានឥទ្ធិពលអ្វីទៅលើប្រាក់ចំណេញជាប់ពន្ធទេ) ។ ត្រូវអនុវត្តដូចគ្នាដែរ ចំពោះការលុបចោលនូវគណនីនៃទ្រព្យអកម្ម

ដែលគ្មានភស្តុតាងបង្ហាញ និងចំពោះគ្រប់ប្រតិបត្តិការផ្សេងទៀតដែលនាំឱ្យមានការកើនឡើងនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស ។

# ជំពូកទី៥

## វិធាននូទៅស្តីពីចំណាយ

### ផ្នែកទី ៥.១ : ចំណាយអាជីវកម្ម

១- ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កង គឺជាបន្ទុក ឬចំណាយដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ ដែលអ្នកជាប់ពន្ធបានធ្វើឡើងដើម្បីប្រកបអាជីវកម្ម និងដែលគ្មានការបញ្ចូលសំរាប់ជាថ្នូរមកវិញក្នុងទ្រព្យសកម្មនូវទ្រព្យសកម្មណាមួយ ឬដែលគ្មានការលុបបំណុលណាមួយខាងទ្រព្យអកម្ម ។

២- ចំណាយបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ : ចំណាយណាមួយអាចកាត់កងបានតែពីលទ្ធផលនៃការិយបរិច្ឆេទដែលក្នុងអំឡុងពេលនោះ ចំណាយនោះបំពេញបាននូវល័ក្ខខ័ណ្ឌដូចមានចែងក្នុងផ្នែកទី ៥.២ នៃប្រកាសនេះ ។ ដូច្នេះអ្នកជាប់ពន្ធមិនអាចរំកិលកាលបរិច្ឆេទកត់ត្រាចំណាយពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀតបានឡើយ ។ ការិយបរិច្ឆេទនីមួយៗគឺឯករាជ្យពីអ្វីដែលមានពីមុននឹងអ្វីដែលមានជាបន្ទាប់មកទៀត ។ ដើម្បីកំណត់លទ្ធផលនៃការិយបរិច្ឆេទណាមួយ ត្រូវគិតបញ្ចូលតែហេតុការណ៍និងប្រតិបត្តិការទាំងឡាយណាដែលនាំឱ្យលទ្ធផលនោះសំរេចបានតែប៉ុណ្ណោះ ។

- ក- ចំណាយដែលទាក់ទងដល់ការិយបរិច្ឆេទមុនៗ: ចំណាយណាមួយដែលបានកើតឡើង និងបានក្លាយជាបន្ទុកនៃការិយបរិច្ឆេទមុនណាមួយហើយមិនអាចយកមកកាត់កងពីលទ្ធផលនៃការិយបរិច្ឆេទចរន្តបានទេ។
- ខ- ចំណាយមិនបានទូទាត់ពេលបិទការិយបរិច្ឆេទ : ប្រសិនបើចំណាយមួយដែលតាមគោលការណ៍មានចែងនៅក្នុងផ្នែក ៥.១ និងផ្នែក ៥.២ នៃប្រកាសនេះ ត្រូវជាបន្ទុកនៃការិយបរិច្ឆេទត្រូវបិទណាមួយ ប៉ុន្តែនៅពេលបិទបញ្ជីបន្ទុកនេះមិនទាន់បានទូទាត់នៅឡើយ សហគ្រាសត្រូវធ្វើគណនេយ្យកម្មចំណាយនេះក្នុងគណនីបន្ទុកត្រូវសង (ឧទាហរណ៍ ឈ្នួលផ្ទះមិនបានបង់ ពន្ធមិនបានបង់ក្នុងការិយបរិច្ឆេទ...) ។ តែបើមិនបានធ្វើគណនេយ្យកម្មបែបនេះទេ ចំណាយនេះមិនអាចលើកយកទៅកត់ត្រាជាបន្ទុកនៅក្នុងការិយបរិច្ឆេទបន្ទាប់បានឡើយ ។
- គ- ចំណាយនៃការិយបរិច្ឆេទបន្ទាប់ : សំរាប់គោលដៅនៃពបច មិនត្រូវបានអនុញ្ញាតទេនូវការកត់បញ្ចូលទៅក្នុងការិយបរិច្ឆេទមួយនូវចំណាយដែលទាក់ទងនឹងការិយបរិច្ឆេទបន្ទាប់ៗ ។
- ឃ- ចំណាយទាំងឡាយដែលបានទូទាត់ជាមុន ត្រូវកាត់ចេញតែពីលទ្ធផលនៃការិយបរិច្ឆេទណាដែលត្រូវរ៉ាប់រងចំណាយទាំងនេះតែប៉ុណ្ណោះ ។

៣- ចំណាយដើម្បីប្រកបអាជីវកម្ម : ត្រូវបានអនុញ្ញាតឱ្យកាត់កងបានតែចំណាយណាដែលបានធ្វើដើម្បីបំរើអាជីវកម្ម ឬដើម្បីជាប្រយោជន៍នៃអាជីវកម្ម ។ ដូច្នេះចំណាយណាដែលមិនផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងធម្មតា ឬដែលផ្តល់ប្រយោជន៍ដល់តតិយជន គឺមិនអាចកាត់កងបានទេ ។ ចំណាយដែលមិនមែនជាចំណាយដើម្បីប្រកបអាជីវកម្ម មានជាអាទិ៍ :

- ក- ចំណាយបំរើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសឯកបុគ្គល ( ឧទាហរណ៍ ចំណាយលំនៅដ្ឋានពន្ធផ្ទាល់ខ្លួន ចំណាយលើយានជំនិះប្រើប្រាស់ជាឯកជន...)

ខ- ចំណាយលេចធ្លោ ឬស្តុកស្តម្ភហួសហេតុ ដែលគ្មានប្រយោជន៍ ឬមានប្រយោជន៍តិចតួចពេកដល់អាជីវកម្ម ។ ពាក្យ "ចំណាយស្តុកស្តម្ភហួសហេតុ" សំដៅដល់ចំណាយលើសពីតម្រូវការ ឬខ្ជះខ្ជាយហួសពីភាពសមហេតុសមផល ថ្លៃ ឬតម្លៃខ្ពស់មិនសមហេតុសមផល ឬលេចធ្លោហួសពេក ។

៤- ចំណាយដែលគ្មានការបញ្ចូលសំរាប់ជាថ្នូរមកវិញក្នុងទ្រព្យសកម្មនូវទ្រព្យសកម្មណាមួយឬដែលគ្មានការលុបបំណុលណាមួយខាងអកម្ម : នេះគឺជាចំណាយដែលបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស ។ សំរាប់គោលដៅនៃពបច ចំណាយណាដែលមិនបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធរបស់សហគ្រាស គឺមិនអាចកាត់កងបានទេ ។ ចំណាយមិនបណ្តាលឱ្យមានការថយចុះនូវទ្រព្យសកម្មសុទ្ធ មានជាអាទិ៍ :

ក- បន្ទុកដែលសហគ្រាសខ្លួនឯងផ្ទាល់មិនបានទទួលរង

ខ- ចំណាយដែលមានការបញ្ចូលជាថ្នូរនូវចំណែកថ្មីមួយក្នុងទ្រព្យសកម្ម ឬដែលបណ្តាលឱ្យមានការកើនតំលៃនៃចំណែកណាមួយនៃទ្រព្យសកម្ម

គ- ចំណាយសំរាប់ពន្យារពេលឱ្យបានវែងគួរកត់សំគាល់នូវរយៈពេលប្រើប្រាស់នៃទ្រព្យសកម្មណាមួយ

ឃ- ចំណាយដែលមានថ្នូរ ជាការបំបាត់បំណុលខាងទ្រព្យអកម្ម (ឧទាហរណ៍ ការសងប្រាក់ខ្ចី) ។

## ផ្នែកទី ៥.២ : ចំណាយអាចកាត់កងបាន

១- ចំពោះខ្ទង់ចំណាយណាមួយដែលបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងផ្នែកទី ៥.១ នៃប្រកាសនេះហើយ ដើម្បីអាចយកទៅកាត់កងសំរាប់គោលដៅនៃ ពបច បាន ខ្ទង់ចំណាយនោះត្រូវបំពេញថែមទៀតនូវល័ក្ខខ័ណ្ឌទាំងបីដូចតទៅ :

ក- ហេតុការណ៍ដែលបញ្ជាក់នូវបន្ទុក ឬចំណាយរបស់អ្នកជាប់ពន្ធបានកើតឡើង : គឺបានន័យថាភាពពិតរបស់បន្ទុកឬចំណាយនោះត្រូវបានបញ្ជាក់អះអាងដោយភស្តុតាងដែលអាចត្រួតពិនិត្យបាន ( វិក្កយបត្រ ប្រតិវេទន៍គយ លិខិតឆ្លើយឆ្លងពាណិជ្ជកម្ម កិច្ចសន្យាខ្ចីប្រាក់ ...) ។

ខ- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង :

ខ១- ក្នុងករណីដែលបន្ទុក ឬចំណាយតម្រូវឱ្យមានការទូទាត់សងចំពោះការផ្គត់ផ្គង់ទ្រព្យសកម្ម ឬសេវា លទ្ធផលសកម្មភាពសេដ្ឋកិច្ចកើតឡើងនៅពេលដែលទ្រព្យសកម្មឬសេវានោះត្រូវបានផ្គត់ផ្គង់

ខ២- ក្នុងករណីដែលបន្ទុកឬចំណាយបានកើតឡើងដោយសារអ្នកជាប់ពន្ធបានប្រើប្រាស់ ឬបានផ្គត់ផ្គង់នូវទ្រព្យសកម្មឬសេវា លទ្ធផលសកម្មភាពសេដ្ឋកិច្ចកើតឡើងនៅពេលដែលអ្នកជាប់ពន្ធបានប្រើប្រាស់នូវទ្រព្យសកម្ម ឬបានផ្គត់ផ្គង់នូវទ្រព្យសកម្មឬសេវានោះ ។

ខ៣- ត្រូវបានចាត់ទុកថាលទ្ធផលនៃសកម្មភាពបានកើតឡើង នៅពេលដែលមានការទូទាត់សងណាមួយដូចខាងក្រោមនេះកើតឡើង :

- ការប៉ះប៉ូវឱ្យកម្មករ សំណងជំងឺចិត្ត ឬសំណងលើការបំពានកិច្ចសន្យា
- ការចុះថ្លៃ ឬការបង្វិលសងវិញ
- ប្រាក់រង្វាន់ផ្សេងៗ
- សំណងលើការទទួលធានា ឬតាមកិច្ចព្រមព្រៀងផ្តល់សេវា
- ប្រាក់ពន្ធនានាក្រៅពីតំណាទានពន្ធបរទេស ពន្ធអប្បបរមា និងពន្ធលើប្រាក់ចំណេញ ។

គ- បន្ទុករបស់អ្នកជាប់ពន្ធត្រូវបានកំណត់ច្បាស់លាស់ : គឺបានន័យថាបន្ទុក ឬចំណាយនោះ :

គ១- ត្រូវបានធ្វើគណនេយ្យកម្មក្នុងអំឡុងនៃការិយបរិច្ឆេទ

គ២- ត្រូវមានភស្តុតាងបញ្ជាក់ត្រឹមត្រូវពីចំនួនទឹកប្រាក់ច្បាស់លាស់នៃបន្ទុកនោះ(វិក្កយបត្រ...) ។

២- បន្ថែមលើលក្ខខណ្ឌទាំងបីខាងលើ :

ក- សំរាប់គោលដៅនៃពបច ដើម្បីអាចកាត់កងបាននូវចំណាយដែលមិនទាន់បានទូទាត់នៅដំណាច់ឆ្នាំសារពើពន្ធ លុះត្រាតែចំណាយនោះគឺជាបំណុលពិតប្រាកដរបស់អ្នកជាប់ពន្ធ ។ ប្រសិនបើទឹកប្រាក់ដែលមិនបានទូទាត់មិនតំណាងឱ្យបំណុលពិតប្រាកដទេនោះ ការកាត់កងមិនត្រូវបានអនុញ្ញាតឡើយ ។ ដើម្បីបញ្ជាក់នូវបំណុលពិតប្រាកដ ត្រូវតែមានការកំហិតទារដោយម្ចាស់បំណុល ជាមួយនឹងការរំពឹងដោយសមស្របថា បំណុលនឹងត្រូវទូទាត់ពិតប្រាកដដោយកូនបំណុល ។

ខ- សំរាប់ប្រាក់បៀវត្សពីការបំរើការងារ សហគ្រាសអាចកាត់កងប្រាក់បៀវត្សដែលមិនទាន់បានបើក ប្រសិនបើប្រាក់បៀវត្សនោះត្រូវបានបើកក្នុងអំឡុងពេល ៦០ ថ្ងៃ នៃឆ្នាំសារពើពន្ធបន្ទាប់ ។ សំរាប់គោលដៅនៃពបច ដើម្បីទប់ស្កាត់នូវការយឺតយ៉ាវក្នុងការបើកប្រាក់បៀវត្សជាប់ពន្ធ វិធានពិសេសមួយត្រូវបានបង្កើតឡើងនៅក្នុងវាក្យខ័ណ្ឌ គ ដើម្បីកំណត់ព្រំដែនឱ្យសហគ្រាសក្នុងការកាត់កងប្រាក់បៀវត្សដែលមិនទាន់បានបើក ។

គ- ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ សហគ្រាសអាចកាត់កងនូវចំណាយដែលមិនទាន់បានទូទាត់នៅដំណាច់ឆ្នាំសារពើពន្ធ វៀរលែងតែ :

គ១- ប្រាក់បៀវត្សពីការបំរើការងារដែលមិនទាន់បានបើក ប៉ុន្តែមិនបានបើកក្នុងអំឡុងពេល ៦០ ថ្ងៃ នៃឆ្នាំសារពើពន្ធបន្ទាប់

គ២- ចំណាយដែលមិនទាន់បានទូទាត់ដទៃទៀតដល់បុគ្គលទាក់ទិន ប៉ុន្តែមិនបានទូទាត់ក្នុងអំឡុងពេល ១៨០ ថ្ងៃ នៃឆ្នាំសារពើពន្ធបន្ទាប់ លើកលែងតែចំណាយដែលអាចកាត់កងបាននៃសារពើភ័ណ្ឌ ទ្រព្យជាមូលធន និងទ្រព្យដែលអាចរំលស់បាន។

គ៣ - ក្នុងករណីដូចក្នុងវាក្យខ័ណ្ឌ គ១ និងវាក្យខ័ណ្ឌ គ២ ខាងលើ ចំណាយដែលបានកាត់កងត្រូវកត់ត្រាបញ្ចូលជាចំណូលជាប់ពន្ធសំរាប់ឆ្នាំសារពើពន្ធនោះវិញ ។ ចំណូលជាប់ពន្ធនេះជាកម្មវត្ថុនៃការកំណត់ពន្ធឡើងវិញ ។

## ផ្នែកទី ៥.៣ : ចំណាយមិនអាចកាត់កងបាន

១- លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ក្រៅពីចំណាយដែលបំពេញលក្ខខ័ណ្ឌដូចមានចែងក្នុងផ្នែកទី ៥.២ នៃប្រកាសនេះ ចំណាយផ្សេងទៀតទាំងអស់ គឺជាចំណាយមិនអាចកាត់កងបាន និងត្រូវបញ្ចូលមកវិញសំរាប់គិតលទ្ធផលសារពើពន្ធ ។

២- ចំពោះរំលស់ ឬសំវិធានធនដែលកត់ត្រាខុសគោលការណ៍ ឬកត់ត្រាលើស សហគ្រាសត្រូវអនុវត្តតាមវិធានដូចមានចែងក្នុងកថាខ័ណ្ឌ ៥ នៃផ្នែកទី ៦.៨ នៃប្រកាសនេះ ។

## ផ្នែកទី ៥.៤ : សោហ៊ុយបង្កើតសហគ្រាស

១- សោហ៊ុយបង្កើតសហគ្រាស គឺជាចំណាយក្នុងឱកាសនៃប្រតិបត្តិការដែលកំណត់ឡើងនូវអត្ថិភាព សកម្មភាព ឬការអភិវឌ្ឍន៍របស់សហគ្រាស ។ ប៉ុន្តែទឹកប្រាក់ចំណាយនេះមិនអាចកត់បញ្ចូលក្នុងផលិតកម្មទ្រព្យសកម្មណាមួយ ឬសេវាណាមួយជាកំណត់ទេ ។ សោហ៊ុយបង្កើតសហគ្រាស (ឬបន្ទុកត្រូវចែករំលែកបញ្ចូលក្នុងច្រើនការិយបរិច្ឆេទ) មានជាអាទិ៍ :

ក- សោហ៊ុយបង្កើតសហគ្រាស និងអភិវឌ្ឍន៍ដំបូង : នេះជាសោហ៊ុយចំណាយនៅពេលដំបូងសំរាប់បង្កើតសហគ្រាស ឬដែលទាក់ទងទៅនឹងសកម្មភាពថ្មី ។ សោហ៊ុយនេះមានជាអាទិ៍ សោហ៊ុយក្នុងការស្រាវជ្រាវលទ្ធភាពបង្កើតសហគ្រាស ការផ្សាយពាណិជ្ជកម្ម ការដឹកនាំ និងការត្រួតពិនិត្យការដ្ឋាន ការបណ្តុះបណ្តាលបុគ្គលិក បុរេហិរញ្ញប្បទាន ជំនួយបច្ចេកទេស... ។

ខ- សោហ៊ុយទាក់ទងនឹងលក្ខន្តិកៈរបស់ក្រុមហ៊ុន : គឺជាសោហ៊ុយចំណាយក្នុងពេលបង្កើតក្រុមហ៊ុន នៅពេលបន្ថែមឬបន្ថយមូលធនរបស់ក្រុមហ៊ុន ឬសោហ៊ុយដែលធ្វើឡើងក្នុងប្រតិបត្តិការប្រហាក់ប្រហែលគ្នាណាមួយ (ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា...) ។ សោហ៊ុយនេះមានជាអាទិ៍ ពន្ធប្រថាប់ត្រាលើលិខិតផ្សេងៗរបស់ក្រុមហ៊ុន (ឧបហារិត ការបង្កើន មូលធន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា...) ប្រាក់សាគុណនៃការបង្កើតក្រុមហ៊ុន ចំណាយចំពោះការធ្វើបែបបទស្របច្បាប់នៃប្រកាសនកិច្ច... ។

គ- សោហ៊ុយនៃការបោះផ្សាយការខ្ចីបុល : គឺជាសោហ៊ុយចំណាយក្នុងឱកាសចុះកិច្ចសន្យាខ្ចីបុល ។

ឃ- សោហ៊ុយក្នុងការទិញអចលកម្ម : ក្នុងនេះ មានតែពន្ធលើការផ្ទេរសិទ្ធិ ឬកម្មសិទ្ធិ ប្រាក់សាគុណកំរៃជើងសារ និងសោហ៊ុយលិខិតស្នាមតាមផ្លូវច្បាប់ប៉ុណ្ណោះ ។ ឯចំណាយផ្សេងទៀត គឺជាចំណែកនៃបរិយាទាននៃអចលកម្ម ឬជាបន្ទុកនៃការិយបរិច្ឆេទដែលមានសោហ៊ុយទាំងនោះ ។

២- ចំណាយដូចតទៅនេះ មិនមែនជាសោហ៊ុយបង្កើតសហគ្រាសទេ :

ក- ចំណាយដែលជាបន្ទុកចាំបាច់មួយនៃការិយបរិច្ឆេទដែលមានចំណាយនោះ (ឧទាហរណ៍ សោហ៊ុយធម្មតានៃការផ្សាយពាណិជ្ជកម្ម)

ខ- សោហ៊ុយឋាបនកម្ម និងការផ្តុំតំលើងដែលត្រូវបានគិតបញ្ចូលក្នុងតំលៃទិញអចលកម្មជាប់ពាក់ព័ន្ធ ។

៣- សោហ៊ុយបង្កើតសហគ្រាស ជាសោហ៊ុយដែលបានចាយនាឱកាសបង្កើតសហគ្រាស ឬជាសោហ៊ុយដែលសហគ្រាសបានចាយនាឱកាសទិញមធ្យោបាយអាជីវកម្មជាអចិន្ត្រៃយ៍របស់ខ្លួន គឺជាចំណាយដែលគ្មានថ្នូរមកវិញនៅក្នុងទ្រព្យសកម្មរបស់សហគ្រាសទេ ។ គណនីទាំងឡាយដែលសោហ៊ុយទាំងនេះត្រូវបានធ្វើគណនេយ្យកម្ម គឺជាគណនីទ្រព្យសកម្មគ្មានតំលៃពិតប្រាកដ ។

៤- សំរាប់គោលដៅនៃពបច សោហ៊ុយបង្កើតសហគ្រាស អាចត្រូវបានកាត់ចេញទាំងស្រុងបានពីលទ្ធផលនៃការិយបរិច្ឆេទដែលសោហ៊ុយទាំងនេះបានកើតឡើង ។ ប៉ុន្តែបើសហគ្រាសធ្វើការកាត់កងតាមការរំលស់វិញ សោហ៊ុយទាំងនេះមិនអាចធ្វើរំលស់ក្នុងរយៈពេលលើសពី ២ ការិយបរិច្ឆេទបានទេ ។

## ផ្នែកទី ៥.៥ : ការទិញ

១- ការទិញអាចបែងចែកជា ៣ ប្រភេទ :

ក- ការទិញដែលអាចស្តុកបាន ដូចជា គ្រឿងផ្គត់ផ្គង់ និងទំនិញ

ខ- ការទិញមិនអាចស្តុកបាន ឬមិនបានស្តុក ដូចជា ទឹក អគ្គិសនី ប្រេងឥន្ធនៈ និងប្រេងរំអិល សំភារៈផ្គត់ផ្គង់តូចតាចសំរាប់ការិយាល័យ ហត្ថបករណ៍តូចតាចដែលត្រូវផ្លាស់ថ្មីញឹកញាប់... (នៅចុងការិយបរិច្ឆេទ ការទិញប្រភេទនេះមិនត្រូវបានធ្វើនិយ័តកម្មដោយគណនីស្តុកទេ ប៉ុន្តែត្រូវធ្វើដោយគណនី "បន្ទុកបានពិនិត្យកត់ត្រាមុន" )

គ- ការទិញការសិក្សា ឬការផ្គត់ផ្គង់សេវា ដែលជាទឹកប្រាក់បានចាយឱ្យអ្នកទទួលម៉ៅការបន្តសំរាប់ការផលិត ការបំប្លែង ការរក្សាផលិតផលទុកឱ្យបានយូរ ឬការផ្គត់ផ្គង់សេវា... ។ អ្នកទទួលម៉ៅការបន្ត អាចជា

អ្នកផលិតយកតែថ្លៃឈ្នួលពលកម្ម (អ្នកទិញជាអ្នកផ្តល់វត្ថុធាតុដើមឱ្យ) អ្នកទទួលម៉ៅការបន្តខាងឧស្សាហកម្ម ឬអ្នកទទួលម៉ៅការបន្តសំរាប់ការផ្គត់ផ្គង់ទំនិញឬសេវា (តាមធម្មតាគឺមានការងារខាងសាធារណៈការ ការងារសាងសង់អគារ...) ។

២- គណនេយ្យកម្មនៃការទិញ : ការទិញត្រូវកត់ត្រាចុះបញ្ជីនាពេលទទួលវិក្កយបត្រ ទៅតាមបរិយាទានពិតនៃការទិញនោះ ។

ក- ចំពោះទ្រព្យសកម្មក្នុងស្រុក បរិយាទានទិញ គឺជាចំណាយពិតប្រាកដរបស់សហគ្រាសសំរាប់ការទិញដែលមានថ្លៃទិញ បូកសោហ៊ុយបន្ទាប់បន្សំដែលជាប់ទាក់ទិនដោយផ្ទាល់នឹងការទិញ ដូចជាសោហ៊ុយដឹកជញ្ជូន ធានារ៉ាប់រង.. និងដកចេញនូវការបញ្ចុះថ្លៃផ្សេងៗដែលអ្នកផ្គត់ផ្គង់បានយល់ព្រមផ្តល់ឱ្យ ។

ខ- ចំពោះទ្រព្យសកម្មនាំចូល បរិយាទានទិញ រួមមានជាអាទិ៍ :

ខ១- ថ្លៃទិញ

ខ២- សោហ៊ុយដឹកជញ្ជូនផ្លូវសមុទ្រ ឬផ្លូវអាកាស

ខ៣- សោហ៊ុយធានារ៉ាប់រង ដែលបានចាយនៅខាងក្រៅដែនដីជាតិ

ខ៤- សោហ៊ុយឆ្លងកាត់ កំរៃជើងសារ និងជើងសារជំនួញដែលត្រូវបង់ឱ្យសហគ្រាសនានា ដែលស្ថិតនៅឯបរទេស(គិតរួមបញ្ចូលទាំងកំរៃជើងសារធនាគារ សោហ៊ុយសំណុំរឿងនិងសោហ៊ុយនៃការទូទាត់)

ខ៥- សោហ៊ុយផ្សេងៗក្រោយការបញ្ចូលទ្រព្យសកម្មមកក្នុងដែនដីជាតិ ដូចជាសោហ៊ុយឆ្លងកាត់ កំរៃជើងសារ និងជើងសារជំនួញ ដែលត្រូវបង់ឱ្យសហគ្រាសដែលស្ថិតនៅក្នុងដែនដីជាតិ សោហ៊ុយដឹកជញ្ជូន និងសោហ៊ុយធានារ៉ាប់រងពីព្រំដែនមកដល់ឃ្លាំង ។

៣- គណនេយ្យកម្មនៃពន្ធគយ : ពន្ធគយ (ពន្ធលើទំនិញនាំចេញ នាំចូល) ត្រូវធ្វើគណនេយ្យកម្មក្នុងគណនីពន្ធគយ និងមិនត្រូវធ្វើគណនេយ្យកម្មនៅក្នុងគណនីទិញសំភារៈនិងសេវាទេ ។

៤- គណនេយ្យកម្មនៃអាករលើតំលៃបន្ថែម (អតប) :

ក- ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់មិនជាប់អតប : ត្រូវអនុវត្តតាមគោលការណ៍ ដូចមានចែងសំរាប់អាករផ្សេងៗនៃកថាខ័ណ្ឌ ៥ នៃផ្នែកនេះ ។

ខ- ចំពោះសហគ្រាសដែលធ្វើការផ្គត់ផ្គង់ជាប់ អតប :

ខ១- ចំពោះ អតប ដែលអាចសុំជាឥណទានបាន ត្រូវកត់ត្រាក្នុងគណនីតតិយជន ។

ខ២- ចំពោះ អតប ដែលមិនអាចសុំជាឥណទានបាន ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងសំរាប់អាករផ្សេងៗនៃកថាខ័ណ្ឌ ៥ នៃផ្នែកនេះ ។

ខ៣- ចំពោះ អតប ដែលបានកត់ត្រាក្នុងគណនីតតិយជន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ខ១ នៃកថាខ័ណ្ឌនេះ ប៉ុន្តែក្រោយមកទៀតក្លាយជាមិនអាចសុំជាឥណទានបាន សហគ្រាសត្រូវកត់ត្រា អតប នេះ ក្នុងគណនីទ្រព្យសកម្មឬគណនីទិញដែលជាប់ទាក់ទិន ។ ប៉ុន្តែប្រសិនបើ អតប នេះមិនអាចកត់បញ្ចូលបានដោយសមហេតុផលទៅក្នុងគណនីទ្រព្យសកម្ម ឬគណនីទិញណាមួយបានទេ សហគ្រាសអាចកត់ត្រា អតប នេះ ជាចំណាយនៃការិយបរិច្ឆេទដែលមានការបដិសេធឥណទាន ។

៥- គណនេយ្យកម្មនៃអាករផ្សេងៗ : ដូចជា អាករលើផលរបរ អាករពិសេស អាករបំភ្លឺសាធារណៈ អាករមិនត្រូវកាត់ចេញពីបរិយាទានទិញទេ ។ ប្រសិនបើអាករទាំងនេះមានឆ្លុះបញ្ចាំងក្នុងវិក្កយបត្រនៃការទិញទ្រព្យសកម្ម

និងសេវា អាករទាំងនេះត្រូវបូកបន្ថែមលើថ្លៃទិញ និងត្រូវធ្វើគណនេយ្យកម្មក្នុងគណនីបន្ទុក (ទិញឬសោហ៊ុយទូទៅ) ឬគណនីទ្រព្យសកម្មដែលទាក់ទិន ។

៦- ការដកយកទំនិញឬសេវាមកប្រើប្រាស់ផ្ទាល់ខ្លួន : ការដកយកទំនិញឬសេវាមកប្រើប្រាស់ផ្ទាល់ខ្លួនដោយម្ចាស់សហគ្រាសឯកបុគ្គល សហគ្រាសត្រូវកត់ត្រាក្នុងគណនីលក់ទំនិញឬសេវា ដោយគិតតាមតំលៃទីផ្សារនៃទំនិញឬសេវា ។

៧- កិច្ចការបញ្ចូលការទិញ និយ័តកម្មការទិញ ស្តុកនិងបំណុលអ្នកផ្គត់ផ្គង់ : ដូចបន្ទុកផ្សេងទៀតដែរ ការទិញត្រូវគិតបញ្ចូលក្នុងការិយបរិច្ឆេទដែលបំណុលរបស់អ្នកទិញបានកើតឡើង ។ ផ្អែកតាមគោលការណ៍នៃការកត់ត្រាការទិញនាថ្ងៃទទួលវិក្កយបត្រ ដូច្នេះនៅថ្ងៃបញ្ចប់ការិយបរិច្ឆេទអាចមានចន្លោះពេលមួយ (គឺការមុនក្រោយគ្នា) រវាងការទទួលវិក្កយបត្រ ការទទួលទំនិញ និងការកត់ត្រាគណនេយ្យ ។ ក្នុងករណីនេះ ត្រូវធ្វើនិយ័តកម្មនៅឱកាសធ្វើសារពើភ័ណ្ឌតាមរបៀបដូចតទៅ :

ក- បើសិនវិក្កយបត្រមិនទាន់បានទទួល ប៉ុន្តែសំភារៈបានប្រគល់ទទួលរួចហើយ បំណុលដែលមានទឹកប្រាក់ប៉ាន់ស្មានមួយត្រូវបានកត់ត្រាក្នុងគណនី "អ្នកផ្គត់ផ្គង់-វិក្កយបត្រមិនទាន់មកដល់" ដោយកត់ត្រាខាងឥណពន្ធនៃគណនីការទិញ ឬគណនីទ្រព្យសកម្ម ។

ខ- បើសិនវិក្កយបត្រត្រូវបានធ្វើគណនេយ្យកម្ម ប៉ុន្តែទ្រព្យសកម្មមិនទាន់បានទទួល ទ្រព្យសកម្មនេះត្រូវកត់បញ្ចូលក្នុងសារពើភ័ណ្ឌនាពេលបិទការិយបរិច្ឆេទ (អាចប្រើគណនី "ស្តុកស្ថិតនៅតាមផ្លូវ") ។

## ផ្នែកទី ៥.៦ : បន្ទុកសេវាខាងក្រៅ

១- ការជួល ដែលមានជាអាទិ៍ :

ក- ការជួលអចលនទ្រព្យ ឬចលនទ្រព្យសំរាប់បំរើអាជីវកម្ម : ក្នុងនេះអាចមានការបង់ប្រាក់ផ្សេងៗដូចតទៅ :

ក១- ប្រាក់ឈ្នួល និងបន្ទុកនៃការជួលអចលនទ្រព្យ ឬចលនទ្រព្យ សំរាប់បំរើអាជីវកម្មដោយសហគ្រាស (រួមទាំងអ្វីដែលបានបង់ក្នុងក្របខ័ណ្ឌកិច្ចសន្យានៃភតិសន្យាហិរញ្ញវត្ថុ) ត្រូវកាត់ចេញពីលទ្ធផលនៃការិយបរិច្ឆេទដែលត្រូវសងនូវប្រាក់ឈ្នួល និងបន្ទុកនេះ ទោះបីជាការបង់ប្រាក់ជាក់ស្តែងត្រូវបានធ្វើឡើងនៅថ្ងៃណាក៏ដោយ ។

ក២- ប្រាក់ឈ្នួលបង់មុន : ប្រាក់នេះត្រូវកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការ(ឧទាហរណ៍ នៅគណនី"បន្ទុកបានពិនិត្យកត់ត្រាមុន") ដូច្នេះពុំមានផលប៉ះពាល់ដល់លទ្ធផលនៃការិយបរិច្ឆេទនៃការបង់ប្រាក់ឡើយ ។ ប្រាក់នេះត្រូវបានកាត់ចេញតែពីលទ្ធផលនៃការិយបរិច្ឆេទដែលសហគ្រាសបានទូទាត់ប្រាក់នេះសំរាប់សងប្រាក់ឈ្នួលដែលត្រូវសងតែប៉ុណ្ណោះ ។

ក៣- ប្រាក់ធានា : ប្រាក់ដែលបានបង់ជាប្រាក់ធានា ត្រូវធ្វើគណនេយ្យកម្មនៅខាងទ្រព្យសកម្មនៃតារាងតុល្យការ ។ ប្រាក់ធានាអាចមានឥទ្ធិពលតែលើលទ្ធផលនៃការិយបរិច្ឆេទដែលប្រាក់នេះត្រូវបានទទួលយ៉ាងពិតប្រាកដដោយម្ចាស់កម្មសិទ្ធិនៃទ្រព្យជួលតែប៉ុណ្ណោះ ។

ក៤- សំរាប់គោលដៅខាងពន្ធដារ ប្រាក់ទឹកតែដែលសហគ្រាសបានបង់ឱ្យម្ចាស់កម្មសិទ្ធិនៃទ្រព្យជួលគឺជាចំណាយមិនអាចកាត់កងបាន ។

ខ- ការជួលកន្លែងស្នាក់នៅ : ប្រាក់ឈ្នួលកន្លែងស្នាក់នៅ ត្រូវជាប់ពន្ធទៅតាមមុខសញ្ញាប្រើប្រាស់នៃកន្លែងស្នាក់នៅជាប់ទាក់ទិន ។ ចំពោះកន្លែងស្នាក់នៅដែលសំរាប់បំរើតម្រូវការរបស់បុគ្គលិកសហគ្រាស

ប្រាក់ឈ្នួលគឺជាអត្ថប្រយោជន៍បន្ថែមដែលបុគ្គលិកបានទទួល ។ ចំពោះកន្លែងស្នាក់នៅសំរាប់បំរើតម្រូវការផ្សេងទៀត ប្រាក់ឈ្នួលគឺជាចំណាយមិនអាចកាត់កងបាន ។

២- ការងារថែទាំ និងជួសជុល : ជាគោលការណ៍ ចំណាយក្នុងការងារថែទាំនិងជួសជុល ត្រូវបានអនុញ្ញាតឱ្យកាត់កងបានតែក្នុងករណីតែមួយដែលអាចធ្វើឱ្យប្រើប្រាស់បានជាធម្មតានូវទ្រព្យសកម្មរបស់សហគ្រាស ដោយថែរក្សាទ្រព្យនេះឱ្យស្ថិតក្នុងសភាពអាចប្រើបាន ឬដំណើរការបានរហូតដល់ពេលបញ្ចប់នៃរយៈកាលរំលស់របស់វា និងដែលមិនធ្វើឱ្យមានការកែលំអជាប់លាប់នូវទ្រព្យនោះ ។ ការកែលំអជាប់លាប់ គឺជាការជួសជុល កែលំអសំរាប់ធ្វើឱ្យទ្រព្យសកម្មមានតំលៃលើស ឬសំរាប់អូសបន្លាយរយៈពេលប្រើប្រាស់នៃទ្រព្យនោះឱ្យបានវែងហួសរយៈកាលរំលស់ដែលបានកំណត់ទុកពីដើមដំបូង(ការកែលំអជាប់លាប់ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មជាប់ទាក់ទិន) ។

៣- ចំណាយធានារ៉ាប់រង : ចំណាយដែលបានបង់លើកិច្ចសន្យាធានារ៉ាប់រងហានិភ័យចំពោះទ្រព្យសកម្ម(គ្រោះថ្នាក់អគ្គីភ័យ ព្យុះ...) ឬកិច្ចសន្យាធានារ៉ាប់រងបន្ទុកជាយថាហេតុ (ជាអាទិ៍ ការទទួលខុសត្រូវខាង ពាណិជ្ជកម្ម ឬស៊ីវិល) ត្រូវកាត់ចេញពីលទ្ធផលនៃការិយបរិច្ឆេទដែលចំណាយនេះក្លាយជាបន្ទុកត្រូវសង (គឺត្រូវគណនាតាមចំនួនថ្ងៃដែលកិច្ចសន្យាធានារ៉ាប់រងត្រូវគ្របដណ្តប់នៅក្នុងការិយបរិច្ឆេទ) ។

៤- កំរៃជើងសារ និងលាភការខាងក្រៅ :

ក- កំរៃជើងសារ និងលាភការផ្សេងៗបានបង់នៅបរទេស : ចំនួនប្រាក់បង់ថ្លៃសេវាដែលបានផ្តល់នៅបរទេសឱ្យដល់សហគ្រាស ត្រូវបានអនុញ្ញាតឱ្យកាត់កងតែក្នុងករណីដែលភាពពិតនិងប្រយោជន៍របស់សេវាទាំងនេះត្រូវបានបង្ហាញ ហើយចំនួនទឹកប្រាក់សោហ៊ុយក៏មិនត្រូវបានបំផ្លើស ។

ខ- សួយសារចំពោះសម្បទាន ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ សញ្ញាផលិត សិទ្ធិអ្នកនិពន្ធ សិទ្ធិចំលង : សួយសារប្រភេទនេះអាចកាត់កងបាន ក្នុងករណីដែលវាមិនមែនជាសំណងនៃលទ្ធកម្មនូវទ្រព្យសកម្មណាមួយ ហើយចំនួនទឹកប្រាក់ក៏មិនត្រូវបានបំផ្លើស ។

៥- បេសកកម្ម : សោហ៊ុយបេសកកម្មអាចកាត់កងបាន ប្រសិនបើបេសកម្មនេះបំរើអាជីវកម្មយ៉ាងពិតប្រាកដ ហើយចំនួនទឹកប្រាក់ក៏មិនច្រើនហួសហេតុពេកធៀបទៅនឹងប្រភេទនិងទំហំរបស់អាជីវកម្ម និងធៀបទៅនឹងប្រាក់ចំណេញដែលសំរេចបាន ។ ចំពោះសោហ៊ុយចំរុះ (ជាអាទិ៍ សោហ៊ុយធ្វើដំណើរនិងបេសកកម្មដែលមានលក្ខណៈបំរើអាជីវកម្មផង និងធ្វើទេសចរកំសាន្តផង) ត្រូវបានអនុញ្ញាតឱ្យកាត់កងតែចំពោះចំណែកណាដែលមានលក្ខណៈមិនអាចប្រកែកបានថាបំរើអាជីវកម្មតែម្យ៉ាងប៉ុណ្ណោះ ។ សោហ៊ុយធ្វើដំណើរនិងបេសកកម្មទៅបរទេស អាចអនុញ្ញាតឱ្យកាត់កងបាន តែកាលណាប្រយោជន៍សំរាប់សហគ្រាសនៃការចំណាយទាំងនេះត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ ។ ដូចគ្នាដែរចំពោះការទៅចូលរួម ឬការរៀបចំសន្និសិទ្ធ សិក្ខាសាលា ប្រជុំ... សោហ៊ុយចំណាយអាចកាត់កងបានតែក្នុងលក្ខណៈដែលសកម្មភាពទាំងនេះជាប់ទាក់ទិនដោយផ្ទាល់ ទៅនឹងអាជីវកម្មរបស់សហគ្រាស ។

៦- ការកំសាន្ត ការសំរាកលំហែ : កថាខ័ណ្ឌ១ នៃមាត្រា ១៩ នៃចសព បានចែងថា មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេនូវចំណាយលើសកម្មភាពទាំងឡាយដែលជាទូទៅចាត់ទុកជាការកំសាន្ត ការសំរាកលំហែ ការទទួលភ្ញៀវ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលជាប់ទាក់ទិននឹងសកម្មភាពទាំងនេះ ។ ការទទួលភ្ញៀវមានជាអាទិ៍ ការអញ្ជើញភ្ញៀវហូបបាយនៅភោជនីយដ្ឋាន ការនាំភ្ញៀវធ្វើទេសចរ ការចេញថ្លៃបន្ទប់សណ្ឋាគារឱ្យភ្ញៀវ ... ។

## ផ្នែកទី ៥.៧ : ពន្ធ និងអាករ

១- ការិយបរិច្ឆេទត្រូវទទួលរងបន្ទុកពន្ធ :

ក- ចំពោះពន្ធអាករដែលមិនត្រូវបានប្រមូលតាមវិធីដាក់លិខិតប្រកាសសារពើពន្ធទេនោះ ពន្ធអាករទាំងនេះ គឺជាបន្ទុកនៃការិយបរិច្ឆេទដែលពន្ធអាករទាំងនេះបំពេញបាននូវល័ក្ខខ័ណ្ឌនានានៃចំណាយអាចកាត់កងបាន ។

ខ- ចំពោះពន្ធអាករដែលត្រូវបានប្រមូលតាមវិធីដាក់លិខិតប្រកាសសារពើពន្ធ ក្នុងករណីដែលពន្ធអាករទាំងនេះអាចកាត់កងបាន គឺត្រូវកាត់ចេញពីលទ្ធផលនៃការិយបរិច្ឆេទដែលពន្ធអាករទាំងនេះត្រូវបានដាក់ឱ្យប្រមូល ឬក្លាយជាបំណុលត្រូវសង ។

២- ពន្ធអាករអាចកាត់កងបាន : សំរាប់គោលដៅនៃពបច សហគ្រាសអាចកាត់កងបាននូវពន្ធអាករទាំងឡាយដែលជាបន្ទុករបស់សហគ្រាស លើកលែងតែប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា ។ ពន្ធអាករដែលអាចកាត់កងបានទាំងនេះរួមមាន ពន្ធប៉ាតង់ ពន្ធលើការនាំចូលនិងការនាំចេញ (ពន្ធគយ) អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករលើផលរបរ អាករលើតម្លៃបន្ថែមដែលមិនអាចកាត់កងបាន(អាករលើធាតុចូលដែលមិនអនុញ្ញាតជាឥណទាន) ពន្ធប្រថាប់ត្រា ពន្ធតែមប្រ៊ី ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ... ។

៣- ពន្ធអាករដែលត្រូវបានប្រមូលតាមរបៀបកាត់ទុក : ពន្ធអាករដែលត្រូវបានប្រមូលតាមរបៀបកាត់ទុក ពុំមែនជាពន្ធដែលជាបន្ទុករបស់សហគ្រាសទេ ប៉ុន្តែគឺជាបន្ទុករបស់អ្នកទទួលចំណូលដែលត្រូវជាប់ពន្ធ (ឧទាហរណ៍ ពន្ធលើប្រាក់បៀវត្ស) ។ ដូច្នេះ ពន្ធនេះមិនអាចកាត់ចេញពីប្រាក់ចំណេញជាប់ពន្ធរបស់សគ្រាសបានទេ ។

## ផ្នែកទី ៥.៨ : បៀវត្ស និងបន្ទុកប្រហាក់ប្រហែល

១- ល័ក្ខខ័ណ្ឌនៃការកាត់កង : ប្រាក់បៀវត្សជាប់ពន្ធលើប្រាក់បៀវត្ស ប្រាក់បៀវត្សរួចពន្ធ និងអត្ថប្រយោជន៍បន្ថែម ដូចមានចែងនៅក្នុងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស លេខ ៣៩៦ ប្រក.សហវ.ពដ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺអាចកាត់កងបានទាំងអស់ ក្នុងករណីដែលទឹកប្រាក់ទាំងនេះជាប់ទាក់ទងទៅនឹងការងារពិតប្រាកដ និងមិនហួសហេតុធៀបនឹងសារៈសំខាន់នៃសេវាដែលបានផ្តល់ ។ ពាក្យ "ហួសហេតុ" មានន័យថាបំផ្លើស ឬច្រើនពេក បើប្រៀបទៅនឹងការពិតឬតំលៃពិត ។

២- ការិយបរិច្ឆេទត្រូវកត់បញ្ចូលជាបន្ទុក : ចំណាយលើបុគ្គលិកមានលក្ខណៈជាបន្ទុកប្រចាំឆ្នាំ និងជាបន្ទុកធម្មតានៃអាជីវកម្ម ។ ដោយហេតុនេះ ចំណាយលើបុគ្គលិកត្រូវកាត់ចេញពីលទ្ធផលនៃការិយបរិច្ឆេទដែលបានទទួលរងដោយពិតប្រាកដនូវចំណាយនេះតែប៉ុណ្ណោះ ។ ដោយឡែកនៅចុងការិយបរិច្ឆេទ អាចមានប្រាក់បៀវត្សខ្លះត្រូវបានបើកមុន ឬមិនទាន់បានបើកឱ្យបុគ្គលិក ។ ប្រាក់បៀវត្សទាំងនេះដែលមានលក្ខណៈជាបំណុលប្រាកដប្រជា គឺអាចកាត់កងបានដោយឆ្លងកាត់គណនីបន្ទុកបានពិនិត្យកត់ត្រាមុន ឬគណនីបន្ទុកត្រូវសង ។

៣- ប្រភេទផ្សេងៗនៃលាភការ :

ក- លាភការនៃបុគ្គលិកទទួលបៀវត្សដែលមិនមែនជាអ្នកគ្រប់គ្រង : នេះជាករណីទូទៅ និងដែលមានចែងលំអិតនៅក្នុងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស ។

ខ- លាភការនៃម្ចាស់សហគ្រាសឯកបុគ្គលនិងក្រុមគ្រួសារ : ប្រាក់ចំណេញដែលសហគ្រាសឯកបុគ្គលសំរេចបាន គឺជាលាភការសំរាប់ការងារបំរើអាជីវកម្មរបស់ម្ចាស់សហគ្រាស និងសហព័ទ្ធរបស់គាត់ និងជាលាភការសំរាប់មូលធនដែលត្រូវបានយកមកវិនិយោគក្នុងអាជីវកម្មផង ។ ដូច្នេះការកាត់យក

ផ្សេងៗ ដោយម្ចាស់សហគ្រាសនិងសហព័ន្ធ អាស្រ័យដោយពួកគេមានសកម្មភាពនៅក្នុងសហគ្រាសនោះ គឺជាការប្រើប្រាស់ប្រាក់ចំណេញ និងមិនមែនជាបន្ទុកត្រូវកាត់កងទេ ។ ដោយហេតុថាប្រាក់ចំណេញរបស់សហគ្រាសឯកបុគ្គលជាកម្មសិទ្ធទាំងស្រុងរបស់ម្ចាស់សហគ្រាស ដូច្នេះម្ចាស់សហគ្រាសឯកបុគ្គលត្រូវបានអនុញ្ញាតឱ្យដកយកប្រាក់ចំណេញនេះប្រើប្រាស់ផ្ទាល់ខ្លួនមុនបាន ដោយមិនជាប់ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភទេ ។ ប៉ុន្តែក្នុងករណីដែលរដ្ឋបាលសាពើពន្ធមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាការដកយកមុននូវប្រាក់ចំណេញនេះធ្វើឱ្យអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចតម្រូវឱ្យអ្នកជាប់ពន្ធបង់ពន្ធភ្លាមបាន ។

គ- លាភការផ្តល់ឱ្យសមាជិកផ្សេងទៀតនៃក្រុមគ្រួសាររបស់ម្ចាស់សហគ្រាសឯកបុគ្គល : លាភការដែលផ្តល់ឱ្យកូន កូនប្រសារ និងញាតិពន្ធនានា របស់ម្ចាស់សហគ្រាស គឺអាចកាត់កងបានដរាបណាវាជាថ្នូរនៃការងារពិតប្រាកដមានចំនួនទឹកប្រាក់មិនបំផ្លើស និងពិតជាបានបើកឱ្យជាក់ស្តែងមែន ។

ឃ- លាភការរបស់អ្នកគ្រប់គ្រងនៃនីតិបុគ្គល : ដោយហេតុជនទាំងនេះមានសិទ្ធិត្រួតពិនិត្យ និងសិទ្ធិសំរេចលាភការដែលពួកគេបានទទួលអាចមានលក្ខណៈបំផ្លើស ។ លក្ខណៈវិនិច្ឆ័យដូចតទៅ អាចប្រើប្រាស់បានសំរាប់បញ្ជាក់បង្ហាញ និងកំណត់ចំនួននៃការបំផ្លើសនេះ (ភាគនៃលាភការដែលត្រូវបានចាត់ទុកថាជាការបំផ្លើស គឺជាចំណាយមិនអាចកាត់កងបាន) :

ឃ១- សារៈសំខាន់នៃសកម្មភាពដែលបានបំពេញដោយអ្នកគ្រប់គ្រង និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ឱ្យអ្នកគ្រប់គ្រងនោះ

ឃ២- ការវិវត្តន៍នៃផលរបរ និងប្រាក់ចំណេញពិតរបស់សហគ្រាស

ឃ៣- ទំហំសហគ្រាស

ឃ៤- ការប្រៀបធៀបលាភការនេះជាមួយនឹងលាភការដែលបានផ្តល់ឱ្យបុគ្គល មានការងារស្រដៀងគ្នានៅក្នុងសហគ្រាសមួយទៀតដែលធ្វើអាជីវកម្មប្រហាក់ប្រហែលគ្នានៅក្នុងតំបន់ឬជាមួយនឹងលាភការដែលបានផ្តល់ឱ្យអ្នកបំរើការងារយកបៀវត្សដែលមានឋានៈនាទីនៅក្នុងសហគ្រាស

ឃ៥- ការប្រៀបធៀបរវាងលាភការសរុបដែលបានផ្តល់ឱ្យទៅអ្នកដឹកនាំ និងបៀវត្សដែលបានផ្តល់ឱ្យបុគ្គលិកទាំងអស់ដែលត្រូវទទួលបៀវត្ស ។

៤- គួរកត់សំគាល់ថា ចំនួនទឹកប្រាក់កត់ត្រាខាងឥណពន្ធទៅក្នុងគណនីចំណាយ និងកត់ត្រាខាងឥណទានក្នុងគណនីសមាគត (អ្នកចូលហ៊ុន) ឬគណនីបុគ្គលទាក់ទិន ត្រូវបានចាត់ទុកថាបានចាយក្នុងឆ្នាំសារពើពន្ធដែលចំណាយត្រូវបានកត់ត្រាខាងឥណពន្ធ ។

៥- ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ ពាក្យ "ឥណទាន" និង "ឥណទានបានកត់ត្រា" សំដៅដល់ហេតុការណ៍ដែលនិវាសនជនឬអនិវាសនជនបានកត់ត្រាជាមុននូវបំណុលសំរាប់ទូទាត់ឱ្យម្ចាស់បំណុលអនិវាសនជន ដែលក្នុងនោះមាន :

ក- ការទូទាត់ទៅឱ្យអ្នកជួល ឬភ្នាក់ងារ តាមរយៈគណនីធនាគារក្នុងនាមម្ចាស់កម្មសិទ្ធិអនិវាសនជន

ខ- ការទូទាត់ការប្រាក់ធនាគារទៅក្នុងគណនីសន្សំរបស់អនិវាសនជន

គ- ក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនទិញ-លក់ហ៊ុនដាក់តំកល់ ប្រាក់សោធននិវត្តន៍ ឬប្រាក់បំណាច់ប្រចាំឆ្នាំ ទៅក្នុងគណនីធនាគាររបស់អនិវាសនជន

ឃ- ការកាត់កងទឹកប្រាក់ដែលត្រូវទូទាត់ដោយនិវាសនជន (ឬអ្នកដែលត្រូវបានចាត់ទុកថាជានិវាសនជន) នៃទឹកប្រាក់ដែលអនិវាសនជនជំពាក់

ង- ចំនួនទឹកប្រាក់ដែលបានកត់ត្រាជាឥណទានទៅក្នុងគណនីពិសេសរបស់សមាគត ។

៦- បន្ទុកខាងសង្គមកិច្ច : បន្ទុកខាងសង្គមកិច្ចទាំងឡាយណាដែលបានបញ្ញត្តិនៅក្នុងច្បាប់ការងារ គឺអាចកាត់កងបាន ។

## ផ្នែកទី ៥.៩ : ការប្រាក់

១- និយមន័យ :

ក- ពាក្យ "ការប្រាក់" សំដៅដល់ទឹកប្រាក់ដែលកូនបំណុលត្រូវសងម្ចាស់បំណុល និងដែលជាប់ទាក់ទិននឹងប្រាក់នានាដែលកូនបំណុលជំពាក់ម្ចាស់បំណុល។ ការប្រាក់ គឺជាតំលៃនៃការឱ្យខ្ចីប្រាក់ ឬជាតំលៃនៃការយល់ព្រមមិនតាមទារឥណទានដែលបានផ្តល់ឱ្យជាទំនិញឬសេវា ។ ការប្រាក់មាន ជាអាទិ៍ :

ក១- ទឹកប្រាក់ដែលបានបង់ឬត្រូវបង់តាមកាតព្វកិច្ចបំណុលដែលមិនមែនជាការបង្វិលសងប្រាក់ដើម

ក២- ប្រាក់ចុះថ្លៃ បុព្វលាភ ឬការទូទាត់ប្រហាក់ប្រហែលគ្នានេះ ។

ខ- ពាក្យ "កាតព្វកិច្ចបំណុល" សំដៅដល់កាតព្វកិច្ចធ្វើការទូទាត់សងជាសាច់ប្រាក់ ឬជាទ្រព្យសកម្មទៅឱ្យបុគ្គលម្នាក់ទៀត ក្នុងនេះមានទាំងកាតព្វកិច្ចរបស់ធនាគារឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតចំពោះប្រាក់បញ្ញើ កាតព្វកិច្ចចំពោះសមតុល្យក្នុងគណនីត្រូវសង រូបិយាណត្តិ សញ្ញាប័ណ្ណ ...។

២- ការប្រាក់នៃប្រាក់ខ្ចីពីតតិយជន :

ក- ការប្រាក់នៃប្រាក់ដែលសហគ្រាសខ្ចីពីតតិយជនសំរាប់បំរើតម្រូវការក្នុងអាជីវកម្ម ត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីលទ្ធផលនៃការិយបរិច្ឆេទដែលការប្រាក់ក្លាយជាបំណុលត្រូវសង (ពោលគឺការប្រាក់សំរាប់រយៈពេលមួយក្នុងការិយបរិច្ឆេទ) ។ ក្នុងនេះសហគ្រាសត្រូវបង្ហាញឱ្យឃើញនូវភាពពិតនៃប្រាក់ខ្ចីដោយមានភស្តុតាងជាលិខិតខ្ចីប្រាក់ ដែលមានចុះថ្ងៃខែជាក់លាក់ និងដែលមានកំណត់ច្បាស់លាស់នូវបែបបទនៃការសងប្រាក់ដើម និងការប្រាក់ ។

ខ- ការប្រាក់នៃប្រាក់ខ្ចីពីតតិយជន សំរាប់តម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសឯកបុគ្គល គឺមិនអាចកាត់កងបានទេ ។ ចំពោះសហគ្រាសឯកបុគ្គល ស្ថានភាពនេះកើតមានឡើងកាលបើគណនីម្ចាស់សហគ្រាសមានសមតុល្យឥណាយិក (សមតុល្យនៃគណនីម្ចាស់សហគ្រាសនាពេលបិទការិយបរិច្ឆេទ គឺត្រូវស្មើនឹងសមតុល្យនៃគណនីនេះនាពេលបើកការិយបរិច្ឆេទ ដកឬបន្ថែមនូវរាល់ការកាត់យកផ្សេងៗ ឧបហារិតនៃម្ចាស់សហគ្រាស ព្រមទាំងប្រាក់ខាតឬប្រាក់ចំណេញនៃការិយបរិច្ឆេទ) ។ ដូច្នេះសហគ្រាសអាចត្រូវធ្វើការខ្ចីបុល ដើម្បីទប់ទល់នឹងការខ្វះខាតប្រាក់កាសដែលមានដើមហេតុពីការដែលម្ចាស់សហគ្រាសបានដកយកមុននូវទឹកប្រាក់លើសពីចំនួនដែលខ្លួនត្រូវបានចំណេញ ។ ក្នុងករណីនេះការប្រាក់អាចកាត់ចេញបាន គឺមានតែការប្រាក់ដែលទាក់ទងដល់ចំណែកនៃការខ្ចីដែលលើសពីតួលេខសមតុល្យឥណាយិកខ្ពស់បំផុតនៅក្នុងឆ្នាំជាប់ពន្ធនៃគណនីម្ចាស់សហគ្រាសតែប៉ុណ្ណោះ ។

៣- ការប្រាក់នៃមូលធន : ទឹកប្រាក់នានាដែលបានទូទាត់ឱ្យសំរាប់ជាលាភការនៃមូលនិធិផ្ទាល់របស់សហគ្រាស គឺមិនអាចកាត់កងបានទេ ។

៤- ការប្រាក់សងឱ្យគណនីម្ចាស់សហគ្រាសឯកបុគ្គល : ចំណាយនេះមិនអាចកាត់កងបានទេ ។

៥- ចំណាយការប្រាក់មិនអាចកាត់កងបាន : ចំណាយការប្រាក់ណាមួយដែលបទប្បញ្ញត្តិក្នុងកថាខ័ណ្ឌ២ កថាខ័ណ្ឌ៣ និងកថាខ័ណ្ឌ៤ នៃផ្នែកនេះមិនអនុញ្ញាតឱ្យកាត់កង គឺជាចំណាយមិនអាចកាត់កងបាន ។

៦- កំហិតលើការកាត់កងការប្រាក់ : សំរាប់ឆ្នាំជាប់ពន្ធណាមួយការប្រាក់នានាដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងកថាខ័ណ្ឌ ២ កថាខ័ណ្ឌ ៣ និងកថាខ័ណ្ឌ ៤ នៃផ្នែកនេះ ត្រូវស្ថិតក្រោមកំហិតលើការកាត់កងការប្រាក់សំរាប់ឆ្នាំជាប់ពន្ធនោះ ។ កំហិតលើការកាត់កងការប្រាក់សំរាប់ឆ្នាំជាប់ពន្ធណាមួយ គឺជាចំនួនទឹកប្រាក់ការប្រាក់អតិបរមា ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និងដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម ។ ក្នុងនេះ ចំណាយការប្រាក់ណាដែលមិនត្រូវបានអនុញ្ញាតឱ្យយកមកកាត់កងនៅក្នុងឆ្នាំចរន្តអាចយោងជាចំណាយការប្រាក់សំរាប់ឆ្នាំបន្តបន្ទាប់ទៀតបានសំរាប់ធ្វើការកាត់កងនៅក្នុងកំហិតដូចគ្នា រហូតដល់សមតុល្យនៃចំណាយការប្រាក់មិនទាន់អនុញ្ញាតឱ្យកាត់កងនេះត្រូវបានប្រើប្រាស់អស់ ។ ការកំណត់ចំនួនការប្រាក់អនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវធ្វើឡើងនៅចុងឆ្នាំជាប់ពន្ធនោះ ។

កំហិតលើការប្រាក់ = ក + ខ

ក = ៥០% នៃប្រាក់ចំណេញសុទ្ធដែលត្រូវបានគណនា ដោយគ្មានចំណូលការប្រាក់ ឬចំណាយការប្រាក់ ហើយដោយការប្រាក់ត្រូវបានកំណត់តាមកថាខ័ណ្ឌ ១ នៃផ្នែកនេះ

ខ = ចំណូលការប្រាក់ដែលបានទទួល ឬត្រូវបានទទួលនៅក្នុងឆ្នាំជាប់ពន្ធ ។

## ផ្នែកទី ៥.១០ : បន្ទុកពិសេស

១- ទោសទណ្ឌ និងពិន័យ : ប្រាក់ពន្ធបន្ថែម ការប្រាក់យឺតយ៉ាវ ប្រាក់ពិន័យផ្សេងៗ និងទោសទណ្ឌគ្រប់ប្រភេទដែលសហគ្រាសបានទទួលរងដោយសារការល្មើសនឹងបទប្បញ្ញត្តិច្បាប់ផ្សេងៗ គឺត្រូវគិតបញ្ចូលមកវិញដើម្បីធ្វើការកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ ទោសទណ្ឌ និងពិន័យ មានជាអាទិ៍ :

ក- ការប្រាក់យឺតយ៉ាវ និងប្រាក់ពន្ធបន្ថែមមកពីការមិនគោរពកាតព្វកិច្ចសារពើពន្ធ

ខ- ប្រាក់ពិន័យខាងគយ

គ- ប្រាក់ពិន័យពីការល្មើសបទប្បញ្ញត្តិច្បាប់ស្តីពីថ្លៃ ឬបទប្បញ្ញត្តិខាងសេដ្ឋកិច្ច

ឃ- ប្រាក់ពិន័យអនុវត្តលើបទល្មើសផ្ទាល់ខ្លួនរបស់បុគ្គល (ពិន័យព្រហ្មទ័ណ្ឌ)

ង- ប្រាក់ពិន័យដែលជាការដាក់ទោសចំពោះការល្មើសនឹងបទប្បញ្ញត្តិសាធារណៈ ។

២- វិភាគទានសប្បុរសធម៌ :

ក- ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវវិភាគទានសប្បុរសធម៌ ដែលបានបរិច្ចាគឱ្យដល់ស្ថាប័នរដ្ឋាភិបាល និងអង្គការនានា ដែលធ្វើសកម្មភាពមិនស្វែងរកចំណេញ ដូចមានចែងក្នុងផ្នែកទី ១.៦ នៃប្រកាសនេះ ប៉ុន្តែចំនួនទឹកប្រាក់វិភាគទានសប្បុរសធម៌ដែលអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធណាមួយ មិនត្រូវឱ្យលើសពី ៥ ភាគរយ នៃប្រាក់ចំណេញជាប់ពន្ធ(នៃឆ្នាំជាប់ពន្ធនោះ) មុនពេលកាត់កងវិភាគទានសប្បុរសធម៌ឡើយ ។ ចំពោះសហគ្រាសធានារ៉ាប់រង ក៏រិតទឹកប្រាក់វិភាគទានសប្បុរសធម៌ដែលត្រូវបានអនុញ្ញាតសំរាប់ឆ្នាំជាប់ពន្ធណាមួយគឺ ៥ ភាគរយ នៃបុព្វលាភដុលក្នុងឆ្នាំជាប់ពន្ធនោះ ។

ខ- ចំពោះទឹកប្រាក់វិភាគទានសប្បុរសធម៌ដែលនៅសល់ពីការកាត់កង ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ទឹកប្រាក់នេះមិនអាចយោងទៅកាត់កងនៅឆ្នាំជាប់ពន្ធណាមួយផ្សេងទៀតបានទេ ពោលគឺត្រូវក្លាយជាចំណាយមិនអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធដែលទឹកប្រាក់នេះបានកើតឡើង ។

៣- អំណោយ និងឧបត្ថម្ភកធនផ្សេងៗ : អំណោយ និងឧបត្ថម្ភកធនផ្សេងៗ ដែលសហគ្រាសបានធ្វើទោះក្នុងគោលដៅបែបណាក៏ដោយ សុទ្ធតែជាចំណាយមិនអាចកាត់កងបានទាំងអស់ ។

៤- ការរំលឹកពន្ធ : ក្នុងករណីនេះ ការកាត់កងត្រូវស្របទៅតាមប្រភេទពន្ធនីមួយៗ ដែលមានការរំលឹកនេះ ។ ដោយឡែកសំរាប់ពន្ធកាត់ទុកដែលអ្នកទូទាត់ប្រាក់ត្រូវកាត់ទុកប្រាក់ពន្ធមុនពេលទូទាត់ ប៉ុន្តែមិនបានកាត់ទុកប្រាក់ពន្ធ ហើយដែលត្រូវបានរដ្ឋបាលសារពើពន្ធរំលឹកឱ្យបង់ពន្ធដែលត្រូវកាត់ទុកនេះ ពន្ធដែលរំលឹកឱ្យបង់ពីការខកខាននេះ មិនអនុញ្ញាតឱ្យកាត់កងសំរាប់គណនាប្រាក់ចំណេញជាប់ពន្ធទេ ។

៥- ខាតលើឥណទេយ្យ : សំរាប់គោលដៅនៃពបច ខាតលើឥណទេយ្យ គឺអាចកាត់កងបានក្នុងករណីដែលភាពមិនអាចទារបាននៃឥណទេយ្យនេះត្រូវបានបញ្ជាក់បង្ហាញដោយជាក់ស្តែង (ឧទាហរណ៍ដូចជា ការព្យាយាមបង្ហាញឯកសារប្រមូលបំណុល ឬមានភស្តុតាងច្បាស់លាស់នៃការខិតខំព្យាយាមក្នុងការប្រមូល ឬទទួលបានទឹកប្រាក់ដែលជំពាក់ដោយអសាធនភាពជាស្ថាពររបស់កូនបំណុល...) ហើយឥណទេយ្យនោះត្រូវបានលុបចេញពីបញ្ជីគណនេយ្យរបស់សហគ្រាស ។ លើកលែងតែមានភស្តុតាងបញ្ជាក់ផ្ទុយ ការបោះបង់ចោលនូវឥណទេយ្យគឺជាទង្វើមិនធម្មតានៃការគ្រប់គ្រង ដូច្នេះមិនអាចកាត់កងបានទេ ។

៦- បន្ទុកពិសេសផ្សេងៗ : ការបាត់បង់ផ្សេងៗ និងបន្ទុកដទៃទៀត តាមធម្មតាគឺអាចកាត់កងបានក្នុងលក្ខណៈដែលការបាត់បង់និងបន្ទុកទាំងនេះ បានកើតមានឡើងក្នុងក្របខ័ណ្ឌនៃដំណើរការអាជីវកម្មធម្មតារបស់សហគ្រាស ពោលគឺការបាត់បង់និងបន្ទុកទាំងនេះ មិនទាក់ទងនឹងទង្វើមិនធម្មតានៃការគ្រប់គ្រងទេ ។ ម្យ៉ាងវិញទៀត ត្រូវធានាថាការបាត់បង់និងបន្ទុកទាំងនេះ មិនត្រូវបានកាត់កងរួចហើយតាមរបៀបណាមួយផ្សេងទៀតនោះទេ (ឧទាហរណ៍ ការបាត់បង់ទំនិញបណ្តាលមកពីចោរលួច ឬគ្រោះមហន្តរាយ ពុំត្រូវមានការកាត់កងអ្វីដោយឡែកនោះទេ ពីព្រោះការបាត់បង់នេះត្រូវបានគិតបញ្ចូលមកកាត់កងជាស្វ័យប្រវត្តិតាមយន្តការនៃការធ្វើគណនេយ្យកម្មការទិញ ការលក់ និងស្តុក) ។

## ជំពូកទី៦

## វិធាននានាទៅស្តីពីរំលស់

### ផ្នែកទី ៦.១ : និយមន័យ

១- លទ្ធកម្ម (ការទិញ ការទទួលបាន ការបញ្ចូល...) នៃអចលកម្មពុំបណ្តាលឱ្យមានការថយចុះនៃទ្រព្យសកម្មសុទ្ធទេ ពីព្រោះការចំណាយត្រូវបានជាថ្នូរបញ្ចូលមកវិញនៅក្នុងទ្រព្យសកម្មរបស់សហគ្រាសនូវទ្រព្យសកម្មថ្មីមួយ ។ ដូច្នេះលទ្ធកម្មនៃអចលកម្មពុំមានជះឥទ្ធិពលដល់លទ្ធផលជាប់ពន្ធឡើយ ។ ប៉ុន្តែភាគច្រើននៃអចលកម្មតែងត្រូវសឹករេចដោយការប្រើប្រាស់និងដោយភាពហួសសម័យ ។ ដូច្នេះជាធម្មតាត្រូវយកមកគិតគូរនូវការសឹករេចនេះដែលជាបន្ទុកមួយយ៉ាងពិតប្រាកដចំពោះសហគ្រាស ។

២- រំលស់ គឺជាការពិនិត្យកត់ត្រាអំពីការសឹករេចជាស្ថាពរនៃទ្រព្យសកម្ម ដែលបណ្តាលមកពីការប្រើប្រាស់ពីពេលវេលាពីការផ្លាស់ប្តូរបច្ចេកទេស ឬពីមូលហេតុផ្សេងទៀត ។ ក្នុងនេះត្រូវធ្វើការបែងចែកបរិយាទាននៃទ្រព្យសកម្មទៅតាមរយៈពេលគ្រោងទុកនៃការប្រើប្រាស់(អាយុកាលប្រើប្រាស់) ដោយផ្អែកតាមផែនការរំលស់មួយ ។ រាល់ការកែប្រែធំដុំក្នុងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ទ្រព្យសកម្ម តម្រូវឱ្យមានការសើរើផែនការរំលស់ដែលកំពុងអនុវត្ត ។

៣- សំរាប់គោលដៅនៃពបច ដើម្បីអាចកាត់កងបាន រំលស់ត្រូវបំពេញល័ក្ខខ័ណ្ឌ ៥ យ៉ាង ដូចតទៅនេះ :

ក- រំលស់ត្រូវធ្វើតែលើអចលកម្មដែលកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់សហគ្រាស

ខ- រំលស់ត្រូវធ្វើតែលើអចលកម្មដែលទទួលរងការសឹករេច

គ- រំលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម

ឃ- វិលស់ត្រូវគណនាតាមវិធីរំលស់ស្មើភាគសំរាប់ទ្រព្យសកម្មស្ថិតក្នុងថ្នាក់១ ឬវិធីរំលស់ថយជាលំដាប់សំរាប់ទ្រព្យសកម្មស្ថិតក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤

ង- រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស ។

៤- ក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ ការកាត់កងសំរាប់រំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យសកម្មរូបី ឬអ្នកជួលទ្រព្យសកម្មរូបីក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ ឬការខូចខាតនៃទ្រព្យ ។ ជាធម្មតា ចំពោះភតិសន្យាហិរញ្ញវត្ថុ អ្នកទទួលជួលជាអ្នកទទួលរងនូវហានិភ័យខាងលើ ។

## ផ្នែកទី៦.២: រំលស់ត្រូវធ្វើតែលើអចលកម្មកត់ត្រាខាងទ្រព្យសកម្មនៃតារាងតុល្យការរបស់សហគ្រាស

១- សហគ្រាសត្រូវធ្វើរំលស់តែលើអចលកម្មដែលកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់ខ្លួន ។ ចំពោះអចលកម្មដែលត្រូវបានប្រើប្រាស់ចំរុះ (គឺបំរើអាជីវកម្មសហគ្រាសផង និងបំរើការងារក្រៅអាជីវកម្មផង) :

ក- សហគ្រាសឯកបុគ្គល : ចំពោះការប្រើប្រាស់អចលកម្មសំរាប់បំរើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស ត្រូវបានចាត់ទុកថាបានលក់តាមតំលៃទីផ្សារឱ្យម្ចាស់សហគ្រាស(កត់ត្រាចូលក្នុងផលបន្ទាប់បន្សំ)នូវសេវាមួយដែលជាសេវានៃការផ្តល់អចលកម្មសំរាប់បំរើតម្រូវការផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាស ហើយម្ចាស់សហគ្រាសត្រូវបានចាត់ទុកថាបានដកយកប្រើប្រាស់ផ្ទាល់ខ្លួននូវសេវារបស់សហគ្រាសនេះ ។ ប្រសិនបើអ្នកទទួលផលមិនមែនជាម្ចាស់សហគ្រាស នោះគឺជាការលក់សេវានិងការផ្តល់អត្ថប្រយោជន៍បន្ថែម ឬការធ្វើចំណាយមិនអាចកាត់កងបាន ។

ខ- សហគ្រាសនីតិបុគ្គល : សហគ្រាសត្រូវបានចាត់ទុកថាបានលក់សេវា និងបានផ្តល់អត្ថប្រយោជន៍បន្ថែម ឬបានធ្វើចំណាយមិនអាចកាត់កងបាននៃការប្រើប្រាស់អចលកម្មក្នុងគោលដៅមិនមែនអាជីវកម្ម ។

គ- ចំពោះសហគ្រាសដែលបានអនុវត្តតាមវិធានដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ ការប្រើប្រាស់ចំរុះនូវអចលកម្មកត់ត្រាក្នុងតារាងតុល្យការ ពុំមានផលប៉ះពាល់អ្វីដល់ការធ្វើរំលស់ទេ ។

២- ចំពោះទ្រព្យសកម្មអរូបីនីមួយៗ និងទ្រព្យសកម្មនៅក្នុងថ្នាក់១ ដែលកត់ត្រានៅក្នុងតារាងតុល្យការ សហគ្រាសត្រូវបើកគណនីទ្រព្យសកម្មមួយសំរាប់កត់ត្រារាល់ទឹកប្រាក់ដែលជាប់ទាក់ទិននឹងទ្រព្យសកម្មនោះ(ថ្លៃទិញ ទឹកប្រាក់កាត់បន្ថយ ទឹកប្រាក់បង្វិលសងវិញ ការកែលំអជាប់លាប់...) ។

៣- ចំពោះទ្រព្យសកម្មរូបីក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ ដែលបានកត់ត្រាក្នុងគណនីទ្រព្យសកម្មរួមគ្នា សហគ្រាសត្រូវបើកគណនីសំរាប់ថ្នាក់នីមួយៗ ដោយត្រូវកត់ត្រាចូលនូវចំនួនទឹកប្រាក់ដែលមិនទាន់បានធ្វើរំលស់ ចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងលទ្ធកម្មបន្ថែម(ការទិញបន្ថែម ការទទួលបន្ថែម ការបញ្ចូលបន្ថែម...) នូវទ្រព្យសកម្ម និងចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងការបញ្ចេញទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ ។

## ផ្នែកទី ៦.៣ : រំលស់ត្រូវធ្វើតែលើចំណែកដែលទទួលរងការសឹករេចរឹល

១- និយមន័យនៃអចលកម្ម : អចលកម្ម ឬទ្រព្យសកម្មជាប់លាប់ គឺជាចំណែក (ឬសមាសភាគ) នៃទ្រព្យសកម្មដែលសំរាប់ប្រើប្រាស់យូរអង្វែងនៅក្នុងសកម្មភាពនៃអង្គភាពអាជីវកម្ម និងដែលរក្សាបាននូវរូបរាងដើមដដែលចាប់ពីពេលដាក់ប្រើប្រាស់រហូតដល់ពេលឈប់លែងប្រើការ ។ ទ្រព្យសកម្មណាមួយ ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យទាំងពីរដូចតទៅ ទើបអាចចាត់ទុកជាអចលកម្មបាន :

ក- គោលដៅ : ទ្រព្យសកម្មគ្រប់ប្រភេទ (ចលនទ្រព្យ ឬអចលនទ្រព្យ ទ្រព្យសកម្មរូបី ឬអរូបី) ដែលសហគ្រាសបានទិញឬបានផលិត មិនមែនសំរាប់ប្តូរភាព ឬមិនមែនសំរាប់លក់ (ប្រសិនបើលក់ទៅវិញ

គឺលក់នៅក្រោយពេលបានដាក់ប្រើប្រាស់ហើយ) ប៉ុន្តែគឺសំរាប់ប្រើប្រាស់យូរអង្វែង (ឧទាហរណ៍ រថយន្ត ដែលសហគ្រាសលក់រថយន្តទិញមកសំរាប់លក់ទៅវិញគឺជាចំណែកមួយនៃការទិញនិងស្តុក រីឯរថយន្ត ប្រើប្រាស់សំរាប់បំរើតម្រូវការផ្ទៃក្នុងរបស់សហគ្រាស គឺជាអចលកម្ម) ។

ខ- រយៈពេល : ការរក្សាទុកទ្រព្យសកម្មនៅក្នុងអង្គភាពអាជីវកម្មត្រូវបានកំណត់ថាជាប់លាប់ ប្រសិន បើមានរយៈពេលលើសពី ១ ឆ្នាំ ដោយគិតចាប់តាំងពីពេលដាក់ប្រើប្រាស់ដំបូង ។

២- ភាពខុសគ្នារវាងអចលកម្ម និងបន្ទុក : ការចំណាយដែលមានផ្ទួរជាការបញ្ចូលនូវចំណែកថ្មីមួយទៅក្នុងទ្រព្យសកម្ម នៃសហគ្រាស គឺជាអចលកម្ម ។ ចំពោះចំណាយទាក់ទិននឹងទ្រព្យសកម្មដែលបានកត់ត្រារួច ហើយនៅក្នុង តារាងតុល្យការ សហគ្រាសត្រូវអនុវត្តតាមសេចក្តីចែងនៅក្នុងកថាខ័ណ្ឌ២ នៃផ្នែកទី៥.៦ នៃប្រកាសនេះ ។

៣- អចលកម្មដែលអាចរំលស់បាន : អចលកម្មអាចរំលស់បាន គឺជាអចលកម្មដែលមានភាពប្រើការបានត្រូវចុះថយជា ធម្មតាទៅតាមពេលវេលា ដោយសារបាតុភូតនៃភាពសឹករេច ឬភាពចាស់ទៅៗ ភាពមិនស្របទៅតាមល័ក្ខខ័ណ្ឌ ប្រែប្រួលថ្មីនៃបច្ចេកទេសឬសេដ្ឋកិច្ច និងមូលហេតុផ្សេងទៀត ។ អចលកម្មអាចរំលស់បាន មានជាអាទិ៍ :

ក- អចលកម្មរូបី : ដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព អចលកម្មរូបី (ឬទ្រព្យសកម្មរូបី) ដែលអាចរំលស់បាន គឺទ្រព្យសកម្មរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែង តែបាត់បង់តំលៃដោយការប្រើប្រាស់ឬភាពហួសសម័យ ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ ប៉ុន្តែ រ៉ែក្នុងដីជាទ្រព្យអាចរំលស់បាន ។

ខ- អចលកម្មអរូបី : អចលកម្មអរូបីជាអាទិ៍មានដូចខាងក្រោមនេះ (ប៉ុន្តែមានអចលកម្មមួយចំនួនមិនអាច រំលស់បានទេ ដូចជាសិទ្ធិធ្វើពាណិជ្ជកម្ម សិទ្ធិប្រើប្រាស់ដីធ្លី...) :

ខ១- សោហ៊ុយបង្កើតសហគ្រាស

ខ២- សោហ៊ុយស្រាវជ្រាវ និងអភិវឌ្ឍន៍ : នេះគឺជាសោហ៊ុយនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែល សហគ្រាសបានធ្វើឡើងសំរាប់បំរើការងាររបស់ខ្លួនផ្ទាល់ ។ ដូចគ្នានឹងសោហ៊ុយបង្កើតសហគ្រាស ដែរ សោហ៊ុយនេះគឺជាចំណាយគ្មានផ្ទួរមកវិញនៅក្នុងទ្រព្យសកម្មនៃសហគ្រាសទេ ។ គណនី ទាំងឡាយដែលសំរាប់កត់ត្រានូវសោហ៊ុយទាំងនេះ គឺជាគណនីទ្រព្យសកម្មដែលគ្មានតំលៃ ពិតប្រាកដ ។ ដូច្នេះហើយក្នុងការធ្វើគណនេយ្យកម្មជាអចលកម្មនូវគំរោងការស្រាវជ្រាវ និងអភិវឌ្ឍន៍ណាមួយ គំរោងការនោះត្រូវអាចសំគាល់និងញែកដាច់តែឯងបាន និងត្រូវមាន សង្ឃឹមច្រើនក្នុងការទទួលផលខាងពាណិជ្ជកម្ម ។ សំរាប់គោលដៅនៃពបច សោហ៊ុយនេះ អាចកាត់ចេញទាំងស្រុងបានពីលទ្ធផលនៃការិយបរិច្ឆេទដែលកើតមានបន្ទុកនេះ ។

ខ៣- ប្រកាសនីយប័ត្រ ពាណិជ្ជសញ្ញា អាជ្ញាប័ណ្ណ សម្បទាន កម្មវិធីកុំព្យូទ័រ (ចំណែកដែល មានច្បាប់ការពារ)

ខ៤- មូលនិធិពាណិជ្ជកម្ម

ខ៥- អចលកម្មអរូបីផ្សេងទៀត ។

គ- អចលកម្មហិរញ្ញវត្ថុ : មូលប័ត្រ ភាគកម្ម និងអចលកម្មហិរញ្ញវត្ថុផ្សេងៗ មិនអាចរំលស់បានទេ ពីព្រោះវាមិនសឹករេចទៅតាមការប្រើប្រាស់ ឬទៅតាមពេលវេលាឡើយ ។

## ផ្នែកទី ៦.៤ : វិលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម

១- វិលស់ត្រូវធ្វើឡើងនៅលើមូលដ្ឋាននៃថ្លៃដើមនៃទ្រព្យសកម្មដែលត្រូវវិលស់ ។ ដូច្នេះទឹកប្រាក់បូកយោងនៃវិលស់ដែលបានអនុវត្តលើទ្រព្យសកម្មណាមួយ មិនអាចលើសពីថ្លៃដើមនៃទ្រព្យសកម្មនោះបានទេ ទោះបីតំលៃគិតគូរជាថ្មីធំជាងថ្លៃដើមក៏ដោយ ។ ថ្លៃដើម គឺជាតំលៃពីដំបូងនៃអចលកម្មដែលត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ។ តំលៃពីដំបូង ដែលជាតំលៃទ្រព្យសកម្ម នៅពេល និងនៅទីកន្លែង ដែលទ្រព្យសកម្មនោះត្រូវបានបញ្ចូលទៅក្នុងបេតិកភ័ណ្ឌរបស់សហគ្រាស ក៏ហៅបានដែរថា បរិយាទានប្រវត្តិសាស្ត្រ ។

២- រាល់ទ្រព្យសកម្ម : ត្រូវធ្វើគណនេយ្យកម្មនាថ្ងៃបញ្ចូលក្នុងបេតិកភ័ណ្ឌសហគ្រាស ដោយត្រូវកត់ត្រាតាមថ្លៃដើម ឬបរិយាទានប្រវត្តិសាស្ត្រ ដែលត្រូវបានកំណត់ដូចតទៅ :

ក- តាមបរិយាទានលទ្ធកម្ម ចំពោះទ្រព្យសកម្មដែលសហគ្រាសបានទិញ ក្នុងនេះ :

ក១- ត្រូវកត់ត្រាចុះបញ្ជីគណនេយ្យតាមបរិយាទានផ្ទាល់នៃការទិញ ពោលគឺតាមថ្លៃទិញ ដកចេញនូវការបញ្ចុះថ្លៃពាណិជ្ជកម្ម និងបូកបញ្ចូលនូវសោហ៊ុយបន្ទាប់បន្សំផ្សេងៗ ( ពន្ធគយនិងសោហ៊ុយជាប់ទាក់ទិនផ្សេងៗ ការដឹកជញ្ជូន សោហ៊ុយឆ្លងកាត់ និងឃ្លាំងស្តុក សោហ៊ុយទទួលអចលកម្មមានការលើកដាក់ជាដើម ធានារ៉ាប់រងលើការដឹកជញ្ជូន សោហ៊ុយទិញភាគកម្ម និងមូលប័ត្រ...) និងសោហ៊ុយផ្គុំតំលើងដែលចាំបាច់ក្នុងការដាក់ទ្រព្យសកម្មឱ្យដំណើរការ ។

ក២- សោហ៊ុយទូទៅ និងបន្ទុកហិរញ្ញវត្ថុ ដែលបានចាយដើម្បីបានអចលកម្ម មិនត្រូវគិតបញ្ចូលក្នុងបរិយាទានផ្ទាល់នៃការទិញទេ ។

ក៣- ក្នុងករណីមានការទូទាត់ពន្យារពេល តំលៃត្រូវកត់ត្រានៃទ្រព្យសកម្មត្រូវផ្អែកលើថ្លៃព្រមព្រៀង ដូច្នេះគឺពុំទាក់ទិនទៅនឹងបែបបទនៃការទូទាត់នៅថ្ងៃក្រោយឡើយ ទោះបីបំណុលមានឬគ្មានការឡើងចុះក៏ដោយ ។

ខ- តាមបរិយាទានផលិតកម្ម ចំពោះទ្រព្យសកម្មដែលសហគ្រាសបានផលិតក្នុងនេះ :

ខ១- ត្រូវបានចុះបញ្ជីគណនេយ្យតាមបរិយាទានពិតនៃផលិតកម្ម ដែលជាបរិយាទានផ្ទាល់នៃការទិញវត្ថុធាតុនិងសំភារៈផ្គត់ផ្គង់ដែលបានប្រើប្រាស់ បូកបន្ថែមនូវបន្ទុកផ្ទាល់ទាំងអស់(សោហ៊ុយបុគ្គលិក ចំណាយសេវាខាងក្រៅ) និងបន្ទុកប្រយោលនៃផលិតកម្ម ក្នុងលក្ខណៈដែលបន្ទុកប្រយោលទាំងនេះអាចបញ្ចូលបានយ៉ាងស្រួល និងសមហេតុសមផល ទៅក្នុងបរិយាទានផលិតកម្មនៃទ្រព្យសកម្មនោះ ។ បរិយាទានពិតផលិតកម្ម ត្រូវបានកំណត់បញ្ជាក់ឡើងដោយគណនេយ្យវិភាគ ឬបើគ្មានគណនេយ្យវិភាគទេ គឺដោយការគណនាស្ថិតិ ។

ខ២- បរិយាទានផលិតកម្មមិនត្រូវរួមបញ្ចូលទេនូវសោហ៊ុយនៃការស្តុក សោហ៊ុយនៃការលក់ និងការគ្រប់គ្រងទូទៅ សោហ៊ុយស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបន្ទុកហិរញ្ញវត្ថុ ។ ដោយឡែកចំពោះបរិយាទានពិតផលិតកម្មនៃទ្រព្យសកម្មសំខាន់ៗ ដូចជាការស្ថាបនាពហុរោងចក្រឧស្សាហកម្មជាដើម គឺមានការប្រាក់នៃបំណុលនានាដែលបានផ្តល់ទុនដល់ការស្ថាបនានេះ ដែរ ប៉ុន្តែសំរាប់តែដំណាក់កាលចាប់ពីពេលបើកផ្តល់ឱ្យប្រើប្រាស់ជាដំបូងនូវមូលនិធិ
រហូតដល់ពេល ធ្វើហើយរួចរាល់ប៉ុណ្ណោះ ។

គ- តាមតំលៃឧបហារិតចំពោះទ្រព្យសកម្មដែលសហគ្រាសទទួលបានពីរដ្ឋ សមូហភាព សាធារណៈ ឬ អ្នកវិនិយោគឯកជន : ក្នុងនេះត្រូវបានចុះបញ្ជីគណនេយ្យតាមតំលៃឧបហារិត ដូចដែលបានកំណត់ ក្នុងកិច្ចព្រមព្រៀងនៃឧបហារិត ។

ឃ- តាមតំលៃទីផ្សារចំពោះទ្រព្យសកម្មដែលសហគ្រាសបានមកដោយគ្មានបង់ថ្លៃ : ក្នុងនេះត្រូវបានចុះបញ្ជី គណនេយ្យតាមតំលៃទីផ្សារ ដែលជាថ្លៃមួយដែលអ្នកទិញធម្មតាម្នាក់ហ៊ានទិញទ្រព្យសកម្ម ក្នុងសភាព និងទីកន្លែងដែលទ្រព្យសកម្មនោះស្ថិតនៅ ។

៣- អាករលើផលរបរឬអាករលើតំលៃបន្ថែម ដែលបានទទួលរងក្នុងការទិញឬក្នុងការផលិតទ្រព្យសកម្ម និងដែលមិន អាចប្រមូលបានវិញ គឺជាចំណែកមួយនៃថ្លៃដើមដែលត្រូវរំលស់ ។

៤- តំលៃពីដំបូង (បរិយាទានប្រវត្តិសាស្ត្រ) មិនអាចកែប្រែបានឡើយ លើកលែងតែក្នុងការវាយតំលៃឡើងវិញដែល អាជ្ញាធរមានសមត្ថកិច្ចបានអនុញ្ញាត។ រាល់លំអៀងនៃការវាយតំលៃឡើងវិញត្រូវចាត់ទុកជាប្រាក់ចំណេញជាប់ពន្ធ និងជាមូលដ្ឋានបន្ថែមសំរាប់រំលស់បន្ត ។

## ផ្នែកទី ៦.៥ : ការធ្វើរំលស់ទ្រព្យសកម្ម

១- រំលស់ទ្រព្យសកម្មអរូបី : ដូចមានចែងក្នុងមាត្រា ១៤ នៃចសព ចំពោះទ្រព្យសកម្មអរូបី (ឬអចលកម្មអរូបី) ដែលមានអាយុកាលមានកំណត់ (ជាអាទិ៍ ប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិចំលង គំនូរប្លង់ គំរូសិទ្ធិអាជីវកម្ម...) អត្រារំលស់លើទ្រព្យសកម្មនីមួយៗ ត្រូវគណនាដោយផ្អែកលើអាយុកាលរបស់ទ្រព្យសកម្មនោះតាមវិធីរំលស់ ស្មើភាគ ។ ប្រសិនបើអាយុកាលនៃទ្រព្យសកម្មអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមអត្រា ១០ ភាគរយ នៃតំលៃទ្រព្យសកម្មអរូបី ។ ការរំលស់ទ្រព្យសកម្មអរូបី ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៦.៦ នៃប្រកាសនេះ ។

២- រំលស់ធនធានធម្មជាតិ : ដូចមានចែងក្នុងមាត្រា ១៥ នៃចសព ចំពោះធនធានធម្មជាតិមានជាអាទិ៍ ប្រេងកាត ឧស្ម័នធម្មជាតិ ... រំលស់ត្រូវបានកំណត់ដូចតទៅ :

ក- ចំណាយក្នុងការរុករកនិងអភិវឌ្ឍន៍ ក្នុងនោះមានទាំងការប្រាក់ដែលជាប់ទាក់ទងដល់ចំណាយនោះផង ត្រូវបូកបញ្ចូលក្នុងគណនីទ្រព្យសកម្មនៃធនធាននោះ

ខ- ទឹកប្រាក់រំលស់លើធនធានធម្មជាតិនីមួយៗ ដែលត្រូវផាត់ចេញនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនា ឡើងដោយយកសមតុល្យនៃគណនីធនធានធម្មជាតិ ទៅគុណនឹងផលចែករវាងបរិមាណដែលបាន ផលិតចេញពីធនធានធម្មជាតិនៅក្នុងឆ្នាំនោះ និងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយក បានពីធនធាននោះ ។

៣- រំលស់ទ្រព្យសកម្មរូបី :

ក- វិធីរំលស់ : ចំពោះទ្រព្យសកម្មរូបី មាត្រា ១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព បានអនុញ្ញាត ឱ្យប្រើវិធីរំលស់ពីរបែប គឺវិធីរំលស់ស្មើភាគ និងវិធីរំលស់ថយជាលំដាប់ ។

ខ- ថ្នាក់នៃទ្រព្យសកម្មរូបី : ទ្រព្យសកម្មរូបីទាំងអស់ត្រូវបានបែងចែកជា ៤ ថ្នាក់:

ខ១- ថ្នាក់១ រួមមាន អគារ រចនាសម្ព័ន្ធរបស់អគារ និងសំណង់ដែលជាសមាសភាគនៃអគារ នោះ ។ ទ្រព្យសកម្មនីមួយៗនៅក្នុងថ្នាក់នេះ ត្រូវធ្វើរំលស់ដោយឡែកពីគ្នា តាមវិធីរំលស់ ស្មើភាគ តាមអត្រា ៥ ភាគរយ ក្នុងមួយឆ្នាំនៃបរិយាទានលទ្ធកម្ម (ថ្លៃដើម) ។

ខ២- ថ្នាក់២ រួមមាន កុំព្យូទ័រ ប្រព័ន្ធពត៌មានអេឡិចត្រូនិច សហ្វវែរ និងបរិក្ខារទុកដាក់ទិន្នន័យ។ ទ្រព្យសកម្មនៅក្នុងថ្នាក់នេះ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់ តាមអត្រា ៥០ ភាគរយ នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ។

ខ៣- ថ្នាក់៣ រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ ។ ទ្រព្យសកម្មនៅក្នុងថ្នាក់នេះ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់ តាមអត្រា ២៥ ភាគរយ នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ។

ខ៤- ថ្នាក់៤ រួមមាន រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗទៀត ។ ទ្រព្យសកម្មនៅក្នុងថ្នាក់នេះត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់ តាមអត្រា ២០ ភាគរយ នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ។

គ- សំរាប់គោលដៅនៃពន្ធលើប្រាក់ចំណេញ ការធ្វើរំលស់ទ្រព្យក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ ត្រូវអនុវត្តតាមវិធីរំលស់ថយចុះជាលំដាប់ ។ វិធីគណនាទឹកប្រាក់រំលស់ដែលត្រូវកាត់បន្ថយសំរាប់ថ្នាក់នីមួយៗ ត្រូវអនុវត្តដូចតទៅ :

ទឹកប្រាក់រំលស់ត្រូវកាត់បន្ថយ = មូលដ្ឋានរំលស់ x អត្រារំលស់សំរាប់ថ្នាក់នីមួយៗ

មូលដ្ឋានរំលស់ = ទឹកប្រាក់ដែលមិនទាន់រំលស់នៅដើមឆ្នាំ + ទឹកប្រាក់បន្ថែមក្នុងឆ្នាំសារពើពន្ធ - ទឹកប្រាក់ដែលបានដកចេញក្នុងឆ្នាំសារពើពន្ធ

ទឹកប្រាក់ដែលមិនទាន់រំលស់នៅដើមឆ្នាំ = មូលដ្ឋានរំលស់ - ទឹកប្រាក់រំលស់ដែលត្រូវកាត់ (រួមទាំងរំលស់ឧបត្ថម្ភកធន និងរំលស់ពិសេស ដូចមានចែងក្នុងផ្នែកទី ៦.៨) ។

៤- ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ តទៅ អ្នកជាប់ពន្ធត្រូវគណនាចំនួនទឹកប្រាក់មិនទាន់រំលស់អស់នៃទ្រព្យសកម្មក្នុងថ្នាក់នីមួយៗ ដោយអនុវត្តតាមអត្រារំលស់នៃទ្រព្យក្នុងថ្នាក់នីមួយៗ ទៅតាមវិធានដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ ៣ នៃផ្នែកទីនេះ និងផ្នែកទី ៦.៦ និងផ្នែកទី ៦.៧ ។

## ផ្នែកទី ៦.៦ : រំលស់ទ្រព្យសកម្មរូបីតាមវិធីរំលស់ស្មើភាគ

១- ការរំលស់លើអគារ រចនាសម្ព័ន្ធរបស់អគារ និងសមាសភាគជាមូលដ្ឋាននៃអគារ (ទ្រព្យសកម្មថ្នាក់១ ត្រូវបានកំណត់អាយុកាលប្រើប្រាស់រយៈពេល ២០ ឆ្នាំ) ត្រូវគណនាតាមវិធីរំលស់ស្មើភាគ តាមអត្រា ៥ ភាគរយ នៃបរិយាទានលទ្ធកម្ម ។

២- ចំណុចផ្តើមរំលស់ : រំលស់ត្រូវធ្វើឡើងចាប់ពីកាលបរិច្ឆេទដែលទ្រព្យសកម្មត្រូវបានដាក់ប្រើប្រាស់ ។

៣- ចំណុចបញ្ចប់រំលស់ : តាមធម្មតាចំណុចបញ្ចប់គឺកាលបរិច្ឆេទដែលទ្រព្យសកម្មត្រូវបានរំលស់អស់(នៅពេលនោះទឹកប្រាក់រំលស់បូកយោងត្រូវស្មើនឹងថ្លៃដើមនៃទ្រព្យសកម្ម) ។ ចំណុចបញ្ចប់ក៏អាចកើតមានឡើងមុនកាលបរិច្ឆេទរំលស់អស់នេះដែរ ដូចក្នុងករណីនៃការបញ្ចេញទ្រព្យសកម្មរបស់សហគ្រាសដោយការលក់ ការដាក់ឱ្យទៅជាកាកសំណល់ ឬការបំផ្លាញចោល ។

៤- ការគណនាទឹកប្រាក់រំលស់ : ទឹកប្រាក់រំលស់ប្រចាំឆ្នាំត្រូវគណនាឡើងដោយយកថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) នៃទ្រព្យសកម្ម គុណនឹងអត្រារំលស់នៃទ្រព្យនោះ ។ ដោយឡែកសំរាប់ :

ក- ឆ្នាំចាប់ផ្តើមរំលស់ ទឹកប្រាក់រំលស់ត្រូវគិតស្មើនឹងទឹកប្រាក់រំលស់ប្រចាំឆ្នាំ (គិតមួយឆ្នាំពេញ)

ខ- ឆ្នាំបញ្ចប់រំលស់ :

ខ១- ក្នុងករណីទ្រព្យសកម្មត្រូវបានបញ្ចេញពីសហគ្រាស ទឹកប្រាក់រំលស់ត្រូវស្មើនឹងសូន្យ

១២- ក្នុងករណីទ្រព្យសកម្មបានដល់ចុងបញ្ចប់អាយុកាលប្រើប្រាស់របស់វា ទឹកប្រាក់រំលស់ត្រូវស្មើនឹងសមតុល្យមិនទាន់រំលស់អស់នៃគណនីទ្រព្យសកម្មនៃទ្រព្យត្រូវរំលស់ ។ ប៉ុន្តែប្រសិនបើសមតុល្យនេះធំជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ ( ឧទាហរណ៍ មានការកែលំអជាប់លាប់ ) ទ្រព្យសកម្មជាប់ទាក់ទិនត្រូវបានចាត់ទុកថាបានកើនអាយុកាលប្រើប្រាស់ និងត្រូវបានធ្វើរំលស់ជាបន្តទៀតរហូតដល់សមតុល្យនេះតូចជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ ទើបធ្វើរំលស់ឱ្យអស់ដើម្បីបញ្ចប់រំលស់តែម្តង ។

## ផ្នែកទី ៦.៧ : រំលស់ទ្រព្យសកម្មរូបីតាមវិធីរំលស់ថយជាលំដាប់

១- ចំពោះការរំលស់ទ្រព្យសកម្មរូបីតាមវិធីរំលស់ថយជាលំដាប់ សហគ្រាសត្រូវអនុវត្តតាមសេចក្តីចែងនៅក្នុងកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៣ នៃផ្នែកទី ៦.៦ នៃប្រកាសនេះ។

២- សំរាប់ទ្រព្យសកម្មក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ សហគ្រាសត្រូវបង្កើតគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាសំរាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្ម ហើយសហគ្រាសត្រូវកត់ត្រាតំលៃមិនទាន់រំលស់អស់នៃទ្រព្យសកម្មទាំងអស់ក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នានៃថ្នាក់នីមួយៗនោះ ។

៣- ការកត់ត្រាបញ្ចូលទ្រព្យសកម្ម ទៅក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នា :

ក- សំរាប់ទ្រព្យសកម្មទើបដាក់ប្រើប្រាស់ : សំរាប់គោលដៅនៃការគណនាទឹកប្រាក់រំលស់អាចកាត់កងបាន បើសិនទ្រព្យសកម្មណាមួយទើបតែត្រូវបានដាក់ប្រើប្រាស់នៅក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវកត់បញ្ចូលទៅក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នា
នាថ្ងៃដាក់ប្រើប្រាស់ទ្រព្យសកម្មនោះនូវសមតុល្យនៃគណនីទ្រព្យ សកម្មនៃទ្រព្យដែលត្រូវបញ្ចូល ។

ខ- សំរាប់ទ្រព្យសកម្មដែលបានធ្វើរំលស់ហើយតែមិនទាន់រំលស់អស់នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ : សហគ្រាសត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មទៅតាមផ្នែកទី ៦.៥ នៃប្រកាសនេះ ។ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤ សហគ្រាសត្រូវកត់ត្រាទ្រព្យសកម្មនោះទៅក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាដោយកត់ត្រាតំលៃទឹកប្រាក់មិនទាន់រំលស់អស់នៃទ្រព្យសកម្មដូចថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៣ ។

៤- រំលស់អាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាឡើងដោយយកសមតុល្យនៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នានៅចុងឆ្នាំនោះ ពោលគឺមូលដ្ឋានរំលស់ដូចបានកំណត់ក្នុងវាក្យខ័ណ្ឌ គ នៃកថាខ័ណ្ឌ ៣ នៃផ្នែក ៦.៥ នៃប្រកាសនេះ (ក្រោយបានធ្វើការកែតម្រូវសព្វគ្រប់ហើយចំពោះគណនីរួមបញ្ចូលគ្នានោះ) គុណនឹងអត្រារំលស់សំរាប់ថ្នាក់ទ្រព្យសកម្មនោះ ។ តួលេខចាប់ផ្តើមនៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាសំរាប់ដើមឆ្នាំបន្ទាប់ គឺស្មើនឹងសមតុល្យចុងឆ្នាំទើបកន្លងទៅនៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នានេះ ដកនឹងរំលស់ដែលត្រូវបានអនុញ្ញាត (រួមទាំងរំលស់ឧបត្ថម្ភកធន និងរំលស់ពិសេស ដូចមានចែងក្នុងផ្នែកទី ៦.៨) ក្នុងឆ្នាំទើបកន្លងទៅសំរាប់គណនីទ្រព្យសកម្មរួមបញ្ចូលគ្នានេះ ។

៥- នៅក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើទ្រព្យណាមួយនៅក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃផ្នែកនេះ ត្រូវបានបញ្ចេញពីអង្គភាពអាជីវកម្ម សហគ្រាសត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មនៃទ្រព្យត្រូវបានបញ្ចេញនូវចំណូលចំណាយនានាដែលជាប់ទាក់ទិននឹងការបញ្ចេញនេះ រួចហើយកត់ត្រាផ្ទេរចំណូលចំណាយទាំងនេះទៅក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នា ។ ប្រសិនបើការការកត់ត្រាបែបនេះធ្វើឱ្យសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាក្លាយជាអវិជ្ជមាន សហគ្រាសត្រូវកត់ត្រាជាប្រាក់ចំណេញជាប់ពន្ធនូវទឹកប្រាក់ស្មើនឹងសមតុល្យអវិជ្ជមាននេះ ហើយសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវកែតម្រូវមកសូន្យវិញ ។

៦- នៅចុងឆ្នាំជាប់ពន្ធ ប្រសិនបើក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាណាមួយដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃផ្នែកនេះ ជាក់ស្ដែងគ្មាននៅសល់ទ្រព្យសកម្មអ្វីទៀតទេនោះ សមតុល្យវិជ្ជមាននៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នានោះត្រូវបានកត់ត្រាជាការខាតបង់អាចកាត់កងបាន ហើយសមតុល្យនៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវបានកែតម្រូវមកសូន្យវិញ ។

## ផ្នែកទី ៦.៨ : រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស

១- ទោះបីនៅចុងការិយបរិច្ឆេទនីមួយៗ សហគ្រាសត្រូវចាត់ចែងធ្វើជំរឿន និងវាយតំលៃទៅតាមតំលៃពិតបច្ចុប្បន្ន នូវទ្រព្យសកម្មទាំងអស់របស់ខ្លួនក៏ដោយ (ធ្វើសារពើភ័ណ្ឌលំអិត) ជាគោលការណ៍ សហគ្រាសពុំអាចធ្វើការកែតម្រូវអ្វីទៅលើតួលេខតំលៃនៃទ្រព្យទាំងនេះសំរាប់គោលដៅខាងពន្ធដារបានទេ ពីព្រោះ :

ក- ប្រសិនបើតំលៃកត់ត្រាក្នុងតារាងតុល្យការទាបជាងតំលៃក្នុងបញ្ជីសារពើភ័ណ្ឌ ស្របតាមគោលការណ៍ប្រុងប្រយ័ត្ន តំលៃកត់ត្រាក្នុងតារាងតុល្យការនេះត្រូវរក្សាទុកនៅដដែល លើកលែងតែក្នុងករណីដែលច្បាប់បានកំណត់ ។

ខ- ប្រសិនបើតំលៃកត់ត្រាក្នុងតារាងតុល្យការខ្ពស់ជាងតំលៃក្នុងបញ្ជីសារពើភ័ណ្ឌ តំលៃកត់ត្រាក្នុងតារាងតុល្យការនេះ ក៏ត្រូវរក្សាទុកនៅដដែលដែរ (ច្បាប់ស្ដីពីសារពើពន្ធមិនអនុញ្ញាតឱ្យកាត់កងសវិធានធនទេ) លើកលែងតែក្នុងករណីប្រែប្រួលធំដុំក្នុងលក្ខខ័ណ្ឌប្រើប្រាស់អចលកម្ម ករណីទ្រព្យសកម្មត្រូវបានបញ្ចេញពីសហគ្រាស និងបញ្ចេញពីបញ្ជីគណនេយ្យ និងករណីដែលច្បាប់បានកំណត់ ។

២- នៅក្នុងការិយបរិច្ឆេទនីមួយៗ សហគ្រាសត្រូវធ្វើនូវរាល់ការរំលស់សំរាប់ធានាការសឹករេចនៅក្នុងការិយបរិច្ឆេទនោះ ទោះបីក្នុងការិយបរិច្ឆេទនោះសហគ្រាសគ្មានចំណេញ ឬមានចំណេញមិនគ្រប់គ្រាន់ក៏ដោយ ។ ក្នុងនេះ :

ក- ដើម្បីអាចកាត់កងបាន រំលស់ត្រូវតែបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់សហគ្រាសមុនការផុតរយៈពេលដែលសហគ្រាសត្រូវដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ខ- សហគ្រាសមិនត្រូវបានអនុញ្ញាតឱ្យលើកពេលរំលស់ទ្រព្យសកម្មណាមួយរបស់ខ្លួនទេ (ឧទាហរណ៍ ក្នុងពេលមានការខាតបង់)

គ- ប្រាក់រំលស់ឬភាគនៃប្រាក់រំលស់សំរាប់ការិយបរិច្ឆេទណាមួយដែលពុំបានចុះបញ្ជីគណនេយ្យនៅពេលបិទការិយបរិច្ឆេទនោះ គឺត្រូវខាតបង់ជាស្ថាពរដោយពុំអាចយកទៅកាត់កងក្នុងលទ្ធផលការិយបរិច្ឆេទផ្សេងទៀតបានឡើយ ។

៣- ការបាត់បង់សិទ្ធិក្នុងការកាត់កងនូវ ប្រាក់រំលស់ ឬភាគនៃប្រាក់រំលស់ ដែលមិនបានធ្វើគណនេយ្យកម្មក្នុងការិយបរិច្ឆេទត្រឹមត្រូវ បណ្ដាលឱ្យមានវិបាកដូចតទៅ :

ក- រំលស់លើកពេល មិនអាចយកមកកាត់កងក្នុងការគណនាប្រាក់ចំណេញជាប់ពន្ធបានឡើយ ទោះបីនៅក្រោយអាយុកាលប្រើប្រាស់របស់ទ្រព្យនោះក៏ដោយ

ខ- រំលស់ដែលត្រូវបានបដិសេធចេញពីបន្ទុកអាចកាត់កងបានដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវបានចាត់ទុកថាត្រូវបានធ្វើឡើងជាប្រក្រតីសំរាប់ការគណនាតំលៃលើស ឬតំលៃខ្វះនៃការលក់ ។

៤- ឧទាហរណ៍ :

ក- សហគ្រាសមួយបានទិញឃ្លាំងមួយនៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៤ ដែលមានថ្លៃដើម ៤០.០០០.០០០ រៀល ។

ខ- ឃ្លាំងនេះមានអាយុកាលប្រើប្រាស់ ២០ ឆ្នាំ និងត្រូវបានធ្វើរំលស់តាមវិធីស្មើភាគជាទៀងទាត់នៅគ្រប់ពេលបិទការិយបរិច្ឆេទ លើកលែងតែនៅឆ្នាំ ២០០៦ ដោយសារតែនៅការិយបរិច្ឆេទនោះសហគ្រាសមានការខាតបង់យ៉ាងធ្ងន់ធ្ងរ ។

គ- ឃ្លាំងត្រូវបានលក់ចេញនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០២២ បានប្រាក់ ១៥.០០០.០០០ រៀល ។

ឃ- ស្ថានភាពទាក់ទិននឹងការគណនារំលស់ តំលៃលើសឬតំលៃខ្វះ នៃឃ្លាំងនេះមានដូចតទៅ :

ឃ១- អត្រារំលស់ : ៥ ភាគរយ (ឃ្លាំងមានអាយុកាលប្រើប្រាស់ ២០ ឆ្នាំ ជាទ្រព្យសកម្មរូបីថ្នាក់ ១)

ឃ២- ការរំលស់បានធ្វើគណនេយ្យកម្ម :

- រំលស់ឆ្នាំ ២០០៤ = ៤០.០០០.០០០ រៀល x ៥% = ២.០០០.០០០ រៀល
  (ឆ្នាំចាប់ផ្តើមរំលស់គិតស្មើនឹងរំលស់ប្រចាំឆ្នាំ)
- រំលស់ឆ្នាំ ២០០៥ = ៤០.០០០.០០០ រៀល x ៥% = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០០៦ = ០ រៀល
- រំលស់ឆ្នាំ ២០០៧ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០០៨ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០០៩ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១០ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១១ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១២ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៣ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៤ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៥ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៦ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៧ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៨ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០១៩ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០២០ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០២១ = ២.០០០.០០០ រៀល
- រំលស់ឆ្នាំ ២០២២ = ០ រៀល

(ឆ្នាំបញ្ចេញទ្រព្យសកម្ម រំលស់គិតស្មើសូន្យ)

ឃ៣- តំលៃពិតគណនេយ្យ = ថ្លៃដើម - រំលស់បានអនុវត្ត

- ថ្លៃដើម = ៤០.០០០.០០០ រៀល
- រំលស់បានអនុវត្ត = ៣៤.០០០.០០០ រៀល
- តំលៃពិតគណនេយ្យ = ៦.០០០.០០០ រៀល

ឃ៤- តំលៃលើស = ថ្លៃលក់ - តំលៃពិតគណនេយ្យ

- ថ្លៃលក់ = ១៥.០០០.០០០ រៀល
- តំលៃពិតគណនេយ្យ = ៦.០០០.០០០ រៀល

- តំលៃលើស = ៩.០០០.០០០ រៀល

ង- សំរាប់គោលដៅខាងពន្ធដារ តំលៃលើសនេះត្រូវតែបន្ថែមទឹកប្រាក់រំលស់លើកពេលដោយខុសគឺ ២.០០០.០០០ រៀល នៅឆ្នាំ ២០០៦ ។ ដូច្នេះតំលៃលើសជាប់ពន្ធ គិតតាមច្បាប់ស្តីពីសារពើពន្ធគឺ ១១.០០០.០០០ រៀល (៩.០០០.០០០ រៀល + ២.០០០.០០០ រៀល) ។ ដើម្បីកំណត់លទ្ធផលជាប់ពន្ធ សហគ្រាសត្រូវគិតបញ្ចូលក្នុងលទ្ធផលគណនេយ្យនូវទឹកប្រាក់ ២.០០០.០០០ រៀល (ទឹកប្រាក់រំលស់លើកពេលមិនប្រក្រតី) ។

ច- ករណីនៃតំលៃខ្វះ :

ច១- ប្រសិនបើឃ្លាំងលក់បានថ្លៃ ៣.០០០.០០០ រៀលវិញ តំលៃខ្វះ គឺ :

- ថ្លៃលក់ = ៣.០០០.០០០ រៀល
- តំលៃពិតគណនេយ្យ = <u>៦.០០០.០០០</u> រៀល
- តំលៃខ្វះ = ៣.០០០.០០០ រៀល

ច២- តំលៃខ្វះដែលអាចកាត់កងបានសំរាប់គោលដៅនៃពបច គឺមានតែ ១.០០០.០០០ រៀល ប៉ុណ្ណោះ (៣.០០០.០០០ រៀល - ២.០០០.០០០ រៀល) ដោយសារការគិតបញ្ចូលទៅក្នុងរំលស់ដែលបានកត់ត្រាក្នុងបញ₡គណនេយ្យនូវទឹកប្រាក់រំលស់នៃឆ្នាំ ២០០៦ ដែលជារំលស់លើក ពេលខុស ។

ឆ- សំរាប់ការគណនាតំលៃលើស ឬតំលៃខ្វះនៃទ្រព្យសកម្ម ការរំលស់លើកពេលដោយខុសត្រូវបានចាត់ទុកដូចជាបានកាត់កងរួចហើយពីលទ្ធផលជាប់ពន្ធរបស់សហគ្រាស ។ នៅក្នុងឧទាហរណ៍នេះ ការកំណត់តំលៃលើស ឬតំលៃខ្វះ គឺត្រូវបានធ្វើឡើងដោយយកមកគិតគូរនូវទឹកប្រាក់រំលស់បូកយោង ៣៦.០០០.០០០ រៀល ( ៣៤.០០០.០០០ រៀល + ២.០០០.០០០ រៀល ) ជំនួសឱ្យទឹកប្រាក់ដែលបានធ្វើគណនេយ្យកម្ម ( ៣៤.០០០.០០០ រៀល ) ។

៥- ការធ្វើគណនេយ្យកម្ម :

ក- ឆ្លងតាមឧទាហរណ៍ក្នុងកថាខ័ណ្ឌ ៤ នៃផ្នែកនេះ គេឃើញថាសហគ្រាសត្រូវជាប់ពន្ធលើប្រាក់ចំណេញចំពោះទឹកប្រាក់រំលស់ដែលបានលើកពេលដោយខុស ។ សំរាប់ការអនុវត្តជាក់ស្តែងសហគ្រាសត្រូវធ្វើគណនេយ្យកម្ម (ពិសេសកត់ត្រាចូលគណនីរំលស់ទ្រព្យសកម្ម ឬគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាជាប់ទាក់ទិន) នូវទឹកប្រាក់រំលស់លើកពេលដោយខុសនៅក្នុងថ្ងៃដែលរកឃើញកំហុស ។ នៅចុងឆ្នាំជាប់ពន្ធដែលមានការកែតម្រូវ សហគ្រាសត្រូវគិតបញ្ចូលមកវិញនូវទឹកប្រាក់កត់ត្រាកែតម្រូវនូវរំលស់លើកពេលខុសនេះ ។

ខ- ចំពោះទឹកប្រាក់រំលស់ឬទឹកប្រាក់សំវិធានធនដែលបង្កើតឡើងដោយខុសគោលការណ៍ ឬដែលមានទឹកប្រាក់លើសពីកំរិតអនុញ្ញាត សហគ្រាសត្រូវកត់ត្រាកែតម្រូវទឹកប្រាក់រំលស់ឬសំវិធានធនដែលខុសនេះនៅថ្ងៃរកឃើញកំហុស ។

គ- សំរាប់ករណីដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ សហគ្រាសត្រូវដាក់លិខិតប្រកាសសារពើពន្ធកែតម្រូវ ដូចមានចែងក្នុងកថាខ័ណ្ឌ៣ នៃមាត្រា១១៧ នៃ ចសព ។

ឃ- នៅក្រោយពេលដែលសហគ្រាសបានអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌ ក វាក្យខ័ណ្ឌ ខ និងវាក្យខ័ណ្ឌ គ នៃកថាខ័ណ្ឌនេះរួចហើយ សហគ្រាសអាចធ្វើរំលស់ឬសំវិធានធនជាបន្តទៀតទៅតាមគោលការណ៍ដែលច្បាប់ស្តីពីសារពើពន្ធបានអនុញ្ញាត ។

## ផ្នែកទី ៦.៩ : រំលស់ពិសេស

១ - រំលស់ពិសេសគឺជាចំនួនដែលអាចកាត់កងក្នុងឆ្នាំទី ១ នៃការទិញ ឬនាពេលក្រោយមកទៀតនៅឆ្នាំទី ១ នៃការដាក់ប្រើប្រាស់ទ្រព្យរូបី ដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងកថាខ័ណ្ឌ២ ខាងក្រោមនេះ ។ ចំនួនដែលអាចកាត់កងបាននេះស្មើនឹង ៤០ ភាគរយ នៃតម្លៃមូលធននៃទ្រព្យរូបីថ្មី ឬទ្រព្យរូបីប្រើប្រាស់រួច ដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្មនិងការកែច្នៃ ។ រំលស់ពិសេសនឹងកាត់បន្ថយតំលៃមូលធននៃទ្រព្យរូបី ដែលអាចប្រើប្រាស់សំរាប់ការធ្វើរំលស់ជាធម្មតា ។

២- រំលស់ពិសេសនៃទ្រព្យរូបី នឹងត្រូវបានយកមកកាត់កងដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឆ្នាំសារពើពន្ធ ប្រសិនបើអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។

៣- ទ្រព្យរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេស ត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤ ឆ្នាំសារពើពន្ធ បន្ទាប់ពីឆ្នាំសារពើពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង ។ ប្រសិនបើទ្រព្យរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កង កាត់បន្ថយដោយចំនួនមួយស្មើនឹង ២ ភាគរយ នៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ឱ្យប្រើប្រាស់ ។ ចំនួននេះនឹងមិនប៉ះពាល់តម្លៃពិតគណនេយ្យនៃទ្រព្យរូបី សម្រាប់ការកំណត់ផលចំណេញពីមូលធនជាប់ពន្ធ តាមមាត្រា ៧ នៃចសព ។

៤- ឧទាហរណ៍ទី ១ :

ឧបមាថានៅដើមឆ្នាំជាប់ពន្ធ ២០០៤ អ្នកជាប់ពន្ធម្នាក់មានម៉ាស៊ីនដេរ ៣ គ្រឿងសំរាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់គាត់ ។ សំរាប់គោលដៅនៃពបច ម៉ាស៊ីនដេរស្ថិតក្នុងទ្រព្យសកម្មថ្នាក់ ៤ ដែលបានកត់ត្រាក្នុងរបាយការណ៍គណនេយ្យ មានតំលៃ ១.៦០០.០០០ រៀល ។ នៅឆ្នាំ ២០០៤ គាត់បានលក់ម៉ាស៊ីនដេរ មួយគ្រឿងបានប្រាក់ ៥០០.០០០ រៀល តែគាត់បានទិញម៉ាស៊ីនដេរគំរូថ្មីមួយគ្រឿងមកវិញមានតំលៃ ២.០០០.០០០ រៀល ។ អ្នកជាប់ពន្ធនោះត្រូវបានអនុញ្ញាតផ្តល់រំលស់ពិសេស ៤០ ភាគរយ សំរាប់ដំណើរការវិនិយោគរបស់គាត់ ។

មូលដ្ឋានរំលស់សំរាប់ឆ្នាំ ២០០៤ ត្រូវគណនាដូចតទៅ :

- តំលៃមិនទាន់រំលស់នៃថ្នាក់នៅដើមឆ្នាំ ២០០៤ (០១ មករា ២០០៤)............១.៦០០.០០០ រៀល
- ដកចេញចំណូលដែលបានមកពីការលក់ម៉ាស៊ីនដេរចាស់..................................៥០០.០០០ រៀល
- បូកបន្ថែមតំលៃម៉ាស៊ីនដេរថ្មីដែលបានទិញចូល..........................................២.០០០.០០០ រៀល
- ដកចេញ រំលស់ពិសេស (២.០០០.០០០ x ៤០%).......................................៨០០.០០០ រៀល

មូលដ្ឋានរំលស់ធម្មតាសំរាប់ឆ្នាំ ២០០៤ ...........................................................២.៣០០.០០០ រៀល

ទឹកប្រាក់រំលស់សំរាប់ឆ្នាំជាប់ពន្ធ ២០០៤ មានដូចខាងក្រោម :

- រំលស់ពិសេស (២.០០០.០០០ x ៤០%)...........................................................៨០០.០០០ រៀល
- រំលស់ធម្មតាសំរាប់ថ្នាក់៤ (២.៣០០.០០០ x ២០%).........................................៤៦០.០០០ រៀល

ទឹកប្រាក់រំលស់សរុបសំរាប់ឆ្នាំ ២០០៤ ...........................................................១.២៦០.០០០ រៀល

ទឹកប្រាក់មិនទាន់រំលស់នៅថ្ងៃទី ៣១ ធ្នូ ២០០៤ (តំលៃមិនផ្លាស់ប្តូរសំរាប់ថ្ងៃទី ០១ មករា ២០០៥) គឺស្មើនឹង ១.៨៤០.០០០ រៀល ( គឺស្មើ ២.៣០០.០០០ រៀល - ៤៦០.០០០ រៀល ) ព្រោះរំលស់ពិសេសបានកាត់ចេញរួចហើយ ។

៥- ឧទាហរណ៍ទី ២:

ឧបមាថានៅឆ្នាំ ២០០៦ អ្នកជាប់ពន្ធនៅក្នុងឧទាហរណ៍ទី ១ លក់ម៉ាស៊ីនដេរដែលបានទិញក្នុងឆ្នាំ ២០០៤ (បន្ទាប់ពីដាក់ប្រើបាន ១៦ ខែ)។ ប្រាក់ចំណេញជាប់ពន្ធសំរាប់ឆ្នាំ ២០០៦ របស់គាត់ត្រូវបានកើនឡើងដោយសារការកែតម្រូវការកាត់កងរំលស់ពិសេសមកវិញនូវចំនួនទឹកប្រាក់ ២% សំរាប់ខែនីមួយៗដែលទ្រព្យសកម្មបានដាក់ប្រើ ។

ប្រាក់ចំណេញជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសំរាប់ឆ្នាំ ២០០៦ ត្រូវបានគណនាដូចតទៅ:

- រំលស់ពិសេស ( ២.០០០.០០០ x ៤០%)..................................................៨០០.០០០ រៀល
- ដកចេញការកែតម្រូវសំរាប់រយៈពេលដែលទ្រព្យសកម្មបានប្រើ (៨០០.០០០ រៀល x ២%) ១៦ខែ ...........................................................................................................២៥៦.០០០ រៀល
- ប្រាក់ចំណេញជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសំរាប់ឆ្នាំ ២០០៦ គឺ.....................៥៤៤.០០០ រៀល

## ជំពូកទី៧
## វិធានទូទៅស្តីពីតំលៃលើស និងតំលៃខ្វះនៃទ្រព្យសកម្ម

### ផ្នែកទី ៧.១ : គោលការណ៍

១- ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទ ដែលសហគ្រាសសំរេចបាន រួមបញ្ចូលទាំងតំលៃលើសបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្ម ក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ។

២- តំលៃលើស និងតំលៃខ្វះ គឺជាចំនួនលំអៀងរវាងតំលៃពិតប្រាកដនៃទ្រព្យសកម្ម និងតំលៃពិតគណនេយ្យ (ពោលគឺតំលៃក្រោយកាត់រំលស់រួច) ។

៣- តំលៃលើស និងតំលៃខ្វះ ពុំមានឥទ្ធិពលខាងសារពើពន្ធឡើយ ដរាបណាតំលៃនេះមិនទាន់ស្តែងចេញជាចលនាជាក់ស្តែងនៃទុន ។

៤- តំលៃលើសនិងតំលៃខ្វះ មានពីរប្រភេទ :

ក- តំលៃលើសឬតំលៃខ្វះដែលសំរេចបាន : តំលៃនេះកើតមានឡើងតាមការបញ្ចេញអចលកម្មណាមួយ ។ ការបញ្ចេញនេះអាចជាការលក់ (ករណីភាគច្រើន) ការធ្វើឧបហារិតទៅក្នុងសហគ្រាសមួយទៀត ការដោះដូរ ការបែងចែក ការផ្តល់ជាអំណោយ ការយកវិញរបស់ម្ចាស់សហគ្រាសឯកបុគ្គល (ទ្រព្យសកម្មផ្ទេរចូលបេតិកភ័ណ្ឌឯកជន) នាពេលកំពុងធ្វើអាជីវកម្ម ឬនាពេលបញ្ចប់អាជីវកម្ម (បញ្ឈប់សកម្មភាព ឬមរណៈភាពរបស់ម្ចាស់សហគ្រាស) ការរុះរើចេញ ការបំផ្លាញ ការឈប់លែងប្រើប្រាស់...។ ការបញ្ចេញនេះអាចជាអំពើដោយចេតនារបស់ម្ចាស់សហគ្រាសឬអ្នកគ្រប់គ្រងសហគ្រាស ឬជាវិបាកនៃព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ពួកគេ ដូចជាការដកហូតតាមផ្លូវច្បាប់ ឬមហន្តរាយ... ។

ខ- តំលៃលើសបានកត់ត្រា : តំលៃនេះកើតមានឡើងបន្ទាប់ពីមានការកត់ត្រាក្នុងបញ្ជីគណនេយ្យនូវតំលៃបច្ចុប្បន្នរបស់អចលកម្មមួយជំនួសឱ្យតំលៃចាស់របស់ទ្រព្យនេះ ។ ដូច្នេះវាជាតំលៃលើសគណនេយ្យសុទ្ធសាធ ។ ក្នុងន័យនេះ តំលៃលើសដែលផុសចេញពីការវាយតំលៃសារជាថ្មី ដោយគ្មានច្បាប់អនុញ្ញាតនូវអចលកម្ម ត្រូវក្លាយជាប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្ម ។

គ- ច្បាប់ស្តីពីសារពើពន្ធមិនអនុញ្ញាតឱ្យកត់ត្រាតំលៃខ្វះក្រោមរូបភាពជាសវិធានធនទេ ។ តំលៃខ្វះអាចកត់ត្រាបាន តែក្នុងករណីនៃតំលៃខ្វះសំរេចបានដែលមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះប៉ុណ្ណោះ ។

៥- ទោះបីសំរេចបាននៅក្នុងអំឡុង ឬនៅពេលបញ្ចប់អាជីវកម្មក្តី តំលៃលើស ឬតំលៃខ្វះ បង្កើតបានជាប្រាក់ចំណេញ ឬប្រាក់ខាតរបស់សហគ្រាសដែលត្រូវជាប់ពន្ធ ឬត្រូវកាត់កង ។

## ផ្នែកទី ៧.២ : ការគណនាតំលៃលើស ឬតំលៃខ្វះ

១- ការលក់អចលកម្មណាមួយបង្កើតបាននូវតំលៃលើស កាលបើថ្លៃលក់មានតួលេខធំជាងតំលៃពិតគណនេយ្យនៃទ្រព្យដែលបានលក់នោះ ។

២- តំលៃពិត :

ក- ចំពោះអចលកម្មដែលត្រូវបានរំលស់តាមវិធីរំលស់ស្មើភាគ : តំលៃពិតគណនេយ្យ គឺជាសមតុល្យនៃគណនីទ្រព្យសកម្មនៃអចលកម្មជាប់ទាក់ទិន ដកនឹងទឹកប្រាក់រំលស់ ( រួមទាំងរំលស់ឧបត្ថម្ភកធន និងរំលស់ពិសេស ដូចមានចែងក្នុងផ្នែកទី ៦.៩ ) ដែលបានអនុវត្តចំពោះអចលកម្មនោះ ។

ខ- ចំពោះអចលកម្មដែលត្រូវបានរំលស់តាមវិធីរំលស់ថយជាលំដាប់ : សំរាប់គោលដៅនៃពបច ក្នុងករណីនៃការបញ្ចេញអចលកម្មប្រភេទនេះណាមួយ សហគ្រាសមិនត្រូវគណនាតំលៃពិតគណនេយ្យ ឬតំលៃលើសឬតំលៃខ្វះ សំរាប់ទ្រព្យនោះដោយផ្ទាល់ទេ ។ ក្នុងករណីនេះ សហគ្រាសត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៦.៧ នៃប្រកាសនេះ ហើយតំលៃលើស ឬតំលៃខ្វះនឹងត្រូវស្តែងចេញសំរាប់គណនីទ្រព្យសកម្មរួមបញ្ចូលគ្នានីមួយៗ តែម្តង ។

៣- ឧទាហរណ៍ :

ក- សហគ្រាសបានទិញទ្រព្យសកម្មថ្នាក់ ១ មួយថ្លៃ ២.៥០០.០០០ រៀល និងបានលក់ទ្រព្យនេះចេញវិញក្នុងតំលៃ ១.៨០០.០០០ រៀល ក្រោយដែលសហគ្រាសរំលស់ទ្រព្យនេះតាមវិធីរំលស់ស្មើភាគបានត្រឹមទឹកប្រាក់ ១.៥០០.០០០ រៀល ។

ខ- ការលក់នេះនាំឱ្យមានតំលៃលើសស្មើនឹង :

| | |
|---|---|
| - ថ្លៃលក់ | = ១.៨០០.០០០ រៀល |
| - តំលៃពិតគណនេយ្យ ២.៥០០.០០០ រៀល - ១.៥០០.០០០ រៀល | = ១.០០០.០០០ រៀល |
| - តំលៃលើស ១.៨០០.០០០ រៀល - ១.០០០.០០០ រៀល | = ៨០០.០០០ រៀល |

## ផ្នែកទី ៧.៣ : ករណីពិសេស

១- ដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រា ១៩ នៃចសព ការខាតបង់លើការលក់ ឬដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ ឬប្រយោលក្តី រវាងបុគ្គលទាក់ទិន គឺមិនអាចកាត់កងបានទេ ។ ពាក្យបុគ្គលទាក់ទិនសំដៅដល់:

ក- សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ- សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ។ ពាក្យ គ្រប់គ្រង មានន័យថា មានកម្មសិទ្ធិចាប់ពី ៥១ ភាគរយ ឡើងទៅលើតំលៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវ

កម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ ។

២- ឧបហារិតចូលក្រុមហ៊ុន : ការគណនានូវតំលៃលើសឬតំលៃខ្វះ ត្រូវធ្វើឡើងដោយផ្តើមចេញពីតំលៃពិតប្រាកដនៃសន្លឹកហ៊ុនឬភាគហ៊ុន ដែលបានប្រគល់សំរាប់ជាថ្នូរនៃឧបហារិត ។ តាមគោលការណ៍ តំលៃពិតនៃសន្លឹកហ៊ុនឬភាគហ៊ុននេះ ត្រូវស្មើនឹងតំលៃប៉ាន់ស្មាននៃទ្រព្យសកម្មដែលបានយកមកបញ្ចូលដោយឧបហារិតទៅក្នុងបញ្ជីគណនេយ្យរបស់សហគ្រាសដែលទទួលឧបហារិត ។

៣- ការដោះដូរ : ការដោះដូរ ទោះបីពុំមានការបន្ថែមប្រាក់ក៏ដោយ ត្រូវបានចាត់ទុកជាប្រតិបត្តិការលក់ដែលបន្តដោយប្រតិបត្តិការទិញ ។ តំលៃលើសឬតំលៃខ្វះ គឺស្មើនឹងទឹកប្រាក់លំអៀងរវាងតំលៃទីផ្សារនៃទ្រព្យសកម្មដែលបានទទួលក្នុងការដោះដូរ និងតំលៃពិតគណនេយ្យនៃទ្រព្យសកម្មដែលបានប្រគល់ឱ្យគេ ។ ការដោះដូរ ត្រូវជាប់ពន្ធក្នុងការិយបរិច្ឆេទដែលកើតមានការដោះដូរនេះ ។

៤- ចំពោះ អំណោយ មរណៈភាពនៃម្ចាស់សហគ្រាស ការដកយកវិញនូវទ្រព្យពីទ្រព្យសកម្មរបស់សហគ្រាស ការបញ្ឈប់សកម្មភាព : ប្រតិបត្តិការឬព្រឹត្តិការណ៍ទាំងនេះធ្វើឱ្យកើតមានឡើងនូវតំលៃលើសឬតំលៃខ្វះ ដែលត្រូវបានកំណត់តាមតំលៃទីផ្សារនៃទ្រព្យសកម្មនាថ្ងៃធ្វើអំណោយ ឬនាថ្ងៃមរណៈភាព ឬនាថ្ងៃដកយកវិញ ឬនាថ្ងៃបញ្ឈប់សកម្មភាព ។

# ជំពូកទី៨

# ពន្ធកាត់ទុក

## ផ្នែកទី ៨.១ : គោលការណ៍

១- ស្របតាមមាត្រា ២៥ថ្មី និងមាត្រា ២៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ពន្ធទាក់ទិននឹងប្រាក់ចំណូលដូចមានចែងក្នុងផ្នែកទី ៨.២ និងផ្នែកទី ៨.៣ នៃប្រកាសនេះ ត្រូវបានប្រមូលចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤ តាមវិធីកាត់ទុកមុនពេលបើក ឬមុនពេលទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ដោយអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ។ ពន្ធនេះ ហៅថាពន្ធកាត់ទុក ។

២- សំរាប់គោលដៅនៃពន្ធកាត់ទុក ចំណាយណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុក ដែលបានកត់ត្រាជាចំណាយក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់ ។

## ផ្នែកទី ៨.២ : ពន្ធកាត់ទុកលើការទូទាត់ទៅឱ្យនិវាសនជន

១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបើក ឬទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់បុគ្គលនិវាសនជន ត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ :

ក- អត្រា ១៥ ភាគរយ ចំពោះប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល ។ សំរាប់គោលដៅនៃពន្ធកាត់ទុកប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល គឺសំដៅដល់ប្រាក់ចំណូលពីរាល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ក្រៅតែពីការផលិតនិងការលក់ទំនិញ ភតិសន្យា ការជួល ការលក់នូវទ្រព្យសម្បត្តិ និងក្រៅពីសកម្មភាពបំរើការងារដូចមានចែងក្នុងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្សលេខ ៣៩៦ ប្រក.សហវ.ពដ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រាក់ចំណូលនេះមានជាអាទិ៍ ប្រាក់ចំណូលពីកំរៃជើងសារ

ឬដើងសារជំនួញ ប្រាក់ចំណូលពីសកម្មភាពដឹកជញ្ជូន ជួសជុល សាងសង់ គ្រប់គ្រងពិគ្រោះយោបល់ ប្រាក់ចំណូលពីសេវាប្រហាក់ប្រហែល ដូចជាសេវាបច្ចេកទេស វិទ្យាសាស្ត្រ សិល្បៈ អប់រំសិក្សាធិការ សេវាខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រ នីតិសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម ការសិក្សា ស្រាវជ្រាវ គណនេយ្យ ...

ខ- អត្រា ១៥ ភាគរយ ចំពោះ សួយសារពីទ្រព្យសកម្មអរូបី និងសួយសារពីភាគកម្មក្នុងធនធានរ៉ែ :

ខ១- សំរាប់គោលដៅនៃពន្ធកាត់ទុក សួយសារចំពោះទ្រព្យសកម្មអរូបី គឺសំដៅដល់ចំណូល ជាសាច់ប្រាក់ ឬជាវត្ថុ ដែលទទួលបានទាក់ទិននឹង :

- ការអនុញ្ញាតឱ្យប្រើប្រាស់នូវសិទ្ធិបោះពុម្ពផ្សាយ និងលក់ស្នាដៃអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬសិទ្ធិប្រហាក់ប្រហែល (ក្នុងនេះមានរាប់បញ្ចូលទាំងសិទ្ធិចំលង និងផ្សាយខ្សែអាត់សំលេង ឬវីដេអូ...) ប្រកាសនីយប័ត្រតក្កកម្ម ម៉ាកសញ្ញាផលិត ម៉ាកសញ្ញាពាណិជ្ជកម្ម គំនូរ គំរូប្លង់ គំរោង រូបមន្ត ការសំងាត់អំពីវិធីផលិត... និយាយរួមគឺអ្វីៗទាំងអស់ដែលជាកម្មសិទ្ធិអរូបី ឬសិទ្ធិផ្សេងៗ
- ចំណេះដឹងឬចំណេះធ្វើ ឬពត៌មានទាក់ទិននឹងបទពិសោធន៍ផ្សេងៗក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម វិទ្យាសាស្ត្រ បច្ចេកទេស ...
- ការផ្ទេរសិទ្ធិលើចំណេះ ឬពត៌មាន ដូចមានរៀបរាប់ក្នុងវាក្យខ័ណ្ឌ ខ១ នេះ
- ការផ្តល់យោបល់ ឬការផ្តល់សេវា ទាក់ទិននឹងការអនុវត្តន៍ ឬការប្រើប្រាស់សិទ្ធិដូចមានរៀបរាប់ក្នុងវាក្យខ័ណ្ឌ ខ១ នេះ

ខ២- សំរាប់គោលដៅនៃពន្ធកាត់ទុក សួយសារចំពោះភាគកម្មក្នុងធនធានរ៉ែ គឺសំដៅដល់រាល់អត្ថប្រយោជន៍ ជាប្រាក់ឬជាវត្ថុដែលទទួលបានទាក់ទិននឹងភាគកម្មនេះ ក្រៅតែពីប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធាននេះ និងភាគលាភដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិដោយឡែក។

គ- អត្រា ១៥ ភាគរយ ចំពោះការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ។

ឃ- អត្រា ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការជួលចលនទ្រព្យឬអចលនទ្រព្យ : សំរាប់គោលដៅនៃពន្ធកាត់ទុក ប្រាក់ចំណូលពីការជួលចលនទ្រព្យឬអចលនទ្រព្យ គឺសំដៅដល់សាច់ប្រាក់ឬវត្ថុដែលអ្នកជួលបានបង់សំរាប់ជាថ្នូរនៃការប្រើប្រាស់ចលនទ្រព្យ ដូចជាបរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម បច្ចេកទេស វិទ្យាសាស្ត្រ ... និងអចលនទ្រព្យ ដូចជា ដីធ្លី ផ្ទះសំបែង សំណង់ផ្សេងៗ ... ។ ក្នុងនេះអចលនទ្រព្យត្រូវមានរួមបញ្ចូលទាំងរបស់ទ្រព្យបន្ទាប់បន្សំនៃអចលនទ្រព្យនោះ ព្រមទាំងសិទ្ធិអនុវត្តទៅតាមច្បាប់ស្តីពីកម្មសិទ្ធិដីធ្លី សិទ្ធិអាស្រ័យផលលើអចលនទ្រព្យ និងសិទ្ធិនានាដែលបង្កឱ្យមានការទូទាត់ជាប្រាក់ ឬជាវត្ថុតាមចំនួនផ្សេងៗ ឬតាមចំនួនកំណត់ ។

ង- អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ ។

ច- អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ទៅឱ្យរូបវន្តបុគ្គលនិវាសនជន ដែលមានប្រាក់បញ្ញើនៅក្នុងគណនីសន្សំគ្មានកាលកំណត់ ។

## ផ្នែកទី ៨.៣ : ពន្ធកាត់ទុកលើការទូទាត់ទៅឱ្យអនិវាសនជន

១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន ១៤ ភាគរយ នៃទឹកប្រាក់ត្រូវបើក :

ក- ការប្រាក់

ខ- សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

ខ១- ប្រាក់សួយសារត្រូវបានកំណត់ក្នុងវាក្យខ័ណ្ឌ ខ១ នៃផ្នែកទី៨.២ ខាងលើ ។ ដោយឡែកប្រាក់សួយសារសំរាប់ធនធានរ៉ែ ប្រេងកាត ឬឧស្ម័នធម្មជាតិ សំដៅដល់ អត្ថប្រយោជន៍ជាសាច់ប្រាក់ ឬជាវត្ថុ ដែលទទួលបានទាក់ទិននឹងភាគកម្មទាំងនេះ ក្រៅតែពីប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធានទាំងនេះ និងភាគលាភ ។

ខ២- សំរាប់គោលដៅនៃពន្ធកាត់ទុក ថ្លៃឈ្នួលត្រូវបានកំណត់ក្នុងវាក្យខ័ណ្ឌ ឃ នៃផ្នែកទី ៨.២ ខាងលើ ។

គ- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

ឃ- ភាគលាភ

## ផ្នែកទី ៨.៤ : ការលើកលែងការកាត់ទុកប្រាក់ពន្ធ

១- ការបើកឬការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុចំពោះករណីដូចខាងក្រោម ត្រូវបានអនុញ្ញាតឱ្យលើកលែងការកាត់ទុកនូវប្រាក់ពន្ធកាត់ទុក :

ក- ការប្រាក់ដែលបង់ទៅឱ្យធនាគារនិងស្ថាប័នសញ្ញ័យធនក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។

ខ ការបើកឬទូទាត់ទៅឱ្យរាជរដ្ឋាភិបាល ឬស្ថាប័ននៃរាជរដ្ឋាភិបាលនូវសួយសារ ឬប្រាក់ថ្លៃឈ្នួលលើចលនទ្រព្យ ឬអចលនទ្រព្យ (ក្នុងនេះមានរួមបញ្ចូលផងដែរនូវប្រាក់បង់លើឡូត៍នេសាទ ព្រៃគុប កំពង់ផែ ភាស៊ីផ្សារ ...) ដែលបំពេញបាននូវល័ក្ខខ័ណ្ឌទាំងពីរដូចតទៅ :

ខ១- ការបើកឬទូទាត់នេះ ត្រូវទាក់ទិននឹងចលនទ្រព្យឬអចលនទ្រព្យបានកត់ត្រាជាទ្រព្យសម្បត្តិរដ្ឋនៅក្នុងបញ្ជីសារពើភ័ណ្ឌដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់គ្រង

ខ២- ប្រាក់បើកឬទូទាត់ត្រូវមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថាជាចំណូលបង់ចូលថវិការដ្ឋ

គ ការបើក ឬទូទាត់នូវប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្ស ឬពន្ធលើអត្ថប្រយោជន៍បន្ថែម ដូចមានចែងក្នុងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្សលេខ ៣៩៦ ប្រក.សហវ.ពដ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឃ ការបើកឬទូទាត់នូវការប្រាក់ ដោយរាជរដ្ឋាភិបាលឬស្ថាប័នរាជរដ្ឋាភិបាល ទៅឱ្យបុគ្គលអនិវាសនជនចំពោះប្រាក់ខ្ចីដែលរាជរដ្ឋាភិបាលកម្ពុជាឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលស្គាល់និងយល់ព្រម។

២- ការលើកលែងពន្ធកាត់ទុកចំពោះប្រាក់ចំណូលរបស់សហគ្រាសនីតិបុគ្គលជាប់ពន្ធតាមរបបពិត :

ក- ពន្ធកាត់ទុកមិនត្រូវអនុវត្តទេ ចំពោះប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល របស់សហគ្រាសនីតិបុគ្គលដែលបានចុះបញ្ជីជាសហគ្រាសជាប់ពន្ធតាមរបបពិត ។

ខ- សំរាប់ករណីដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ការកាត់ទុកប្រាក់ពន្ធកាត់ទុកត្រូវបានអនុញ្ញាតឱ្យលើកលែងលើទឹកប្រាក់ណាមួយ លុះណាតែទឹកប្រាក់នោះត្រូវបានកត់ត្រាក្នុងវិក្កយបត្រដែលចេញដោយអ្នកទទួលប្រាក់ និងដែលបានសរសេរបំពេញគ្រប់និទ្ទេសបានត្រឹមត្រូវនិងច្បាស់លាស់ដូចមានចែងក្នុងប្រកាសលេខ ៣៤១ ប្រក.សហវ.ពដ និងប្រកាស លេខ ៣៤២.ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គ- អ្នកបើក ឬទូទាត់ប្រាក់ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធលើទឹកប្រាក់ពន្ធកាត់ទុក ដែលបុគ្គលនេះបានសំរេចមិនអនុវត្តការកាត់ទុក ដោយមូលហេតុខ្លួនបានកំណត់ថា ប្រាក់ចំណូលជាប់ទាក់ទិនបានបំពេញនូវលក្ខខ័ណ្ឌដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ ឬដោយមូលហេតុអ្វីផ្សេងទៀត ។

## ផ្នែកទី ៨.៥ : ការគណនាទឹកប្រាក់ពន្ធកាត់ទុក

១- ចំនួនទឹកប្រាក់ពន្ធកាត់ទុកត្រូវកាត់ទុក ត្រូវគណនាលើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ឱ្យបុគ្គលណាមួយនៅមុនពេលកាត់ទុកប្រាក់ពន្ធ ។

២- ចំពោះការបើក ឬទូទាត់ប្រាក់ឱ្យអនិវាសនជន ដែលមានទាក់ទិនដល់ការផ្គត់ផ្គង់សំភារៈបរិក្ខារផង និងសេវាផងដូចជានៅក្នុងការទូទាត់ចំណាយទិញម៉ាស៊ីនពីក្រៅប្រទេស ដែលរួមមានថ្លៃទិញម៉ាស៊ីន និងថ្លៃសេវាផ្គុំតំលើងដោយអ្នកបច្ចេកទេសជាបុគ្គលអនិវាសនជនផ្តល់ដោយអ្នកលក់ (សំរាប់ដំណើរការដើមដំបូងនៃម៉ាស៊ីន) មូលដ្ឋានសំរាប់គិតពន្ធកាត់ទុក គឺជាចំណែកប្រាក់ដែលទាក់ទិននឹងសេវាផ្គុំតំលើងនេះតែប៉ុណ្ណោះ ។

## ផ្នែកទី ៨.៦ : ភ្នាក់ងារកាត់ទុក និងភាតព្វកិច្ច

១- ដូចមានចែងក្នុងមាត្រា ៣១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចពស និងមាត្រា៨៨ នៃចសព ពាក្យ "ភ្នាក់ងារកាត់ទុក" សំដៅដល់បុគ្គល (រូបវន្តបុគ្គលឬនីតិបុគ្គល) ដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការកាត់ទុកនិងបង់ប្រាក់ពន្ធចូលថវិការដ្ឋក្នុងនាមនៃតតិយជន ។ ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែ បន្ទាប់ពីខែដែលបានធ្វើការកាត់ទុក តាមទំរង់បែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

## ផ្នែកទី ៨.៧ : ទោសទណ្ឌ

១- ភ្នាក់ងារកាត់ទុកត្រូវទទួលខុសត្រូវយ៉ាងពេញលេញ និងរួមគ្នាជាមួយនឹងបុគ្គលជាមុខសញ្ញាត្រូវកាត់ទុកប្រាក់ពន្ធចំពោះប្រាក់ពន្ធដែលត្រូវកាត់ទុក និងបង់ជូនរដ្ឋបាលសារពើពន្ធ ។ ដូច្នេះក្នុងករណីដែលភ្នាក់ងារកាត់ទុកមិនបានបង់ឱ្យបានត្រឹមត្រូវនូវប្រាក់ពន្ធដែលច្បាប់បានតម្រូវឱ្យខ្លួនធ្វើការកាត់ទុក និងបង់ជូនរដ្ឋបាលសារពើពន្ធ ភ្នាក់ងារកាត់ទុកនឹងត្រូវទទួលរងនូវការកំណត់ពន្ធជាឯកតោភាគីឬការកំណត់ពន្ធឡើងវិញ ព្រមទាំងប្រាក់ពិន័យផ្សេងទៀតដូចគ្នានឹងបំណុលពន្ធរបស់ភ្នាក់ងារកាត់ទុកខ្លួនឯងផ្ទាល់ដែរ ។ ភ្នាក់ងារកាត់ទុកក៏ត្រូវទទួលរងនូវទោសទណ្ឌផ្សេងៗទៀត ដូចមានចែងក្នុងចសព ។

# ជំពូកទី៩

# ការគណនាទឹកប្រាក់ពន្ធលើប្រាក់ចំណេញ

## ផ្នែកទី ៩.១ : ការកំណត់លទ្ធផលសារពើពន្ធ

១- ការបញ្ចូលមកវិញនិងការកាត់ចេញផ្សេងៗ : ដោយហេតុថាមានបទប្បញ្ញត្តិដោយឡែកខាងពន្ធដារ ប្រាក់ចំណេញជាប់ពន្ធ តាមធម្មតាមិនស្មើគ្នានឹងប្រាក់ចំណេញគណនេយ្យទេ ។ ដូច្នេះដើម្បីគណនាប្រាក់ចំណេញជាប់ពន្ធ

នៃឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវយកលទ្ធផលគណនេយ្យនៃឆ្នាំជាប់ពន្ធនោះ ( ដែលអាចជា ចំណេញពិត ឬខាតពិត ) មកធ្វើការកែតំរូវផ្សេងៗដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃ កថាខ័ណ្ឌនេះ និងក្នុងកថាខ័ណ្ឌនានាទៀតនៃផ្នែកនេះ ។

ក- គិតបញ្ចូលមកវិញនូវខ្ទង់ចំណាយផ្សេងៗដែលមិនអាចកាត់កងបានសំរាប់ការគណនាប្រាក់ចំណេញជាប់ពន្ធ ដូចជា :

ក១- ពន្ធមិនអាចកាត់ចេញបាន : ពន្ធលើប្រាក់ចំណេញ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអប្បបរមា...

ក២- ទឹកប្រាក់កែតំរូវនូវរំលស់ (ទាយជួទានឱ្យដល់រំលស់) លើកពេល ...

ក៣- ប្រាក់ពិន័យ និងទោសប្បញ្ញត្តិគ្រប់ប្រភេទ ...

ខ- កាត់ចេញនូវខ្ទង់ផ្សេងៗ ដូចជាភាគលាភបានទទួលដូចមានចែងក្នុងកថាខ័ណ្ឌ ៨ នៃផ្នែកទី ១០.២ នៃប្រកាសនេះ ... ។

២- ក្រោយពីបានធ្វើការកែតំរូវដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃផ្នែកនេះ សហគ្រាសត្រូវគណនាវិភាគទានសប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ ។ ក្នុងនេះ សហគ្រាសត្រូវ :

ក- កំណត់លទ្ធផលមុនការកាត់កងវិភាគទានសប្បុរសធម៌សំរាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលនៃការគិតគូរតាមកថាខ័ណ្ឌ ១ នៃផ្នែកនេះ ទៅបូកនឹងទឹកប្រាក់សរុបនៃវិភាគទានសប្បុរសធម៌ដែលបានចំណាយនៅក្នុងឆ្នាំជាប់ពន្ធ

ខ- គណនាវិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលដែលត្រូវបានគណនាឡើងនៅក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ទៅគុណនឹង ៥ ភាគរយ ។

៣- សហគ្រាសត្រូវគណនាវិភាគទានសប្បុរសធម៌អាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ :

ក- ប្រសិនបើទឹកប្រាក់សរុបនៃវិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធតូចជាង ឬស្មើនឹងវិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ ក្នុងករណីនេះ ទឹកប្រាក់សរុបនៃវិភាគទានសប្បុរសធម៌នៅក្នុងឆ្នាំជាប់ពន្ធ គឺជាវិភាគទានសប្បុរសធម៌អាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ

ខ- ប្រសិនបើទឹកប្រាក់សរុបនៃវិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធ ធំជាងវិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ ក្នុងករណីនេះ វិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ គឺជាវិភាគទានសប្បុរសធម៌អាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ ហើយសហគ្រាសត្រូវមានវិភាគទានសប្បុរសធម៌នៅសល់កាត់កងមិនអស់ ដែលត្រូវក្លាយជាចំណាយមិនអាចកាត់កងបានសំរាប់ឆ្នាំជាប់ពន្ធ ។ ក្នុងករណីនេះ :

ខ១- សហគ្រាសត្រូវគណនាឡើងនូវលទ្ធផលជាប់ពន្ធ ក្រោយការកាត់កងវិភាគទានសប្បុរសធម៌ដែលត្រូវបានអនុញ្ញាតឱ្យកាត់កង ។

៤- បន្ទាប់មកសហគ្រាសត្រូវ :

ក- គណនាប្រាក់ចំណេញសុទ្ធក្រៅពីការប្រាក់ ដោយយកលទ្ធផលជាប់ពន្ធក្រោយការកាត់កងវិភាគទានសប្បុរសធម៌ដែលត្រូវបានអនុញ្ញាតឱ្យកាត់កង ទៅបូកនឹងចំណាយការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធ រួចដកនឹងចំណូលការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធ

ខ- គណនាចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកចំណូលការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធ ទៅបូកនឹង ៥០ ភាគរយ នៃប្រាក់ចំណេញសុទ្ធក្រៅពីការប្រាក់ដូចបានគណនាក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ

គ- គណនាចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធអាចកាត់កងបាន ដោយប្រៀបធៀបចំណាយការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធ ទៅនឹងចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ :

គ១- ប្រសិនបើចំណាយការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធធំជាង ឬស្មើនឹងចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធអាចកាត់កងបានគឺត្រូវស្មើនឹងចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ

គ២- ប្រសិនបើចំណាយការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធ តូចជាងចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធនេះគឺអាចកាត់កងបានទាំងអស់សំរាប់ឆ្នាំជាប់ពន្ធ ។ ក្នុងករណីនេះ ត្រូវពិនិត្យមើលសមតុល្យចំណាយការប្រាក់នៅសល់កាត់កងមិនអស់ពីឆ្នាំមុន ។ ប្រសិនបើសមតុល្យនេះវិជ្ជមាន ត្រូវយោងចំណាយការប្រាក់នៅសល់កាត់កងមិនអស់ពីឆ្នាំមុននេះមកកាត់ចេញថែមទៀត គឺកាត់ចេញក្នុងចំនួនមួយដែលគោរពលក្ខខ័ណ្ឌថា ផលបូកនៃចំណាយការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធនិងទឹកប្រាក់យោងមកកាត់ចេញនៃចំណាយការប្រាក់នៅសល់កាត់កងមិនអស់ពីឆ្នាំមុន មិនត្រូវធំជាងចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធទេ ។

ឃ- គណនាប្រាក់ចំណេញសុទ្ធក្រោយការកាត់កងការប្រាក់ (ឬលទ្ធផលជាប់ពន្ធនៃការិយបរិច្ឆេទ) ដោយយកប្រាក់ចំណេញសុទ្ធក្រៅពីការប្រាក់ ទៅបូកនឹងចំណូលការប្រាក់សរុបក្នុងឆ្នាំជាប់ពន្ធ រួចដកនឹងចំណាយការប្រាក់អាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ។ ចំពោះចំណាយការប្រាក់ដែលនៅសល់ពីការកាត់កងនេះ គឺត្រូវបានចាត់ទុកជាចំណាយការប្រាក់សំរាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយការផាត់ចេញត្រូវអនុវត្តទៅតាមខ្លឹមសារនៃកថាខ័ណ្ឌនេះ ។

៥- ប្រសិនបើលទ្ធផលជាប់ពន្ធនៃការិយបរិច្ឆេទដែលបានគណនាឡើងក្នុងកថាខ័ណ្ឌ ៤ នៃផ្នែកនេះ គឺជាប្រាក់ចំណេញ សហគ្រាសត្រូវគណនាលទ្ធផលសារពើពន្ធសំរាប់ឆ្នាំជាប់ពន្ធនោះ ដោយយកមកគិតគូរនូវការខាតបង់ពីឆ្នាំមុនៗដែលត្រូវយោងមក ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៩.៥ នៃប្រកាសនេះ ។

## ផ្នែកទី ៩.២ : ការគណនាបំណុលពន្ធនៃពន្ធលើប្រាក់ចំណេញ

១- បំណុលពន្ធលើប្រាក់ចំណេញ ត្រូវបានគណនាដូចតទៅ :

ក- គណនាបំណុលពន្ធលើប្រាក់ចំណេញនៃឆ្នាំជាប់ពន្ធ (ដែលតទៅនេះហៅថាបំណុលពន្ធលើប្រាក់ចំណេញតាមមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព) ដោយយកលទ្ធផលសារពើពន្ធនៃឆ្នាំជាប់ពន្ធដូចបានកំណត់ក្នុងផ្នែកទី ៩.១ នៃប្រកាសនេះ ទៅគុណនឹងអត្រាពន្ធលើប្រាក់ ចំណេញប្រចាំឆ្នាំនៃមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព (ដូចមានចែងក្នុងផ្នែកទី ៩.៦ នៃប្រកាសនេះ) ។

ខ- ដកឥណទានពន្ធបរទេសតាមមាត្រា ៣៦ នៃចសព (ដូចមានចែងក្នុងផ្នែកទី ៩.៧ នៃប្រកាសនេះចំពោះសហគ្រាសនិវាសនជនដែលមានប្រាក់ចំណូលប្រភពបរទេស) ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះទេ ។

គ-	ដកពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ដែលបានបង់ដោយអ្នកជាប់ពន្ធតាមវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌ ១ នៃមាត្រា ២៣ថ្មី ច្បាប់ស្តីពីវិសោធនកម្មនៃចសព ទៅតាមចំនួនដូចខាងក្រោម :

គ១-	១០០ ភាគរយ នៃប្រាក់ពន្ធបានបង់ សំរាប់សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ ឬ ៣០ ភាគរយ

គ២-	៧ ភាគ ៩១ នៃប្រាក់ពន្ធបានបង់ សំរាប់សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ

គ៣-	០ ភាគរយ នៃប្រាក់ពន្ធបានបង់ សំរាប់សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ០ ភាគរយ

ចំនួនខាងលើនេះមិនត្រូវឱ្យលើសពីបំណុលពន្ធបន្ទាប់ពីកាត់កងឥណទានពន្ធបរទេស ក្នុងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះទេ ។

## ផ្នែកទី ៩.៣ : ការគណនាប្រាក់ពន្ធលើប្រាក់ចំណេញត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ

១-	ប្រាក់ពន្ធលើប្រាក់ចំណេញត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

ក-	ក្នុងករណីដែលលទ្ធផលគណនាតាមផ្នែកទី ៩.២ នៃប្រកាសនេះ មានចំនួនច្រើនជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូក ៨ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ដែលអ្នកជាប់ពន្ធបានបង់សំរាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព អ្នកជាប់ពន្ធត្រូវបង់បន្ថែមនូវចំនួនដែលលំអៀងនោះជូនរដ្ឋបាលសារពើពន្ធ

ខ-	ប្រសិនបើលទ្ធផលគណនាតាមផ្នែកទី ៩.២ នៃប្រកាសនេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូក ៨ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់សំរាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលំអៀង ឬយោងទៅប្រើជាប្រាក់រំដោះសំរាប់ឆ្នាំបន្ទាប់

គ-	មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ឬក៏សុំបង្វិលសង ឬយោងទៅប្រើជាប្រាក់រំដោះតាមវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមាតាមនីតិវិធីដូចមានចែងក្នុងផ្នែកទី ៩.៤ នៃប្រកាសនេះ ។

## ផ្នែកទី ៩.៤: ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ

១-	ប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

ក-	អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមាដូចមានចែងក្នុងមាត្រា ២៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ ។ ពន្ធអប្បបរមាត្រូវបង់ អាចត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធជាមួយគ្នាតាមមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព

ខ-	បើសិនបំណុលពន្ធលើប្រាក់ចំណេញលើសពីបំណុលពន្ធអប្បបរមា :

ខ១- អ្នកជាប់ពន្ធត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌ ១ នៃផ្នែកទី ៩.៣ នៃប្រកាសនេះ នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ខ២- ក្នុងករណីនេះ អ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ

គ- បើសិនបំណុលពន្ធលើប្រាក់ចំណេញ តិចជាងបំណុលពន្ធអប្បបរមា :

គ១- ឥណទានពន្ធរបស់អ្នកជាប់ពន្ធ តាមកថាខ័ណ្ឌ១ នៃផ្នែកទី ៩.៣ នៃប្រកាសនេះ (គឺផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងជំពូក ៨ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់សំរាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព) ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លំអៀងរវាងបំណុលពន្ធអប្បបរមា និងបំណុលពន្ធលើប្រាក់ចំណេញ

គ២- ការកាត់បន្ថយចុះនូវឥណទានពន្ធ តាមការអនុវត្តន៍នៃវាក្យខ័ណ្ឌ គ១ នៃកថាខ័ណ្ឌនេះ ត្រូវបានចាត់ទុកជាការទូទាត់ប្រាក់ពន្ធអប្បបរមាសំរាប់ឆ្នាំជាប់ពន្ធ

គ៣- អ្នកជាប់ពន្ធត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌ ១ នៃផ្នែកទី ៩.៣ នៃប្រកាសនេះ នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដោយក្នុងនេះផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូក ៨ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់សំរាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ត្រូវបានជំនួសដោយទឹកប្រាក់នៃឥណទានពន្ធក្រោយការកាត់បន្ថយដូចមានចែងក្នុងវាក្យខ័ណ្ឌ គ១ នៃកថាខ័ណ្ឌនេះ ។

## ផ្នែកទី ៩.៥ : វិធានស្តីពីការយោងការខាតបង់

១- មាត្រា ១៧ នៃចសព បានចែងថា :

ក- ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ជាបន្ទុកសំរាប់ឆ្នាំជាប់ពន្ធបន្ទាប់ (ដែលហៅថាឆ្នាំជាប់ពន្ធទី ១ នៃការយោងការខាតបង់) ហើយត្រូវកាត់ចេញពីប្រាក់ចំណេញសំរេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ ។ បើប្រាក់ចំណេញនេះមិនគ្រប់គ្រាន់សំរាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី ៥ ។

ខ- នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ បទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយ តាមលំដាប់ដែលការខាតបង់បានកើតឡើង ។

២- ល័ក្ខខ័ណ្ឌនៃការយោងការខាតបង់មកកាត់ចេញ :

ក- ភស្តុតាងបញ្ជាក់ពីការមានការខាតបង់ :

ក១- ដើម្បីអាចកាត់ចេញបាន ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាសដែលបានដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ឱ្យដាក់លិខិតប្រកាសនេះ

ក២- អ្នកជាប់ពន្ធដែលត្រូវទទួលរងការកំណត់ពន្ធជាឯកតោភាគីរបស់រដ្ឋបាលសារពើពន្ធ មិនត្រូវបានអនុញ្ញាតឱ្យយោងការខាតបង់ពីមុនមកកាត់ចេញទេ

ក៣- ការខាតបង់ដែលយោងមកកាត់ចេញ ត្រូវតែមានការបញ្ជាក់អះអាងដោយបញ្ជីឯកសារគណនេយ្យ ដែលត្រូវបានកាន់កាប់ថែរក្សាយ៉ាងល្អ ស្របតាមវិធានដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងក្នុងស្តង់ដាល្អខាងគណនេយ្យ

ខ- អត្តសញ្ញាណនៃសហគ្រាស :

ខ១- ការខាតបង់អាចអនុញ្ញាតឱ្យយោងមកសំរាប់កាត់ចេញពីប្រាក់ចំណេញ ដែលសំរេចបានតែនៅក្នុងក្របខ័ណ្ឌនៃសហគ្រាសតែមួយដដែលប៉ុណ្ណោះ ។ តាមនេះ :

- ក្នុងករណីនៃការផ្លាស់ប្តូរម្ចាស់សហគ្រាស ការខាតបង់របស់ម្ចាស់សហគ្រាសមុន មិនត្រូវបានអនុញ្ញាតឱ្យយោងមកកាត់ចេញពីប្រាក់ចំណេញរបស់ម្ចាស់សហគ្រាសក្រោយឡើយ ។ ការផ្លាស់ប្តូរម្ចាស់សហគ្រាស មានជាអាទិ៍ ក្នុងករណីនៃការលក់សហគ្រាស ករណីម្ចាស់សហគ្រាសស្លាប់ ហើយអ្នកទទួលមរតកធ្វើអាជីវកម្មបន្តពីអ្នកស្លាប់ ...
- ក្នុងករណីនៃការផ្លាស់ប្តូរសកម្មភាពអាជីវកម្ម ដែលត្រូវបានចាត់ទុកជាការបញ្ឈប់សកម្មភាពសហគ្រាសចាស់នឹងការបង្កើតឡើងនូវសហគ្រាសមួយថ្មីទៀត (ឧទាហរណ៍ : សហគ្រាសឈប់ធ្វើសកម្មភាពខាងលក់ដូរ មកធ្វើសកម្មភាពខាងការងារសំណង់...) ការខាតបង់ដែលសហគ្រាសបានទទួលរងក្នុងសកម្មភាពចាស់របស់ខ្លួន មិនត្រូវបានអនុញ្ញាតឱ្យយកមកកាត់ចេញទេពីប្រាក់ចំណេញដែលសហគ្រាសសំរេចបានក្នុងសកម្មភាពថ្មីរបស់ខ្លួន ។

គ- ការិយបរិច្ឆេទត្រូវយោងការខាតបង់មកកាត់ចេញ :

គ១- ការខាតបង់ត្រូវយោងមកកាត់ចេញជាដាច់ខាតពីលទ្ធផលនៃការិយបរិច្ឆេទ(ក្រោយ)ទី១ ដែលមានចំណេញ ។ សហគ្រាសមិនអាចកំណត់បានដោយសេរីទេនូវឆ្នាំជាប់ពន្ធនានាដែលសហគ្រាសត្រូវធ្វើការយោងមកកាត់ចេញនូវការខាតបង់របស់ខ្លួន ។

គ២- ប្រសិនបើដោយមូលហេតុណាមួយ សហគ្រាសមិនបានយោងការខាតបង់ទៅកាត់ចេញនឹងប្រាក់ចំណេញនៃឆ្នាំជាប់ពន្ធណាមួយដែលច្បាប់បានអនុញ្ញាតឱ្យកាត់ចេញ (កាត់ចេញនូវការខាតបង់ទាំងអស់ ឬក្នុងចំណែកណាមួយ) ការខាតបង់នេះមិនអាចយោងទៅកាត់ចេញពីប្រាក់ចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ៗទៀតបានទេ ។

គ៣- ការខាតបង់ដែលសហគ្រាសទទួលរងក្នុងឆ្នាំជាប់ពន្ធ ១៩៩៧ និងក្នុងឆ្នាំជាប់ពន្ធបន្តបន្ទាប់អាចយោងទៅមុខបាន ៥ ឆ្នាំ សំរាប់ធ្វើការកាត់ចេញ ។ ការខាតបង់ដែលសហគ្រាសទទួលរងមុនឆ្នាំជាប់ពន្ធ ១៩៩៧ អាចយោងទៅមុខបាន ៣ ឆ្នាំ សំរាប់ធ្វើការកាត់ចេញ ។

## ផ្នែកទី ៩.៦ : អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ (មាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព)

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានដូចតទៅ :

១- ២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ។

៣-	៩ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់រយៈពេលអន្តរកាល ៥ ឆ្នាំ ដោយគិតចាប់ផ្តើមពីថ្ងៃប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

៤-	០ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៥-	តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្ម ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល :

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ៦.០០០.០០០ ៛ | ០ % |
| ពី | ៦.០០០.០០១ ៛ | ដល់ | ១៥.០០០.០០០ ៛ | ៥ % |
| ពី | ១៥.០០០.០០១ ៛ | ដល់ | ១០២.០០០.០០០ ៛ | ១០ % |
| ពី | ១០២.០០០.០០១ ៛ | ដល់ | ១៥០.០០០.០០០ ៛ | ១៥ % |
| លើសពី | | | ១៥០.០០០.០០០ ៛ | ២០ % |

៦-	សិទ្ធិ បុព្វសិទ្ធិ និងសិទ្ធិដទៃទៀត ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួលក្រោមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មិនអាចផ្ទេរ ឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ។

## ផ្នែកទី ៩.៧ : ឥណទានពន្ធបរទេស (មាត្រា ៣៦ នៃចសព)

១-	អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសំរាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់ពីការបង់ពន្ធនៅបរទេសនោះ ។

២-	ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលអំពីប្រភពកម្ពុជា និងប្រភពបរទេសមកគិត ។

៣	ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សំរាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសំរាប់ឆ្នាំជាប់ពន្ធ និងសំរាប់ប្រាក់ពន្ធដែលបានបង់នៅប្រទេសក្រៅណាមួយ គឺចំនួនដែលទាបជាងគេក្នុងចំណោម :

- ក-	ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ
- ខ-	ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណេញសរុបពីគ្រប់ប្រភពសំរាប់រយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាពន្ធក្នុងមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ទៅគុណនឹងផលចែករវាងប្រាក់ចំណូលដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលសរុបពីគ្រប់ប្រភព ។

៤-	ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេស និងរដ្ឋបាលសារពើពន្ធបរទេសនោះ ។

៥- ក្នុងករណីឥណទានពន្ធមានចំនួនលើសពីបំណុលពន្ធ ចំនួនលើសនោះអាចយកមកប្រើប្រាស់សំរាប់ទូទាត់ពន្ធអប្បបរមា និងអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី ៥ គិតពីឆ្នាំបន្ទាប់នៃឆ្នាំដែលឥណទានពន្ធនោះបានកើតឡើង ។ ប្រសិនបើមានឥណទានពន្ធច្រើនឆ្នាំ ត្រូវយកឥណទានពន្ធទាំងនោះមកប្រើតាមលំដាប់ឆ្នាំដែលឥណទានពន្ធទាំងនោះបានកើតឡើង ។

## ជំពូកទី ១០
## របបពន្ធលើនីតិបុគ្គល

### ផ្នែកទី ១០.១ : គោលការណ៍

១- ដូចមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព និយមន័យនីតិបុគ្គលត្រូវបានកំណត់យ៉ាងទូលាយដោយរួមបញ្ចូលទាំងសហគ្រាស ឬអង្គការនានាដែលប្រកបអាជីវកម្ម ទោះបីបានឬមិនទាន់បានការទទួលស្គាល់ជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្តី ។ នីតិបុគ្គល គឺជាអង្គភាពមួយដែលមានចរិតលក្ខណៈជាក្រុមហ៊ុន ស្ថាប័នរដ្ឋ អង្គការសប្បុរសធម៌ ឬសាសនា អង្គការមិនស្វែងរកចំណេញ ក្រុមហ៊ុនសហកម្មសិទ្ធិ (ដែលមិនមែនជាក្រុមអាជីវកម្ម) ឬគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ដូចមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព អ្នកចូលហ៊ុន គឺជាបុគ្គលដែលមានចំណែកភាគកម្ម ឬដែលអាចបានទទួលប្រាក់ចំណូល ឬប្រាក់ចំណេញក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលដូចមានបញ្ជាក់ ក្នុងកថាខ័ណ្ឌ ១ នៃផ្នែកនេះ ។

៣- ដូចមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ភាគលាភ គឺជាចំណែកជាសាច់ប្រាក់ឬជាទ្រព្យដែលនីតិបុគ្គលបានបែងចែកឱ្យអ្នកចូលហ៊ុនទៅតាមកំរិតភាគកម្មរបស់អ្នកចូលហ៊ុន លើកលែងតែភាគលាភជាប័ណ្ណភាគហ៊ុន និងការបែងចែកនានាក្នុងពេលជំរះបញ្ជីរំលាយក្រុមហ៊ុន ។

### ផ្នែកទី ១០.២ : ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ

ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ត្រូវបានកំណត់ដូចតទៅ :

១- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ ភាគរយ នៃទឹកប្រាក់ត្រូវបែងចែក ចំពោះ :

ក. ការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០ ភាគរយ ដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព និង

ខ. ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៣ នៃផ្នែកនេះ និងការបង់សងវិញនូវមូលធន ។

២- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ ភាគ ៨១ នៃទឹកប្រាក់ត្រូវបែងចែក ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ តាមកថាខ័ណ្ឌ ៣ នៃមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។

៣- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ តាមកថាខ័ណ្ឌ ១ នៃមាត្រា ២០ថ្មី

នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ឬអត្រា ៣០ ភាគរយ តាមកថាខ័ណ្ឌ ២ នៃមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។

៤- ប្រសិនបើសហគ្រាសណាមួយបានទទួលភាគលាភបានបង់ពន្ធតាមកថាខ័ណ្ឌ ១ កថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៣ នៃផ្នែកនេះ ពីសហគ្រាសមួយទៀត ត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន ។ ពេលសហគ្រាសនោះបែងចែកភាគលាភជាបន្តទៀតទៅអ្នកចូលហ៊ុនរបស់ខ្លួន ទឹកប្រាក់បែងចែកដែលត្រូវដកចេញពីគណនីភាគលាភ មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញបន្ថែមដូចក្នុង កថាខ័ណ្ឌ ១ កថាខ័ណ្ឌ ២ និង កថាខ័ណ្ឌ ៣ នៃផ្នែកនេះទេ ។

៥- សម្រាប់គោលដៅនៃផ្នែកនេះ ការបែងចែកណាមួយនៃប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមលំដាប់ដូចខាងក្រោម :

ក- ដំបូង យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ តាមកថាខ័ណ្ឌ ១ នៃ មាត្រា ២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ឬអត្រា ៣០ ភាគរយ តាមកថាខ័ណ្ឌ ២ នៃមាត្រា ២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព

ខ- បន្ទាប់មក យកចេញពីប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ តាមកថាខ័ណ្ឌ ៣ នៃមាត្រា ២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព

គ- បន្ទាប់មកទៀត យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០ ភាគរយ តាមកថាខ័ណ្ឌ ៤ នៃ មាត្រា ២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។

៦- សហគ្រាស ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ដូចមានចែងក្នុងមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព និងបង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលការបែងចែកត្រូវបានទូទាត់ ។

៧- សហគ្រាសដែលបែងចែកភាគលាភ ត្រូវជូនដំណឹងដល់អ្នកទទួលភាគលាភតាមទំរង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ដើម្បីបញ្ជាក់ថាពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភត្រូវបានបង់រួចហើយនៅពេលមានការបែងចែកភាគលាភនេះ ។

៨- សំរាប់គោលដៅនៃពបច បុគ្គលណាមួយដែលបានទទួលភាគលាភ និងដែលអាចបង្ហាញជាភស្តុតាងនូវលិខិតជូនដំណឹងដូចបានតំរូវឡើងនៅក្នុងកថាខ័ណ្ឌ ៧ នៃផ្នែកនេះ បុគ្គលនោះមិនត្រូវកត់ត្រាភាគលាភនេះនៅក្នុងប្រាក់ចំណូលជាប់ពន្ធរបស់ខ្លួនទេ ។

## ជំពូកទី ១១
## របបពន្ធលើសហគ្រាសប្រភេទដោយឡែកៗ

### ផ្នែកទី ១១.១ : របបពន្ធលើសហគ្រាសធានារ៉ាប់រង

១- ដូចមានចែងក្នុងមាត្រា ២១ នៃចសព សហគ្រាសធានារ៉ាប់រងតាមធម្មតាមិនត្រូវជាប់ពន្ធតាមអត្រាដែលត្រូវអនុវត្តជាទូទៅនៃមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសពទេ ។ ប៉ុន្តែសហគ្រាសធានារ៉ាប់រងត្រូវបង់ពន្ធលើ

ប្រាក់ចំណេញដែលមានចំនួនស្មើនឹង ៥ ភាគរយ នៃបុព្វលាភដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រងឬការធានារ៉ាប់រងបន្តនូវហានិភ័យកម្ពុជា ។

២- ប្រសិនបើដោយមូលហេតុណាមួយ សហគ្រាសធានារ៉ាប់រងមានធ្វើសកម្មភាពដែលមិនមែនជាការធានារ៉ាប់រង ឬការធានារ៉ាប់រងបន្ត ប្រាក់ចំណូលដែលទទួលបានពីសកម្មភាពទាំងនេះត្រូវជាប់ ពបច តាមអត្រាដូចមានចែងក្នុងមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ។ ក្នុងករណីនេះ ប្រាក់ចំណេញជាប់ពន្ធត្រូវគណនាឡើងតាមបែបបទដូចគ្នានឹងប្រាក់ចំណេញក្នុងសកម្មភាពរបស់សហគ្រាសផ្សេងទៀតដែរ ។

៣- សហគ្រាសធានារ៉ាប់រងក៏ត្រូវបង់ផងដែរនូវពន្ធលើអត្ថប្រយោជន៍បន្ថែមដូចមានចែងក្នុងមាត្រា ៤៨ នៃចសព ។ ដោយហេតុថា ពន្ធនេះមិនត្រូវបានកំណត់លើប្រាក់ចំណូលជាប់ពន្ធសុទ្ធរបស់សហគ្រាសទេនោះ សហគ្រាសធានារ៉ាប់រងមិនត្រូវបានអនុញ្ញាតឱ្យយកតំលៃនៃអត្ថប្រយោជន៍បន្ថែម ដែលសហគ្រាសបានផ្តល់ឱ្យនិយោជិតខ្លួនទៅកាត់កងនឹងចំណូលបុព្វលាភដុលរបស់ខ្លួនទេ ។

## ជំពូកទី ១២
## របបកំណត់ពន្ធ

### ផ្នែកទី ១២.១ : ប្រភេទនៃរបបកំណត់ពន្ធ

១- មាត្រា ៤ នៃចសព បានកំណត់ឡើងនូវរបបកំណត់ពន្ធ ៣ ប្រភេទ គឺរបបពិត របបបំព្រួញ និងរបបម៉ៅការ ។ បទប្បញ្ញត្តិស្តីពីរបបពិតមានចែងនៅក្នុងជំពូក ១៣ នៃប្រកាសនេះ និងរបបម៉ៅការមានចែងក្នុងជំពូក ១៤ នៃប្រកាសនេះ ។ បទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងប្រកាសដាច់ដោយឡែក ។

### ផ្នែកទី ១២.២ : ដែនអនុវត្តនៃរបបពិត

១- សហគ្រាសណាមួយត្រូវជាប់ពន្ធតាមរបបពិត គឺអាស្រ័យដោយ :

ក- ទ្រង់ទ្រាយគតិយុត្តិនៃសហគ្រាស ឬ

ខ- កំរិតផលរបរ ឬ

គ- ប្រភេទសកម្មភាពអាជីវកម្ម ។

២- ទ្រង់ទ្រាយគតិយុត្តិ : រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល គឺត្រូវជាប់ពន្ធតាមរបបពិត ទោះបីសហគ្រាសនោះមានសកម្មភាពអាជីវកម្មប្រភេទអ្វី ឬកំរិតផលរបរប៉ុន្មានក៏ដោយ ។ សហគ្រាសទាំងនេះមានជាអាទិ៍ សហគ្រាសរដ្ឋ ក្រុមហ៊ុនចំរុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ ឬអង្គការឯកជន ដែលធ្វើសកម្មភាពស្វែងរកចំណេញ ឬដែលទទួលប្រាក់ចំណូលពីបេតិកភ័ណ្ឌខ្លួន... ។

៣- កំរិតផលរបរ ឬប្រភេទសកម្មភាពអាជីវកម្មនៃសហគ្រាសឯកបុគ្គល : សហគ្រាសឯកបុគ្គលណាមួយត្រូវចុះបញ្ជីជាប់ពន្ធតាមរបបពិត ប្រសិនបើសហគ្រាសនោះបំពេញល័ក្ខខ័ណ្ឌក្នុងវាក្យខ័ណ្ឌ ក ឬវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ :

ក- កំរិតផលរបរ :

ក១- សហគ្រាសមានផលរបរក្នុងរយៈពេល ៣ ខែប្រតិទិនជាប់គ្នាណាមួយ ចាប់ពី ១២៥ លានរៀលឡើងទៅសំរាប់ការផ្គត់ផ្គង់ទំនិញឬការផ្គត់ផ្គង់ចំរុះ ឬចាប់ពី ៦០ លានរៀលឡើងទៅសំរាប់ការផ្គត់ផ្គង់សេវា ឬចាប់ពី ៣០ លានរៀលឡើងទៅសំរាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ ។

ការផ្គត់ផ្គង់ចំរុះ គឺការផ្គត់ផ្គង់ទំនិញ បូកនឹងការផ្គត់ផ្គង់សេវា (ក្នុងករណីដែលសហគ្រាសធ្វើការផ្គត់ផ្គង់ទំនិញផងនិងផ្គត់ផ្គង់សេវាផង)

ក២- សហគ្រាសដែលក្នុងពេលចាប់ផ្តើមរយៈពេល ៣ ខែជាប់គ្នាណាមួយ មានមូលដ្ឋានជឿជាក់ថាក្នុងរយៈពេល ៣ ខែប្រតិទិនជាប់គ្នានោះ សហគ្រាសនឹងមានផលរបរចាប់ពី ១២៥ លានរៀលឡើងទៅសំរាប់ការផ្គត់ផ្គង់ទំនិញឬការផ្គត់ផ្គង់ចំរុះ ឬចាប់ពី ៦០ លានរៀលឡើងទៅ សំរាប់ការផ្គត់ផ្គង់សេវា ឬនឹងមានផលរបរចាប់ពី ៣០ លានរៀលឡើងទៅសំរាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ

ក៣- សហគ្រាសមានផលរបរប្រចាំឆ្នាំចាប់ពី ៥០០ លានរៀលឡើងទៅសំរាប់ការផ្គត់ផ្គង់ទំនិញ ឬការផ្គត់ផ្គង់ចំរុះ ឬមានផលរបរប្រចាំឆ្នាំបានពីការផ្គត់ផ្គង់សេវាចាប់ពី ២៥០ លានរៀលឡើងទៅ ឬមានផលរបរប្រចាំឆ្នាំសំរាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋចាប់ពី ១២៥ លានរៀលឡើងទៅ

ក៤- សំរាប់គោលដៅនៃវាក្យខ័ណ្ឌ ក នេះ ផលរបរ គឺជាផលរបរគិតរួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទ ។

ខ- ប្រភេទសកម្មភាពអាជីវកម្ម : សហគ្រាសឯកបុគ្គល ជាសហគ្រាសនិហរ័ណអាហរ័ណ ឬជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

គ- សហគ្រាសបើកថ្មី : ប្រសិនបើក៏រឹតផលរបរប៉ាន់ស្មាន ឬប្រភេទសកម្មភាពអាជីវកម្មរបស់សហគ្រាស (ផ្អែកលើពត៏មានដែលមានចុះនៅក្នុងពាក្យសុំធ្វើអាជីវកម្ម) បំពេញនូវល័ក្ខខ័ណ្ឌត្រូវជាប់ពន្ធតាមរបបពិតដូចមានចែងក្នុងវាក្យខ័ណ្ឌ ក និងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌនេះ ។

## ផ្នែកទី ១២.៣ : ដែនអនុវត្តនៃរបបម៉ៅការ

១- របបម៉ៅការ គឺសំរាប់តែសហគ្រាសឯកបុគ្គលដែលមិនបំពេញល័ក្ខខ័ណ្ឌជាប់ពន្ធតាមរបបពិត ដូចមានចែងក្នុងកថាខ័ណ្ឌ ៣ នៃផ្នែកទី ១២.២ នៃប្រកាសនេះ ។

# ជំពូកទី ១៣
# បទប្បញ្ញត្តិស្តីពីរបបពិត

## ផ្នែកទី ១៣.១ : ភាតព្វកិច្ចឆ្លើយប្រកាសរបស់សហគ្រាស

១- ការប្រកាសអំពីអត្ថិភាព :

ក- ដូចមានចែងក្នុងមាត្រា ១០១ នៃ ចសព :

ក១- បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង ១៥ ថ្ងៃ ក្រោយពីបុគ្គលនោះធ្វើសកម្មភាពសេដ្ឋកិច្ច

ក២- បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរអាស័យដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង សមាសភាពអ្នកទទួលបន្ទុកកិច្ចការពន្ធដារ ឬក្រោយពីមានការផ្ទេរ ឬការបញ្ឈប់អាជីវកម្ម ។

ខ- មាត្រា ១០៣ នៃចសព បានចែងថា រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី តែពុំបានមកចុះបញ្ជី ហើយក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី ។

គ- មាត្រា ១២៨ នៃចសព បានចែងថា ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ (ដែលត្រូវទទួលរងទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃចសព) ក្នុងករណីដែលបុគ្គល :

គ១- មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ឬ

គ២- មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធពីការផ្លាស់ប្តូរផ្សេងៗដូចមានចែងក្នុងវាក្យខ័ណ្ឌ ក២ នៃកថាខ័ណ្ឌនេះ

ឃ- ការចុះបញ្ជី និងការជូនដំណឹង ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវអនុវត្តតាមទំរង់បែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ ។ ដោយឡែកចំពោះពាក្យសុំចុះបញ្ជី ត្រូវមានភ្ជាប់ឯកសារដូចតទៅ :

ឃ១- ចំពោះសហគ្រាសនីតិបុគ្គល :

- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដែលបានបង់ពន្ធប្រថាប់ត្រា
- វិញ្ញាបនប័ត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (សំរាប់គម្រោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់)
- លក្ខន្តិក:
- អត្តសញ្ញាណប័ណ្ណរបស់អ្នកដឹកនាំ (ជាមួយនឹងរូបថត)
- លិខិតបញ្ជាក់អំពីអាស័យដ្ឋានអាជីវកម្ម និងជាយថាហេតុ កិច្ចសន្យាជួលទីតាំង

ឃ២- ចំពោះសហគ្រាសឯកបុគ្គល :

- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដែលចេញដោយស្ថាប័នមានសមត្ថកិច្ច
- អត្តសញ្ញាណប័ណ្ណរបស់ម្ចាស់សហគ្រាស (ជាមួយនឹងរូបថត)
- លិខិតបញ្ជាក់ទីលំនៅ
- សៀវភៅគ្រួសារ
- លិខិតបញ្ជាក់អំពីអាស័យដ្ឋានរបស់អាជីវកម្ម និងជាយថាហេតុ កិច្ចសន្យាជួលទីតាំង

២- ការដាក់លិខិតប្រកាស :

ក- ប្រាក់ចំណេញប្រចាំឆ្នាំ :

ក១- ដូចមានចែងក្នុងមាត្រា ២៩ នៃចសព អ្នកជាប់ពន្ធលើប្រាក់ចំណេញដែលត្រូវបង់ពន្ធតាមរបបពិត ត្រូវផ្ញើជូនជារៀងរាល់ឆ្នាំទៅរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសប្រាក់ចំណេញដែលខ្លួនសំរេចបានក្នុងឆ្នាំសារពើពន្ធមុន។ លិខិតប្រកាសនេះត្រូវចុះបញ្ជីជាដាច់ខាតក្នុងរយ:ពេល ៣ ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។ លិខិតប្រកាសនេះត្រូវធ្វើតាមទំរង់ បែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ ពិសេសត្រូវមានភ្ជាប់មកជាមួយនូវតារាងតុល្យការ គណនីលទ្ធផល និងតារាងពត៏មានបន្ថែម ។

ក២- ចំពោះសហគ្រាសដែលគ្មានចំណេញ ឬមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទ និងក្នុងរយៈពេលដូចគ្នានឹងសហគ្រាសដែលមានចំណេញដែរ ។ មាត្រា ១២៨ នៃចសព បានចែងថា ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តន៍ បទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានដាក់លិខិតប្រកាសសារពើពន្ធ ដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

ក៣- អ្នកវិនិយោគទាំងអស់ ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ។

ខ- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ :

ខ១- ដូចមានចែងក្នុងមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១ ភាគរយ នៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀរលែងតែអាករលើតម្លៃបន្ថែម ដែលសម្រេចបានក្នុងខែមុន ។ ផលរបររបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ ។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។

ខ២- ដូចមានចែងក្នុងមាត្រា ៣២ នៃចសព សហគ្រាសត្រូវធ្វើលិខិតប្រកាសបង់ប្រាក់រំដោះតាមទំរង់បែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ និងត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់រំដោះនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលបំណុលពន្ធបានកើតឡើង ។

គ- អ្នកវិនិយោគទាំងអស់ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ

ឃ- ដូចមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមាត្រា ១១៦ នៃចសព ចំពោះអ្នកជាប់ពន្ធដែលមិនបានដាក់លិខិតប្រកាសក្នុងរយៈពេលដែលច្បាប់បានកំណត់ រដ្ឋបាលសារពើពន្ធនឹងធ្វើការកំណត់ពន្ធជាឯកតោភាគីលើអ្នកជាប់ពន្ធនោះ ។

## ផ្នែកទី ១៣.២ : ភាតព្វកិច្ចគណនេយ្យ

១- ការកាន់បញ្ជីគណនេយ្យ :

ក- កថាខ័ណ្ឌ ១ នៃមាត្រា ៩៨ នៃចសព បានចែងថា អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវដាក់បញ្ជីនិងឯកសារទាំងនោះតាមការតំរូវ ជូនរដ្ឋបាលសារពើពន្ធដើម្បីពិនិត្យ

ខ- មាត្រា ៩៨ នៃចសព និងអនុក្រឹត្យលេខ ០៥/អនក្រ ចុះថ្ងៃទី ០៥ ខែមិនា ឆ្នាំ១៩៩៣ ស្តីពីកាតព្វកិច្ចកាន់បញ្ជី បានកំណត់ឡើងនូវវិធានសំខាន់ៗលើការកាន់បញ្ជីគណនេយ្យ ជាអាទិ៍ :

១១- សហគ្រាសត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យនូវគ្រប់ចំលងការដែលបានធ្វើ

១២- នៅពេលបិទការិយបរិច្ឆេទ សហគ្រាសត្រូវធ្វើសារពើភ័ណ្ឌដើម្បីត្រួតពិនិត្យនូវអត្ថិភាព និងតំលៃនៃទ្រព្យសកម្ម និងទ្រព្យអកម្ម និងត្រូវបង្កើតបញ្ជីសំយោគ

១៣- គណនេយ្យត្រូវកាន់ជាភាសាខ្មែរ ដោយប្រើលេខខ្មែរ ឬលេខឡាតាំង ។ ប៉ុន្តែសហគ្រាសអាចកាន់បញ្ជីគណនេយ្យជំនួយជាភាសាផ្សេងបាន

១៤- រាល់កិច្ចការជំនួយត្រូវកត់ត្រាជាប្រាក់រៀល ។ ក្នុងករណីចាំបាច់ សហគ្រាសអាចដាក់ពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសុំការអនុញ្ញាតឱ្យសហគ្រាសកាន់បញ្ជីគណនេយ្យជារូបិយវត្ថុមួយផ្សេងពីប្រាក់រៀល

១៥- សហគ្រាសត្រូវប្រើប្រាស់ ប្រព័ន្ធគណនេយ្យទ្វេភាគ និងផ្អែកលើមូលដ្ឋានគណនេយ្យបង្គរ (double entry and accrual basis accounting system.)

១៦- វិក្កយបត្រត្រូវតែចេញឱ្យលើរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត

១៧- លិខិតយុត្តិការត្រូវមានចុះថ្ងៃខែឆ្នាំ និងរៀបចំទុកដាក់តាមលំដាប់ច្បាស់លាស់

១៨- សហគ្រាសត្រូវកត់ត្រាចូលបញ្ជីគណនេយ្យនូវកិច្ចការជំនួញនានា តាមលំដាប់លេខរៀងដែលកិច្ចការជំនួញទាំងនេះបានកើតឡើង

១៩- ការកត់ត្រាគណនេយ្យនីមួយៗ អាចឱ្យដឹងបានចំពោះកិច្ចការជំនួញជាប់ទាក់ទិននូវ ប្រភពខ្លឹមសារ ការកំណត់ខ្ទង់គណនី និងលក្ខណៈសង្ខេបនៃកិច្ចការជំនួញនោះ ព្រមទាំងការយោងទៅរកលិខិតយុត្តិការដែលជាសំអាងផង ។ ដោយឡែក អ្នកជាប់ពន្ធត្រូវកត់ត្រាសេចក្តីរាយលំអិតនៃវិក្កយបត្រឱ្យបានត្រឹមត្រូវចូលក្នុងទិនានុប្បវត្តិ

១១០- គ្រប់ការកែតំរូវ ត្រូវទុកឱ្យឃើញដានចាស់ដែលខុស ។ គណនេយ្យត្រូវរៀបចំយ៉ាងណាឱ្យអាចរកឃើញឡើងវិញបាននូវទឹកប្រាក់ពិតប្រាកដនៃចលនាទុននៅក្នុងគណនី ។

២- ការបង្ហាញឯកសារគណនេយ្យ : អ្នកជាប់ពន្ធត្រូវមានភស្តុតាងសំរាប់ខ្ទង់ចំណូលចំណាយនានាដែលខ្លួនបានប្រកាស ។ នៅពេលរដ្ឋបាលសារពើពន្ធមានសំណើឱ្យបង្ហាញភស្តុតាង អ្នកជាប់ពន្ធត្រូវបង្ហាញនូវរាល់ឯកសារគណនេយ្យ បញ្ជីសារពើភ័ណ្ឌ ប័ណ្ណចំណូល ប័ណ្ណចំណាយ.. ដើម្បីបញ្ជាក់អះអាងនូវភាពពិតប្រាកដនៃពត៌មានដែលបានចុះនៅក្នុងលិខិតប្រកាស ។ មាត្រា ១២៨ នៃចសព បានចែងថា ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងករណីដែលអ្នកជាប់ពន្ធមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ ។

៣- ការរក្សាទុកឯកសារគណនេយ្យ : ដូចមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមាត្រា ៩៨ នៃចសព បុគ្គលដែលត្រូវកាន់កាប់ កត់ត្រា ឬរក្សាទុកបញ្ជី ឯកសារនានា ឬទិនានុប្បវត្តិ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជីឬឯកសារទាំងនេះ ក្នុងរយៈពេល ១០ ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធដែលបញ្ជីឬឯកសារទាំងនេះបានកត់ត្រានូវពត៌មានផ្សេងៗលើចំលងការរបស់សហគ្រាស ។

៤- ទោសបញ្ញត្តិនៃកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ :

ក- មាត្រា ១២៨ នៃចសព បានចែងថា ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ (ដែលត្រូវទទួលរងទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃចសព) ក្នុងករណីដែលបុគ្គល :

ក១- មិនបានរក្សាទុកបញ្ជីកាគណនេយ្យ និងឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើចំលងការ

ក២- បានកសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានក្លែងបន្លំផ្សេងៗ

ក៣- បានលាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានផ្សេងៗ ។

## ផ្នែកទី ១៣.៣ : ការពិនិត្យបញ្ជាក់ (សវនកម្ម) និងការកែតំរូវលិខិតប្រកាស

១- ការត្រួតពិនិត្យ (សវនកម្ម) របស់រដ្ឋបាលសារពើពន្ធ : របបកំណត់ពន្ធលើប្រាក់ចំណេញតាមប្រាក់ចំណេញពិតប្រាកដ (ឬរបបពិត) គឺផ្អែកលើការឆ្លើយប្រកាសរបស់អ្នកជាប់ពន្ធ ដោយក្នុងនេះត្រូវមានដំណាក់កាលនៃការត្រួតពិនិត្យជាក្រោយមួយ ។

ក- បើសិនបញ្ជីគណនេយ្យណាមួយមានភាពមិនប្រក្រតី ពោលគឺមិនអាចផ្តល់ភស្តុតាងបញ្ជាក់បានថាលទ្ធផលដែលអ្នកជាប់ពន្ធឆ្លើយប្រកាសមានលក្ខណៈត្រឹមត្រូវស្មោះត្រង់នោះ រដ្ឋបាលសារពើពន្ធអាចធ្វើការកែតំរូវលើការឆ្លើយប្រកាសនេះបាន ដោយអនុវត្តតាមវិធាន និងនីតិវិធីដូចមានចែងក្នុងប្រកាសស្តីពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធលេខ ០៧៣ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ- ដូចមានចែងក្នុងកថាខ័ណ្ឌ ៨ នៃមាត្រា ៩២ នៃចសព រដ្ឋបាលសារពើពន្ធមានសិទ្ធិអំណាចកំណត់ឡើងវិញនូវកិច្ចការជំនួញនានារវាងអ្នកជាប់ពន្ធទាំងឡាយដែលមានជាប់ទាក់ទង ។ សំរាប់គោលដៅនៃវាក្យខ័ណ្ឌ ខ នេះ ពាក្យ"រវាងអ្នកជាប់ពន្ធទាំងឡាយដែលជាប់ទាក់ទង" មានន័យថា រវាងអ្នកជាប់ពន្ធនិងបុគ្គលទាក់ទិន (ដូចមានចែងក្នុងកថាខ័ណ្ឌ១១ នៃមាត្រា ៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព និងកថាខ័ណ្ឌ ៦ នៃមាត្រា ៥៦ នៃចសព) ឬរវាងអ្នកជាប់ពន្ធដែលស្ថិតក្រោមកម្មសិទ្ធិរួមគ្នា (ដូចមានចែងក្នុងមាត្រា ១៨ នៃចសព ) ។

គ- រដ្ឋបាលសារពើពន្ធមានសមត្ថកិច្ច ត្រូវត្រួតពិនិត្យពីលក្ខណៈត្រឹមត្រូវ និងស្មោះត្រង់នៃការឆ្លើយប្រកាសរបស់អ្នកជាប់ពន្ធ ។ ការត្រួតពិនិត្យនេះមានពីររូបភាពដូចមានចែងក្នុងកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៣ នៃផ្នែកនេះ ។

២- ការពិនិត្យបញ្ជាក់ (សវនកម្ម) លើលិខិតស្នាម : ការត្រួតពិនិត្យនេះ សំដៅបញ្ជាក់នូវភាពត្រឹមត្រូវស្មោះត្រង់នៃទិន្នន័យដែលត្រូវបានឆ្លើយប្រកាស ដោយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ និងផ្ទួរផ្ទងគ្នានូវពត៌មានផ្សេងៗដែលរដ្ឋបាលសារពើពន្ធបានទទួលតាមការឆ្លើយប្រកាស (លិខិតប្រកាសបង់ពន្ធ) ឬតាមការបញ្ជាក់បំភ្លឺ (តាមសំណើពីរដ្ឋបាលសារពើពន្ធ) របស់អ្នកជាប់ពន្ធ ឬពត៌មានដែលរដ្ឋបាលសារពើពន្ធបានមកពីការអនុវត្តន៍សិទ្ធិស្រាវជ្រាវប្រមូលពត៌មាន ដូចមានចែងក្នុងមាត្រា ៩២ និងមាត្រា ១០០ នៃចសព (ពិសេសការអង្កេតនិងការប្រមូលផ្តុំពត៌មានពីប្រភពខាងក្រៅ) ។

៣- ការពិនិត្យបញ្ជាក់ដល់ទីកន្លែង : ការត្រួតពិនិត្យនេះ មានគោលដៅដើម្បីក្តាប់ស្ថានភាពពិតប្រាកដនៃការធ្វើសកម្មភាពអាជីវកម្ម (ក៏រឹតចំណេញដុលដែលបានអនុវត្តលើផលិតផលមួយមុខៗឬសកម្មភាពមួយផ្នែកៗ ការត្រួតពិនិត្យតំលៃទិញចូល ចំនួននិយោជិត និងកម្មករ អចលកម្មផ្សេងៗ ...) ដើម្បីធ្វើការផ្ទួរផ្ទងជាមួយនឹងទិន្នន័យដែលបានបង្ហាញក្នុងបញ្ជីគណនេយ្យ ជាមួយនឹងរបៀបរស់នៅរបស់អ្នកដឹកនាំសហគ្រាសដែលត្រូវត្រួតពិនិត្យ.. ។

ក- នីតិវិធីនៃការពិនិត្យបញ្ជាក់ :

ក១- កថាខ័ណ្ឌ១ នៃមាត្រា ១០០ នៃចសព បានចែងថា សំរាប់ការស៊ើបអង្កេតនីមួយៗ ភ្នាក់ងាររដ្ឋបាលសារពើពន្ធដែលមានលិខិតបញ្ជាបេសកកម្ម មានសិទ្ធិចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ជាកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ ។ ភ្នាក់ងារអាចប្រើសិទ្ធិនេះនៅក្នុងពេលម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលទាំងអស់ស្របតាមល័ក្ខខ័ណ្ឌ និងហេតុផលដែលមានបញ្ជាក់នៅក្នុងដីកាដែលចៅក្រមបានចេញឱ្យ ។

ក២- ក្នុងការអនុវត្តន៍ជាក់ស្តែង ចំពោះករណីធម្មតា ដើម្បីផ្តល់ការងាយស្រួលដល់អ្នកជាប់ពន្ធនៅក្នុងការងារត្រៀមរៀបចំផ្សេងៗ (ត្រៀមបញ្ជីឯកសាររកទីប្រឹក្សា) រដ្ឋបាលសារពើពន្ធតែងអនុវត្តផ្ញើលិខិតជូនដំណឹងដល់សាមីសហគ្រាសពីការចុះធ្វើការពិនិត្យបញ្ជាក់ដល់ទីកន្លែងនេះយ៉ាងតិច ១០ ថ្ងៃជាមុន ។

ក៣- បើសិនរដ្ឋបាលសារពើពន្ធយល់ឃើញថា ការជូនដំណឹងជាមុនដូចមានចែងក្នុងវាក្យខ័ណ្ឌ ក២ នៃ កថាខ័ណ្ឌនេះអាចនាំឱ្យខូចខាតដល់លទ្ធផលនៃការត្រួតពិនិត្យពិសេសក្នុងករណីដែលរដ្ឋបាល សារពើពន្ធមានមូលដ្ឋានជឿជាក់ថាមានការបន្លំប្រាក់ពន្ធក្នុងចំនួនច្រើន រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះធ្វើការពិនិត្យបញ្ជាក់ដោយមិនប្រាប់មុន ។ ក្នុងករណីនេះ លិខិតជូនដំណឹងត្រូវបានប្រគល់ឱ្យសហគ្រាស នាពេលចាប់ផ្តើមធ្វើការពិនិត្យបញ្ជាក់(សវនកម្ម)តែម្តង ។

ខ- កាតព្វកិច្ចរបស់អ្នកជាប់ពន្ធដែលត្រូវត្រួតពិនិត្យ :

ខ១- កថាខ័ណ្ឌ ១ នៃមាត្រា ៩៨ នៃចសព បានចែងថា អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងរក្សាទុកនូវបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវដាក់បញ្ជីនិងឯកសារទាំងនោះតាមការតំរូវ ជូនរដ្ឋបាលសារពើពន្ធដើម្បីពិនិត្យ ។

ខ២- កថាខ័ណ្ឌ ២ នៃមាត្រា ១០០ នៃចសព បានចែងថា ភ្នាក់ងាររដ្ឋបាលសារពើពន្ធដែលបានចូលដោយស្របច្បាប់ទៅក្នុងទីកន្លែងរបស់បុគ្គលណាម្នាក់អាច :

- ត្រួតពិនិត្យ ធ្វើសំរង់ ឬចំលងឯកសារនានាដែលស្ថិតនៅក្នុងកន្លែងនោះ
- រឹបអូសឯកសារនានា ឬវត្ថុតាងដទៃទៀត ដែលអាចក្លាយជាពត៏មានសំរាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់
- ដាក់ឧបករណ៍សំរាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសំគាល់ឃាត់ទុកទំនិញ ប្រសិនបើមានជាប់ទាក់ទងដល់ការអនុវត្តន៍ពន្ធណាមួយ
- ធ្វើសារពើភ័ណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសំរេច និងស្តុកដទៃទៀត ។

ខ៣- អ្នកជាប់ពន្ធត្រូវរួមសហការ និងផ្តល់ការងាយស្រួលសព្វបែបយ៉ាងដល់ការងារពិនិត្យបញ្ជាក់ដូចមានចែងក្នុងវាក្យខ័ណ្ឌ ខ១ និងវាក្យខ័ណ្ឌ ខ២ នៃកថាខ័ណ្ឌនេះ ។ កថាខ័ណ្ឌ ១ នៃមាត្រា ១២៨ នៃចសព បានចែងថា គឺជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារក្នុងករណីដែលបុគ្គលណាមួយព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ ។

៤- សិទ្ធិទទួលពត៌មាន :

ក- វិសាលភាពនៃសិទ្ធិទទួលពត៌មាន :

ក១- មាត្រា ៩៩ នៃចសព បានចែងថា ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធឬតតិយជនឱ្យ:

- ផ្តល់ពត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ ដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាពត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន គណនីនៅធនាគារ ...
- បង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់ក្នុងលិខិតជូនដំណឹង ដើម្បីផ្តល់ពត៌មាន និងដើម្បីបង្ហាញ ឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រងដូចមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

ក២- កថាខ័ណ្ឌ ៥ នៃមាត្រា ៩២ នៃចសព បានចែងថា រដ្ឋបាលសារពើពន្ធមានសិទ្ធិអំណាចចូលលំនៅដ្ឋាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បីទទួលបាននូវពត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក (ដោយត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌ ខ២ នៃ កថាខ័ណ្ឌ ៣ នៃផ្នែកនេះ ។

ក៣- វាក្យខ័ណ្ឌ ៦ នៃកថាខ័ណ្ឌ ១ នៃមាត្រា ៩២ នៃចសព បានចែងថា រដ្ឋបាលសារពើពន្ធមានសិទ្ធិអំណាចទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវពត៌មានស្តីពីឬទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ។

ខ- បែបបទអនុវត្តសិទ្ធិទទួលពត៌មាន:

ខ១- កថាខ័ណ្ឌ ២ នៃមាត្រា ៩៩ នៃចសព បានចែងថា លិខិតជូនដំណឹងឱ្យផ្តល់ពត៌មាន (ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក១ នៃកថាខ័ណ្ឌនេះ) ត្រូវមានចុះឈ្មោះ និងលេខអត្តសញ្ញាណកម្មនៃអ្នកជាប់ពន្ធ (ប្រសិនបើមាន) ហើយនិងហត្ថលេខារបស់មន្ត្រីរដ្ឋបាលសារពើពន្ធដែលជាអ្នកទទួលបន្ទុកចេញលិខិតជូនដំណឹង។

ខ២- សិទ្ធិទទួលពត៌មាន មានអនុភាពអនុវត្តបាននៅក្នុងរយៈពេលដែលច្បាប់បានកំណត់សំរាប់ការរក្សាទុកបញ្ជី និងឯកសារគណនេយ្យ និងឯកសារផ្សេងៗ (១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធដែលបានធ្វើកិច្ចការជំនួញ)។

ខ៣- ភ្នាក់ងាររដ្ឋបាលសារពើពន្ធដែលអនុវត្តសិទ្ធិអំណាច ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក២ នៃកថាខ័ណ្ឌនេះ ត្រូវមានលិខិតបញ្ជាបេសកកម្ម ។ កថាខ័ណ្ឌ៤ នៃមាត្រា ១០០ នៃចសព បានចែងថា នៅពេលចូលទៅធ្វើការស៊ើបអង្កេត ភ្នាក់ងាររដ្ឋបាលសារពើពន្ធត្រូវមានអាកប្បកិរិយាសមរម្យ ចៀសវាងប្រការដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបអង្កេតដល់ទីកន្លែងនេះពុំត្រូវអនុវត្តឱ្យហួសកំរិតនៃការចាំបាច់ឡើយ ។

ខ៤- ដូចមានចែងក្នុងមាត្រា ៩៤ នៃចសព រដ្ឋបាលសារពើពន្ធហើយនិងបុគ្គលគ្រប់រូបដែលជាឬធ្លាប់ជាមន្ត្រី ឬភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ ត្រូវរក្សាសំងាត់នូវពត៌មានទាក់ទងនឹងអ្នកជាប់ពន្ធ។

ខ៥- មាត្រា ១៤០ នៃចសព បានចែងថា បើសិនអ្នកជាប់ពន្ធយល់ឃើញថា ខ្លួនបានទទួលរងនូវការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួន អំពីសកម្មភាពខុសឆ្គង ឬខុសច្បាប់ពីសំណាក់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអាចប្ដឹងទាមទារសំណងនៃការខូចខាត ឬការរងគ្រោះនោះទៅតុលាការក្នុងរយៈពេលបីឆ្នាំ ក្រោយកាលបរិច្ឆេទនៃការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួនចុងក្រោយបំផុត ។

គ- ឧបស័គ្គចំពោះការអនុវត្តន៍សិទ្ធិទទួលពត៌មានៈ

គ១- បុគ្គលណាមួយដែលមិនរួមសហការ បង្កការលំបាក ឬប្រឆាំងចំពោះការអនុវត្តន៍ស្របច្បាប់នូវសិទ្ធិអំណាចក្នុងការទទួលពត៌មានរបស់រដ្ឋបាលសារពើពន្ធ បុគ្គលនោះត្រូវបានចាត់ទុកថាបានព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ និងការប្រមូលពន្ធ ។ នេះគឺជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ដែលត្រូវទទួលរងទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃចសព។

គ២- ចំពោះសាមីអ្នកជាប់ពន្ធ ការមិនរួមសហការ បង្កការលំបាកឬប្រឆាំងចំពោះការអនុវត្តន៍ស្របច្បាប់នូវសិទ្ធិអំណាចក្នុងការទទួលពត៌មានរបស់រដ្ឋបាលសារពើពន្ធ មិនបានធ្វើឱ្យបុគ្គលនេះបានរួចផុតពីសិទ្ធិអំណាចក្នុងការកំណត់ពន្ធ ឬកំណត់ពន្ធឡើងវិញរបស់រដ្ឋបាលសារពើពន្ធឡើយ (ប្រកាសស្តីពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធលេខ ០៧៣ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

## ផ្នែកទី ១៣.៤ : សិទ្ធិតាមទារប្រមូលបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ

១- សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការតាមទារប្រមូលបំណុលពន្ធ មានចែងនៅក្នុងប្រកាសលេខ ០៧៣ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការកំណត់ពន្ធការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធ និងលេខ ០៧៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- ចំពោះសហគ្រាសដែលមានកិច្ចសន្យាជាមួយរដ្ឋ គណនេយ្យករសាធារណៈអាចធ្វើការទូទាត់សងនូវការផ្គត់ផ្គង់ទំនិញឬសេវាក្នុងកិច្ចសន្យាបាន លុះណាតែសហគ្រាសបានបង្ហាញលិខិតរបស់រដ្ឋបាលសារពើពនដែលបញ្ជាក់ថាសហគ្រាសបានបំពេញកាតព្វកិច្ចបង់ពន្ធអាករបានត្រឹមត្រូវ និងរួចរាល់ហើយ ។

៣- ចំពោះការមិនបានបង់ពន្ធ ឬការបង់ពន្ធមិនបានគ្រប់គ្រាន់ដែលបានរកឃើញតាមការដោះស្រាយបណ្ដឹងតាមផ្លូវតុលាការ រដ្ឋបាលសារពើពន្ធមានសិទ្ធិតាមទារប្រមូលនូវបំណុលពន្ធនេះ រហូតដល់ដំណាច់ឆ្នាំនៃឆ្នាំបន្ទាប់ពីឆ្នាំកាត់ក្តី ។

## ផ្នែកទី ១៣.៥ : បុគ្គលជាប់ពន្ធ និងទីកន្លែងកំណត់ពន្ធ

១- សហគ្រាសនីតិបុគ្គល : ពន្ធត្រូវបានកំណត់យកនៅទីស្នាក់ការរបស់សហគ្រាស ប៉ុន្តែរដ្ឋបាលសារពើពន្ធអាចកំណត់យកពន្ធនៅកន្លែងផ្សេងៗទៀត ដូចជាទីចាត់ការជាក់ស្តែងរបស់សហគ្រាសជាដើម ។

២- សហគ្រាសឯកបុគ្គល : ដូចសហគ្រាសនីតិបុគ្គលដែរ ចំពោះសហគ្រាសឯកបុគ្គលដែលជាប់ពន្ធតាមរបបពិតពន្ធត្រូវបានកំណត់យកនៅគ្រឹះស្ថានរបស់សហគ្រាសនោះប្រសិនបើមានគ្រឹះស្ថានមួយ ឬនៅគ្រឹះស្ថានជាគោលដើមប្រសិនបើមានគ្រឹះស្ថានច្រើន ។

៣- ករណីពិសេសនៃសហគ្រាសធ្វើអាជីវកម្មតាមរយៈគ្រឹះស្ថានជាច្រើនដែលតាំងនៅតំបន់ផ្សេងៗគ្នា :

ក- ពន្ធលើប្រាក់ចំណេញត្រូវកំណត់នៅគ្រឹះស្ថានជាគោលដើម និងក្រោមលេខសំគាល់តែមួយ សំរាប់គ្រប់គ្រឹះស្ថានទាំងអស់ដែលធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជារបស់សហគ្រាស ។

ខ- សហគ្រាសត្រូវបង្កើតនូវគណនីលទ្ធផលដាច់ដោយឡែកសំរាប់គ្រឹស្ថាននីមួយៗ ដោយសារមានការតំរូវដូចតទៅ :

ខ១- ស្តុករបស់គ្រឹះស្ថាននីមួយៗ ត្រូវតែធ្វើសារពើភ័ណ្ឌ និងធ្វើគណនេយ្យកម្មដាច់ដោយឡែក

ខ២- បញ្ជីបើកប្រាក់ ត្រូវតែកាន់សំរាប់កត់ត្រានៅទីកន្លែងធ្វើការជាអចិន្ត្រៃយ៍របស់និយោជិត

ខ៣- បេឡារបស់គ្រឹះស្ថាននីមួយៗ ត្រូវដាច់ដោយឡែកពីគ្នា

ខ៤- ការលក់ ពិសេសការលក់យកប្រាក់ដល់ដៃ គឺត្រូវកត់ត្រាប្រចាំថ្ងៃ ។

គ- សហគ្រាសត្រូវបង្កើតគណនីលទ្ធផលដាច់ដោយឡែកសំរាប់សកម្មភាពអាជីវកម្មនីមួយៗ បើសកម្មភាពអាជីវកម្មនីមួយៗនោះត្រូវជាប់ពន្ធតាមអត្រាខុសៗគ្នា

ឃ- ការប្រកាសបង់ពន្ធលើប្រាក់ចំណេញ: សហគ្រាសត្រូវ :

ឃ១- ដាក់លិខិតប្រកាសប្រចាំឆ្នាំស្តីពីលទ្ធផលសរុបបញ្ចូលរួមគ្នា ដោយមានអមភ្ជាប់ជាមួយនូវគណនីលទ្ធផលរបស់គ្រឹះស្ថាននីមួយៗ ជូនអង្គភាពរដ្ឋបាលសារពើពន្ធនៅក្នុងកន្លែងនៃគ្រឹះស្ថានជាគោលដើម សំរាប់ការបង់ពន្ធលើប្រាក់ចំណេញសរុបបញ្ចូលរួមគ្នារបស់សហគ្រាស

ឃ២- ដាក់ជូនអង្គភាពរដ្ឋបាលសារពើពន្ធនៅកន្លែងដែលគ្រឹះស្ថានបន្ទាប់បន្សំនីមួយៗតាំងនៅ នូវ :

- ច្បាប់ចំលងនៃលិខិតប្រកាសប្រចាំឆ្នាំស្តីពីលទ្ធផលសរុបបញ្ចូលរួមគ្នា ដែលបានដាក់ជូនអង្គភាពរដ្ឋបាលសារពើពន្ធនៅក្នុងកន្លែងនៃគ្រឹះស្ថានជាគោលដើម
- គណនីលទ្ធផលរបស់គ្រឹះស្ថានបន្ទាប់បន្សំដែលជាប់ទាក់ទិន ។

## ជំពូកទី ១៤
## បទប្បញ្ញត្តិស្តីពីរបបម៉ៅការ

### ផ្នែកទី ១៤.១ : កាតព្វកិច្ចរបស់អ្នកជាប់ពន្ធតាមរបបម៉ៅការ

១- ស្របតាមមាត្រា ៣០ នៃចពស ជារៀងរាល់ឆ្នាំអ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវដាក់លិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធក្នុងមូលដ្ឋានដែលខ្លួនមានសកម្មភាពអាជីវកម្ម យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែតុលា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

២- អ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវបង់ពន្ធលើប្រាក់ចំណេញម៉ៅការជារៀងរាល់ខែតាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

### ផ្នែកទី ១៤.២ : ការកំណត់ពន្ធក្នុងរបបម៉ៅការ

១- ស្របតាមមាត្រា ៤ និងមាត្រា ៩៨ នៃចសព សំរាប់គោលដៅខាងពន្ធដារ អ្នកជាប់ពន្ធតាមរបបម៉ៅការពុំមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យតាមប្រព័ន្ធពេញលេញទេ ។ ដូច្នេះហើយ កំណត់ត្រាគណនេយ្យ និងឯកសារផ្សេងទៀតរបស់អ្នកជាប់ពន្ធតាមរបបម៉ៅការ ទោះបីត្រូវបានយកមកប្រើប្រាស់ជាប្រភពពត៏មានមួយដ៏សំខាន់ក៏ដោយ ក៏ពុំមានតំលៃដាច់ណាត់ទេសំរាប់ការកំណត់ចំនួនប្រាក់ចំណេញម៉ៅការត្រូវជាប់ពន្ធ ។ ដូចមានចែងក្នុងមាត្រា ៣០ នៃចសព ចំនួនប្រាក់ចំណេញម៉ៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាង ។

២- ថ្វីបើប្រាក់ចំណេញម៉ៅការនេះ គឺជាកម្មវត្ថុនៃកិច្ចសន្យាដែលអ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធបានចុះហត្ថលេខាជាមួយគ្នាក៏ដោយ ក៏ប្រាក់ចំណេញម៉ៅការនេះមិនមែនបានមកពីការចរចាជាមួយអ្នកជាប់ពន្ធទេ ប៉ុន្តែគឺបានមកពីការវាយតំលៃប៉ាន់ស្មានរបស់រដ្ឋបាលសារពើពន្ធ ដោយផ្អែកលើកត្តាផ្សេងៗដែលរដ្ឋបាលសារពើពន្ធក្តាប់បាន (ការទិញ សោហ៊ុយចំណាយទូទៅ បៀវត្ស ប្រាក់បូរវត្ថុ ដែលម្ចាស់សហគ្រាសបានកាត់យកមុន ឬក៏រឹតជីវភាពរស់នៅរបស់ម្ចាស់សហគ្រាសនិងក្រុមគ្រួសារ...) ។ ផ្អែកតាមលក្ខណៈវិនិច្ឆ័យអាចកត់សំគាល់បាននៃសកម្មភាពអាជីវកម្មណាមួយ រដ្ឋបាលសារពើពន្ធអាចធ្វើការវាយតំលៃនូវក៏រឹតផលរបរ ហើយក្នុងករណីនេះស្របតាមមាត្រា ៣០ នៃចសព ប្រាក់ចំណេញម៉ៅការ ត្រូវគិតតាមអត្រាចំណេញទៅតាមប្រភេទ និងទៅតាមមុខរបរអាជីវកម្ម ។

៣- ក៏រិតពន្ធលើប្រាក់ចំណេញម៉ៅការត្រូវកំណត់ជាស្ថេរវន្តសំរាប់រយៈពេលមួយមានកំណត់ ៣ខែ ៦ខែ ឬ ១ឆ្នាំ ។

## ជំពូកទី ១៥

## អវសានប្បញ្ញត្តិ

### ផ្នែកទី ១៥.១ : ការទុកជានិរាករណ៍

១- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

### ផ្នែកទី ១៥.២ : កាលបរិច្ឆេទអនុវត្ត

១- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ តទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**<u>កន្លែងទទួល:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។